ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MOEURS & COUTUMES

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ២៨ លេខ ៦ ខែមិថុនា ព.ស. ២៤៩៩ គ.ស. ១៩៥៦

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MOEURS & COUTUMES

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

| ផ្នែកសាសនា | បញ្ជីរឿង | ទំព័រ |
|---|---|---|


— ព្រះពុទ្ធសាសនាប្រទេសកម្ពុជា (ត-ចប់) លោក ទៀង-តៃឈុន ប្រែ ..... ៥០៣

— បញ្ហាកថា ................ ព្រះមហាឧត្ដមវិជ្ជា ឈឹម-សាមី ... ៥១៣

— ប្រជុំធម៌ឧបាសក ........... ព្រះទេពសត្ថា កិម-គូ ......... ៥១៩

— ជាតកកថារឿងពុទ្ធរូបបុរាណ (តមក) ... ឃុនអត្ថកោវិទ ជា-យូរ ប្រែ ..... ៥២៧

*ផ្នែកអក្សរសាស្ត្រ*

— បញ្ហាបរិយាយ ............. ព្រះឧបាលិវង្ស សួរ-ហាយ ..... ៥៣៦

— ពេជ្រព្រះរាជា (តមក)........ លោក ស៊ុន-ហ៊ាន ប្រែ ..... ៥៤៤

— រឿងសាមកុក (តមក) ....... ឧកញ៉ា នូ-កន .......... ៥៥២

— រឿងបល្ល័ង្កទិព្វ (តមក) ...... លោក ភ៊យ-ប៊ុក ប្រែ ...... ៥៦១

— រឿងសៅរ៍សោយ (តមក) ....... ព្រះមហាឧត្ដមវិជ្ជា ប៊ុង-ប៉ម ..... ៥៦៧

— សកម្មភាពនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ... លោក ជាប-ពិន .......... ៥៧៨

*កំណត់និងប្រវត្តិការណ៍*

— ដំណើរទៅកាន់ប្រទេសភូមានៃប្រតិភូ៨រូប ព្រះញាណវីរិយៈ ភ៊ន-សាឆុម ... ៥៨៨

— ដំណើរគណៈប្រតិភូខ្មែរ ទៅប្រជុំសន្និសីទ នៅពុទ្ធគយាប្រទេសឥណ្ឌា ....... លោក ជាប-ពិន .......... ៥៩៨


មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជារ ២៣០រ, ០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

## *TABLE DES MATIÈRES*

PARTIE RELIGIEUSE: *Page*

— Le Bouddhisme au Cambodge (suite et fin) . . . . . . . . . *Traduit par M. TIANG-TAY-CHHUN* . . . . . . 503
— Pannhākathā . . . . . . . . . *par Vénérable CHHIM-SAMEY* 513
— Les règles Bouddhiques des fidèles . . . . . . . . . . . *par Vénérable KEM-TO* . . . 519
— Les statues Bouddhiques primitives (suite) . . . . . *Traduit par M. CHEA-YOU*.. 527

PARTIE LITTÉRAIRE:

— Pannhāpariyay . . . . . . . . . *par Vénérable SO-HAY* . . . . 536
— Conte "Le Diamant du Raja" (suite) . . . . . . . . . . . *Traduit par M. SIN-HEAN* . 544
— Histoire de Samkok (suite) . . *par l'Oknha NOU-KAN* . . . . 552
— Les trente-deux récits du Trône (suite) . . . . . . . . . *Traduit par M. RAY-BOUC* 561
— Le "Sau-Soy" ou l'influence saturnienne (suite) . . . . . *par Vénérable PEUNG-PAM*... 567
— Les activités de la Commission des Moeurs et Coutumes du Cambodge . . . . . . . . . *pur M. CHAP-PIN* . . . . 568

NOTES ET CHRONIQUES:

— Voyage de la Commission religieuse Camdodgienne dn Birmanie . . . . . . . . . *par Vénérable VANN-SADUM* 588
— Voyage de la Délégation Cambodgienne à la conférence Bouddhique de Boddhagaya . *par M. CHAP-PIN* . . . . 598

**Prix d'abonnement annuel** (comprenant 12 numéros) 230$00

## ផ្នែកសាសនា

# ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា

ព្រះគ្រូសង្ឃសត្ថា ប៉ុណ្យ-សុម្ភាជ ធម្មារាមៈ
សាស្ត្រាចារ្យនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត នៅភ្នំពេញ,
សមាជិកឆ្លើយឆ្លងនៃសាលាបារាំងសែសប៉ែកចុងបូព៌ាប្រទេស,
សមាជិកនៃគណៈកម្មការវប្បធម៌ខ្មែរ បានតែងជាភាសាបារាំង
លោក ទៀង-តៃ-ឈុន ក្រមការដើមខ្សែ ប្រែជាភាសាខ្មែរ

(ត-ចប់)

នៅក្នុងសាលានោះក្រៅពីបង្រៀនភាសាបាលី មានបង្រៀនចំណេះវិជ្ជាឯទៀតមួយពេលៗ ។ ព្រះសង្ឃដែលបានបំពេញចំណេះវិជ្ជា ចំនួន ៤ ឆ្នាំរួចហើយ ៗ បានសញ្ញាប័ត្រសាលាបាលីជាន់ខ្ពស់នោះ មានចំនួនច្រើនពាន់អង្គទៅហើយ ។ សាលាបាលីជាន់ខ្ពស់នោះ ដែលមានសមណសិស្សចំនួន៥០០អង្គ, ដល់មកឆ្នាំនេះបានផ្លាស់ឈ្មោះជា "ពុទ្ធិកវិទ្យាល័យ ព្រះសុរាម្រឹត" តាមព្រះរាជបញ្ញត្តិ ។ បន្ទាប់មកទៀត នៅក្នុង គ.ស. ១៩២៥ ព្រះរាជរដ្ឋាភិបាលបានបង្កើតព្រះរាជបណ្ណាល័យ ហើយនឹងមន្ទីរពុទ្ធសាសនបណ្ឌិត្យ នៅក្នុង គ.ស. ១៩៣០ ដោយស្នាដៃនៃនាងកញ្ញា "ស. កាប៉ែលេស" ជាសមាជិកនៃសាលាបារាំងសែសចុងបូព៌ាប្រទេស ។ តមកទៀត បានបង្កើតមន្ទីរក្រុមជំនុំព្រះត្រៃបិដក ដែលមានព្រះសង្ឃអ្នកមានចំណេះវិជ្ជាយ៉ាងជ្រាលជ្រៅ ឲ្យចាប់ប្រែពីភាសាបាលី មកជាភាសាខ្មែរ ។ ការប្រែព្រះត្រៃបិដកភាសាបាលីមកជាភាសា

ខ្មែរនោះ ចាប់ប្រែវិនយបិដកជាមុន, ក្នុងការប្រែនេះមានយកសៀវភៅបាលីអក្សរភូមា និងសៀវភៅបាលីអក្សរសៀម ដែលគេបោះផ្សាយរួចហើយ មកប្រៀបធៀបនឹងគម្ពីរអក្សរខ្មែរផងដែរ ដើម្បីពិនិត្យផ្ទៀងផ្ទាត់ឲ្យត្រឹមត្រូវម៉ត់ចត់ ហើយបោះពុម្ពផ្សាយក្នុងព្រះរាជអាណាចក្រទាំងមូល ព្រមទាំងផ្សាយទៅក្នុងប្រទេសទាំងឡាយខ្លះដែលកាន់ព្រះពុទ្ធសាសនាដូចគ្នា ។

ដល់មកឆ្នាំ ១៩៣៣ គេបានបង្កើតសាលាបាលីរង ក្នុងវត្តទីក្រុង និងខែត្រក្រៅចំនួន ៤០០ សាលា ស្ទើរតែគ្រប់វត្ត ហើយមានសមណសិស្សជាង ២.០០០ អង្គ បានបំពេញចំណេះវិជ្ជាគ្រប់ ៣ ឆ្នាំ រួចបានទទួលសញ្ញាប័ត្រសាលាបាលីរង ។ សាលាបាលីរងទាំងនោះបំរុងនឹងផ្លាស់ទៅជាសាលាបឋមសិក្សាបាលីវិញ ។

ក្រោយបន្តិចគេបានបង្កើតសាលាធម្មវិន័យនៅគ្រប់វត្ត ក្នុងព្រះរាជអាណាចក្រកម្ពុជា ដើម្បីបង្រៀនភិក្ខុសាមណេរទាំងចាស់ទាំងក្មេងជាការចាំបាច់ ។

ក្នុងឆ្នាំ ១៩៥៥ គេបានឃើញគ្រឹះស្ថានមួយខ្ពង់ខ្ពស់ទទុំងនៅខាងមុខព្រះបរមរាជវាំង ហៅថា " ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ" ដែលគេបានសម្រេចនឹងបង្កើតតាំងពីឆ្នាំ ១៩៥៤ នោះមក ។ មហាវិទ្យាល័យថ្មីនេះ នឹងបើកឲ្យតែនិស្សិតដែលមានសញ្ញាប័ត្រមធ្យមវិជ្ជាខាងព្រះពុទ្ធសាសនា ឬ អ្នកដែលមានសញ្ញាប័ត្រដម្លៃស្មើគ្នា ទើបចូលរៀនបាន ។

ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងជាអគ្គពុទ្ធសាសនូបត្ថម្ភក ។

ព្រះមហាក្សត្រ នរោត្តម-សីហនុ វរ្ម័ន ដែលសព្វថ្ងៃបានទទួលតំណែងជាសម្ដេចព្រះឧបយុវរាជ បានដាក់រាជសម្បត្តិ ហើយថ្វាយរាជ្យនោះចំពោះព្រះវររាជបិតានិងព្រះវររាជជននីនាថ ទ្រង់សោយរាជសម្បត្តិតពីព្រះអង្គមក ។ កាលសម្ដេចទ្រង់សោយរាជ្យនៅឡើយ ទ្រង់គ្មានអាឡោះអាល័យបានទ្រង់យាងចុះពីព្រះរាជបល្ល័ង្ក ទៅបំពេញអភិនេស្ក្រមអស់រយៈ ៣ ខែ គឺ ១ វស្សា ។ ទ្រង់បានលើកទឹកចិត្តព្រះសង្ឃនិងលើកតម្កើងសាសនាឲ្យបានរុងរឿងឡើង ហើយថែមទាំងបំណាយព្រះរាជ-ទ្រព្យផ្ទាល់ព្រះអង្គ ដើម្បីកសាងសាលាខាងពុទ្ធចក្រនិងខាងអាណា-ចក្រនៅក្នុងព្រះរាជអាណាចក្រទាំងមូល ។ ពុទ្ធិកមហាវិទ្យាល័យដែលបានថ្លែងរួចមកហើយនោះ ក៏ជាស្នាព្រះហស្តនៃព្រះអង្គជាដើមគំនិតព្រមទាំងទ្រង់បានចូលព្រះរាជទ្រព្យកសាងផង ទើបមហាវិទ្យាល័យនេះមាននាមថា « ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ » ។

ការស្ថាបនានិងសរីរការខាងលើទាំងប៉ុន្មាននេះ នាំឲ្យមានប្រយោជន៍ដ៏ពិសេសដល់ព្រះពុទ្ធសាសនា ហើយនឹងនាំសមាជិកនៃគណៈសង្ឃឲ្យបានចំរើនចំណេះវិជ្ជាស្មើ ៗ គ្នា ហើយនឹងឲ្យព្រះសង្ឃទាំងនោះកាន់ពុទ្ធបញ្ញត្តិត្រឹមត្រូវ តាមដែលព្រះបរមគ្រូនៃយើងសំដែងទុកមក ។ តាំងពីពេលនេះទៅ គណៈព្រះសង្ឃគ្មានខ្វែងគំនិតគ្នាពីរឿងពាក្យប្រៀនប្រដៅឡើយ មានតែសេចក្ដីស្ងប់ស្ងាត់ នឹងចំរើនទៅអនាគតកាល ។

ក្រៅពីស្ថាបនាការ ដែលបានរៀបរាប់ខាងលើរួចមកហើយនោះ មានបង្កើតសមាគមពីរទៀត ហៅថា:

— សមាគមមិត្តសាលាបាលី;

— ពុទ្ធិកសមាគមពិភពលោក ។

សមាគមទី១ សម្រាប់លើកទឹកចិត្តព្រះសង្ឃ ដើម្បីឲ្យខំបំពេញចំណេះវិជ្ជា ជាភាសាបាលី ភាសាជាតិ ឬក៏ភាសាបរទេស ។ ចំណែកខាងសមាគមទី ២ សម្រាប់ធ្វើការទាក់ទងពីរឿងព្រះពុទ្ធសាសនាក្នុងសកលលោក ។

ប្រជាជាតិខ្មែរធ្លាប់ធ្វើពិធីបុណ្យ ដែលត្រូវតាមព្រះពុទ្ធសាសនាទាំង ១២ ខែ ក្នុងមួយឆ្នាំ ៗ ។ ឯពិធីបុណ្យដែលមានឈ្មោះជាងគេនោះគឺៈ

១.— បុណ្យចូលឆ្នាំ ធ្វើនៅថ្ងៃ ១៣ - ១៤ - ១៥ ខែមេសា ។ នៅឱកាសចូលឆ្នាំថ្មីនោះ គេមានធ្វើពិធីបុណ្យ "ពូនភ្នំខ្សាច់" ជាតំណាង "ព្រះចូឡាមណីចេតិយ" ដែលដំកល់ព្រះកេសានៃព្រះសម្ពុទ្ធកាលព្រះអង្គយាងចេញចាកមហាប្រាសាទទៅទ្រង់ព្រះផ្នួស ។

២.— បុណ្យវិសាខបូជា ធ្វើក្នុងខែឧសភានៅក្នុងព្រះបរមរាជវាំង ហើយនឹងក្នុងវត្តទាំងអស់ ក្នុងព្រះរាជាណាចក្រកម្ពុជា ។ បុណ្យនេះជាបុណ្យខួបនៃកំណើតព្រះសម្ពុទ្ធ ដែលទ្រង់ប្រសូត, ទ្រង់ត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណ និងទ្រង់ចូលព្រះបរមនិព្វាន ។ ប្រទេសដទៃដែលកាន់លទ្ធិព្រះពុទ្ធសាសនាតែងធ្វើបុណ្យនេះដែរ ។

៣.— បុណ្យច្រត់ព្រះនង្គ័ល គេធ្វើនៅថ្ងៃ ៤ កេីត ខែពិសាខ (ឧសភា) នៅក្រុងភ្នំពេញ ។ បុណ្យនេះធ្វើតាមទម្លាប់ពីបុរាណ ដើម្បី

រំឭកព្រះរាជប្រវត្តិនៃព្រះបាទសុទ្ធោទនៈ ដែលត្រូវជាព្រះបរមរាជបិតានៃព្រះសម្ពុទ្ធ កាលដែលទ្រង់នាំព្រះសិទ្ធត្ថៈកុមារទៅក្នុងពិធីបុណ្យច្រត់ព្រះនង្គ័លនោះ ។

ក្នុងពិធីបុណ្យនោះ គេឃើញមានអ្នកតំណាងព្រះរាជាម្នាក់ ( ស្តេចមាឃ ) កាន់យាមនង្គ័ល ដែលមានលក្ខណៈជានិមិត្តរូប ហើយភ្ជួរ ៣ ជុំលើដីមួយកន្លែងដែលគេសន្មតជាព្រះស្រែ ។ នៅខាងក្រោយស្តេចមាឃនោះ មានស្ត្រីមួយនាក់ស្លៀកពាក់សំពត់សម្រាប់ពិធីបុណ្យ ដើរពីមុខស្ត្រីឯទៀតដែលតាមហែហម ហើយសាបព្រោះក្នុងគន្លងដែលទើបនឹងភ្ជួររួចថ្មីៗ ។ ពិធីបុណ្យនេះជាសញ្ញានៃការភ្ជួរស្រែចម្ការនៅក្នុងព្រះរាជអាណាចក្រកម្ពុជាទាំងមូល ។

៤.— បុណ្យបំបួសនាគ គេធ្វើនៅប្រទេសកម្ពុជា ក្នុងខែទាំងឡាយគ្រប់ជួរ លើកតែ ៣ ខែដែលចូលវស្សាចេញ តែចំណែកខាងព្រះរាជវង្សានុវង្ស ធ្លាប់ធ្វើបុណ្យនេះមុនថ្ងៃចូលវស្សាមួយថ្ងៃ ។ បព្វជ្ជាបេក្ខៈខាងព្រះរាជវង្សានុវង្ស នឹងបព្វជ្ជាបេក្ខៈខាងគ្រួសារមន្ត្រី ដែលមានស័ក្តិយសខ្ពស់ ហើយដែលសុំអនុញ្ញាតបួសនោះ ក្រោមអធិបតីភាពនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ត្រូវមានចំនួនតែ ១២ នាក់យ៉ាងច្រើនបំផុត ។ គេនិមន្តព្រះសង្ឃមកចំរើនព្រះបរិត្តចំពោះបព្វជ្ជាបេក្ខៈទាំងនោះនៅពេលល្ងាច ។ លុះព្រឹកឡើងនាគទាំងអស់ដើរជាក្បួនដង្ហែទៅវត្ត ។ ដោយហេតុថាព្រះសម្ពុទ្ធជាក្សត្រ ហើយទ្រង់ចេញពីជាតិក្សត្រនោះទៅ ដើម្បីស្រោចស្រង់សត្វលោក គួរតែក្បួនដង្ហែនាគនោះ

មានទំនងជាក្បួនដង្ហែស្តេច បើប្រសិនជាអាចនឹងធ្វើបាន ។ នៅក្នុងក្បួនដង្ហែនោះ មានគ្រឿងនឹងឆ្នុកជ័យស្គរ មានប្រុស-ស្រីកាន់ជើងពានប្រាក់ ដែលមានដាក់ស្បង់ បាត្រ នឹងទៀនធូប គុបតែងលំអដើរពីមុខនាគដែលស្លៀកពាក់ដូចព្រះអង្គម្ចាស់ពីដើម ហើយដែលជិះសេះមានបាំងក្លស់យ៉ាងធំផង ។

បន្ទាប់មក នាគទាំងអស់ដើរចូលទៅក្នុងព្រះវិហារ ហើយអុជទៀននឹងធូប រួចក្រាបថ្វាយបង្គំព្រះពុទ្ធរូប ។ តពីនេះទៅនាគនោះដើរឆ្ពោះទៅមុខឧបជ្ឈាយ៍ដែលមានព្រះសង្ឃចំនួន ២០ អង្គ ហើយក៏សុំបួស ។

៥.— បុណ្យចូលវស្សា មាននៅប្រទេសកម្ពុជា ដូចជាប្រទេសដែលកាន់លទ្ធិព្រះពុទ្ធសាសនាដែរ ។ ព្រះសង្ឃត្រូវសម្រាកចំនួន ៣ ខែជាដំបូងក្នុងរដូវភ្លៀង ។ នៅឱកាសបុណ្យនោះ ក្នុងវត្តនីមួយៗត្រូវមានអុជទៀនវស្សាដែលគេយកឈើមកធ្វើបំពង់លាបពណ៌ ទង់គុបតែងលំអ ហើយគេចាក់ក្រមួនក្នុងបំពង់នោះជុំវិញប្រឆេះ ។ ជួនណាទៀនវស្សានោះគេធ្វើពីក្រមួនសុទ្ធតែម្តង ហើយមានទំហំប៉ុនពីរឆ្អាប់ កំពស់ពីរហត្ថ ។

នៅក្នុងព្រះបរមរាជវាំង ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ឬសមាជិកនៃព្រះរាជវង្សានុវង្ស អុជទៀនវស្សា ៤ ដើមដោយឧឡារិក ។ ទៀនទី ១ អុជទុកក្នុងហោព្រះ ក្នុងព្រះបរមរាជវាំង ។ ទៀនទី ២ អុជក្នុងហោព្រះអដ្ឋិក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ ដែលមានកោដ្ឋព្រះធាតុនៃព្រះ

រាជវង្សានុវង្ស ។ ទៀនទី ៣ អុជទុកក្នុងហោព្រះខ័នរាជ្យ ។ ទៀនទី ៤ អុជទុកនៅក្នុងព្រះវិហារព្រះកែវមរកត ។

ក្រៅពីនេះ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង បានត្រាស់បង្គាប់ឲ្យនាំទៀនវស្សាទៅដាក់វត្តនៅក្នុងទីក្រុង និងវត្តជិតខាង ។ ចំនួនទៀនវស្សាព្រះរាជទ្រព្យទាំងអស់ ១៩ ដើម ។

មុនថ្ងៃចូលវស្សា គឺនៅថ្ងៃពេញបូណ៌មីខែអាសាឍ ការអុំអរតែងមាននៅគ្រប់វត្តទាំងអស់ ។ នៅពេលព្រលប់គេធ្វើពិធីដង្ហែទៀនវស្សាជាមួយនឹងសាដកសម្រាប់ព្រះសង្ឃស្រង់ទឹក ហើយនិងបរិក្ខារផ្សេងៗផង ។

៦.— បុណ្យភ្ជុំបិណ្ឌ ធ្វើនៅគ្រប់វត្តទាំងអស់ចំនួន ១៥ ថ្ងៃ គឺចាប់តាំងពីថ្ងៃ ១ កើតដល់ថ្ងៃ ១៥ កើត ខែភទ្របទ (កញ្ញា) ដើម្បីឧទ្ទិសចំពោះញាតិសន្តាន ដែលបានអនិច្ចកម្មបាត់ទៅហើយ ។

ព្រះបាទយសោវរ្ម័ន ដែលសោយរាជសម្បត្តិពី គ. ស. ៨៨៩ ដល់ ៩១០ (នៅអង្គរ) បានចារិកទុកថា ព្រះអង្គបានប្រគេនបង្ហាន់រៀងរាល់ខែ ដល់ព្រះសង្ឃគង់នៅក្នុងកុដិជាច្រើន ដែលទ្រង់បានកសាង ដើម្បីឧទ្ទិសដល់មនុស្សស្លាប់ក្នុងចម្បាំង និងព្រលឹងមនុស្សដែលគេបោះបង់ចោល ។

ក្រៅពីបុណ្យដែលបានរៀបរាប់ខាងលើនេះ មានបុណ្យផ្សេងៗឯទៀតៗ ជាច្រើន ដូចជាបុណ្យចេញវស្សា, បុណ្យកឋិន, បុណ្យសំពះព្រះខែ (អកអំបុក) ។ល។ បុណ្យទាំងនោះមានរបៀបធ្វើខុសគ្នាបន្តិចៗ ដោយមានបុណ្យខ្លះធ្វើតាមរបៀបសាសនាព្រាហ្មណ៍ តែការបញ្ចូល

ទម្លាប់សាសនាព្រាហ្មណ៍យ៉ាងនេះ មិនអាចនាំឲ្យជួយគ្នានឹងច្បាប់ព្រះសមុទ្រឡើយ ។

នៅប្រទេសកម្ពុជា សាសនាព្រះពុទ្ធបានរុងរឿងលូតលាស់យ៉ាងប្រសើរណាស់ ដោយគេបានកសាងវត្តនិងសាលាបាលីជាច្រើន នៅទីរួមខេត្តខ្វះក្នុងប្រទេសកម្ពុជាឯកជ្យ ។ តាំងពីយូរណាស់មកហើយ បុណ្យពុទ្ធជយន្តិ (បុណ្យវិសាខបូជា) គេធ្វើជាដរាបនៅគ្រប់តែវត្ត តែកាលពីខែតុលា គ.ស. ១៩៥២ នៅទីក្រុងភ្នំពេញ គេបានរៀបពិធីបុណ្យនេះ ដើម្បីទទួលព្រះសារីរិកធាតុព្រះសមុទ្ធ និងព្រះអរហន្តធាតុនៃព្រះអគ្គសាវកទាំងពីរព្រះអង្គ គឺព្រះសារីបុត្រ និងព្រះមោគ្គល្លាន ។ ពិធីបុណ្យនេះ គេធ្វើនៅក្រោមព្រះរាជាធិបតីភាពនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងសម្តេចសង្ឃនាយកទាំងពីរគណៈ ព្រមទាំងវរជនបរទេសដែលកាន់លទ្ធិព្រះពុទ្ធសាសនាដែរ ។ រួចពីនោះមក គេបានសង់ចេតិយមួយយ៉ាងខ្ពស់ត្រដឹម កណ្តាលក្រុងភ្នំពេញ ដើម្បីបញ្ចុះព្រះសារីរិកធាតុនិងព្រះអរហន្តធាតុនោះ ទុកជាទីរលឹកគោរពបូជាតទៅអនាគតកាល ។ ក្នុងរឿងនេះ យើងសូមបំភ្លឺដល់អ្នកអានថា បុណ្យសម្ពោធពុទ្ធសករាជគម្រប់ ២.៥០០ ព្រះវស្សា ដែលធ្វើនៅក្នុងប្រទេសផ្សេងៗ មានកំណត់ពេលវេលាខុសពីគ្នា ដូចយ៉ាងនៅប្រទេសឥណ្ឌា, កោះសេរីលង្កានិងភូមា សម័យដែលត្រូវធ្វើបុណ្យនេះនៅដើមឆ្នាំមុន, តែនៅប្រទេសសៀម, កម្ពុជា, លាវ និងវៀតណាម បុណ្យនេះគេធ្វើនៅចុងឆ្នាំក្រោយ ។ ហេតុដូច្នេះ បានជាកាលបរិច្ឆេទនោះខុស

គ្នាមួយឆ្នាំ គឺប្រទេសឥណ្ឌា កោះស៊េរីលង្កា និងភូមា ត្រូវធ្វើពិធីបុណ្យនេះនៅថ្ងៃ ២៤ ឧសភា គ. ស. ១៩៥៦ ចំណែកប្រទេសអាស៊ីអាគ អគ្នេយ៍ ដែលបានរៀបរាប់ខាងលើរួចមកហើយនោះ ត្រូវធ្វើបុណ្យសម្ពោធពុទ្ធសករាជគម្រប់ ២.៥០០ ព្រះវស្សានៅថ្ងៃ ១៣ ឧសភា គ. ស. ១៩៥៧ ។ យើងមានសេចក្ដីស្ដាយជាទីបំផុត ចំពោះការដែលកំណត់ធ្វើបុណ្យខាងលើនេះខុសគ្នាមួយឆ្នាំដូច្នេះ, រឿងនេះបើតាមយោបល់យើងយល់ថា មានតែអ្នកប្រាជ្ញខាងព្រះពុទ្ធសាសនានៅប្រទេសខ្លះទេ ទើបវិនិច្ឆ័យបាន ។

ម្យ៉ាងទៀត យើងសូមរំលឹកថា នៅឱកាសពាក់កណ្ដាលសករាជនៃព្រះពុទ្ធសាសនា យើងត្រូវធ្វើបុណ្យខួបនៅក្នុងទីក្រុងណា ដែលមានសង់ចេតិយបញ្ចុះព្រះសារីរិកធាតុព្រះពុទ្ធ ។ យើងសូមទទួលអំណរគុណដ៏ជ្រាលជ្រៅចំពោះសមាគម "មហាពោធិ" នៅប្រទេសឥណ្ឌា ដែលបានអញ្ជើញមកជាកិត្តិយស ជួយឧបត្ថម្ភដល់ពិធីបុណ្យទទួលព្រះសារីរិកធាតុនេះពីឆ្នាំ ១៩៥២ ។ ដើម្បីជាអនុស្សាវរីយ៍ចំពោះព្រះសារីរិក-ធាតុដែលបានស្ដេចមកកាន់ប្រទេសកម្ពុជានោះ គេបានសាងព្រះចេតិយ ១ យ៉ាងល្អ កណ្ដាលក្រុងភ្នំពេញ ហើយគេបម្រុងនឹងធ្វើបុណ្យសម្ពោធទុកជាទីគោរពបូជាតទៅអនាគត ។ យើងសង្ឃឹមថា គង់មានឱកាសណាមួយយើងនឹងបានទទួលព្រះសារីរិកធាតុជាពិសេសអំពីប្រទេសឥណ្ឌា ឬកោះស៊េរីលង្កា ឬក៏ប្រទេសភូមាមកបញ្ចុះក្នុងព្រះចេតិយនោះជាមិនខាន ។

នៅទីបំផុតនេះ សូមបញ្ចប់សេចក្ដីថ្លែងការណ៍ខាងលើ ហើយសូមប្រសិទ្ធីពរចំពោះពិធីបុណ្យសម្ពោធពុទ្ធសករាជគម្រប់ ២.៥០០ ព្រះវស្សា ដែលជាគោលចារិកនៃព្រះពុទ្ធសាសនា ហើយដែលនាំឲ្យបានសេចក្ដីសុខក្សេមក្សាន្តក្នុងអនាគតកាល ។

---

## បុរាណសុភាសិត

១ – មនុស្សដែលស្វែងរកភោគទ្រព្យ ដោយល្បែងស៊ីសង

២ – មនុស្សដែលស្វែងរកកិត្តិយស ដោយដាក់ខ្លួនឲ្យអ្នកដទៃប្រើប្រាសតាមត្រូវការ

៣ មនុស្សដែលស្វែងរកសេចក្ដីសប្បាយ ដោយធ្វើជាស្មូមយាចក

៤ – មនុស្សដែលប្រព្រឹត្តចិញ្ចឹមជីវិតដោយចោរកម្ម ។

បុគ្គលទាំង ៤ ពួកនេះ ជាមនុស្សពាលអាប់ឥតប្រាជ្ញា ត្រូវទទួលនូវសេចក្ដីវិនាសក្នុងអនាគតជាប្រាកដ ។

# បញ្ញាកថា

ព្រះមហាឧត្តមវិជ្ជា ឈឹម-សាមី រៀបរៀង

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

លំដាប់នេះ សូមសំដែងអំពីដើមកំណើតនៃបញ្ញា និងហេតុផលដែលនាំឲ្យកើតបញ្ញា ជាសេចក្ដីសង្ខេបដូចមានតទៅនេះ:

ធម្មជាតិណាដែលសម្រាប់ដឹងដោយប្រការៈទាំងពួង ធម្មជាតិនោះហៅថា បញ្ញា ដូចមានវិគ្គហៈថា សព្វប្បការេន ជានាតីតិ បញ្ញា: ប្រែថា ( ធម្មជាតិណា ) ដឹងដោយប្រការសព្វគ្រប់ ( ធម្មជាតិនោះ ) ឈ្មោះថា បញ្ញា ៗ បញ្ញានេះ បើពណ៌នាតាមគម្ពីរវិសុទ្ធិមគ្គនិងបញ្ញានិទ្ទេស ឃើញថាមានសេចក្ដីពិស្ដារជ្រាលជ្រៅពន់ពេកណាស់ ហេតុនេះ សូមពណ៌នាលះយកតែសេចក្ដីណា ដែលមានខ្លឹមសារគួរដល់ការប្រតិបត្តិរបស់សាធុជន ៗ ឱកាសនេះ និងសូមពណ៌នាតែអំពីហេតុ-ផល និងលក្ខណៈរបស់បញ្ញាដោយសេចក្ដីសង្ខេប :

ហេតុដែលនាំឲ្យកើតបញ្ញា មាន ៨ យ៉ាង គឺ

១ — អាចរិយគារវោ — ការគោរពចំពោះអាចារ្យ

២ — បរិបុច្ឆកតា — ការសួរសេចក្ដីសាកសួរ

៣ — បាបវិរតិ — ការវៀរចាកបាប

៤ — សីលសំវរោ — ការសង្រួមក្នុងសីល

៥ – ពាហុសច្ចំ សេចក្ដីចេះដឹងក្នុងផ្លូវលោកផ្លូវធម៌

៦ – វីរិយារម្ភោ ការព្យាយាមយ៉ាងតឹង

៧ – សតិ ការចងចាំច្រើន (ស្មារតី)

៨ – បញ្ញា ការដឹងការស្គាល់ដោយល្អ ។

សូមអធិប្បាយមួយម្ដង ៗ ដូចតទៅនេះ ៖

ការគោរពចំពោះអាចារ្យ គឺការយកចិត្តទុកដាក់ផ្ចិតផ្ចង់បំរើចំពោះគ្រូអាចារ្យ ព្រោះថាបើសិស្សគោរពអាចារ្យ ៗ តែងខំបង្ហាត់បង្រៀនដល់សិស្ស ទាំងអនុគ្រោះពន្យល់សិស្សឱ្យបានចេះដឹងច្រើន ដែលជាហេតុឱ្យសិស្សកើតមានប្រាជ្ញា ។

ការធ្វើសេចក្ដីសាកសួរ គឺការប្រតិបត្តិសិទ្ធស្នាលចំពោះលោកអ្នកចេះដឹងច្រើន ហើយបើឆ្ងល់ហេតុត្រង់ណាមួយ ត្រូវសាកសួរលោកដើម្បីផ្ចិតយក ឬចម្លងយកចំណេះអំពីលោក ។

ការវៀរបាកបាប គឺការលះបង់អំពើអាក្រក់ឱ្យស្រឡះ ដើម្បីធ្វើទឹកចិត្តរបស់ខ្លួនឱ្យរង់ថ្លាស្អាតបរិសុទ្ធល្អ ទើបសេចក្ដីឆ្លៀវឆ្លាសកើតមានឡើង ព្រោះមិនមានអំពើណាមកអាក្រក់ បញ្ញារមែងកើតឡើងបាន ។

ការសង្រួមក្នុងសីល គឺការរក្សាកាយ-វាចា-របស់ខ្លួនឱ្យតាំងនៅក្នុងសេចក្ដីរៀបរយបរិសុទ្ធ មាំមួន ដើម្បីធ្វើឱ្យកើតមានសេចក្ដី

អង់អាច មានឥទ្ធិឫទ្ធិក្នុងទីប្រជុំបរិស័ទ្យ បញ្ញារមែងកើតឡើងដោយសេចក្ដីក្លៀវក្លានោះ ។

សេចក្ដីចេះដឹងក្នុងអធិលោកអធិធម៌ គឺការឧស្សាហ៍សង្វាតខ្មីឃ្មាតស្ដាប់ពាក្យប្រដៅពាក្យពន្យល់រឿយៗ ញឹកញយៗ ដើម្បីឱ្យការចេះដឹងកើតមានក្នុងខ្លួនសន្ដានរបស់ខ្លួនច្រើនឡើងៗ ។

ការព្យាយាមយ៉ាងតឹង គឺការឧស្សាហ៍ស្វាធ្យាយព្យាយាមសិក្សា នឹងព្យាយាមស្ដាប់ត្រិះរិះគិតត្រាតែចូលចិត្តច្បាស់លាស់មិនមានបន្ធូយបន្ថយព្យាយាម ។

ការចងចាំច្រើន (ស្មារតី) គឺការតាំងស្មារតីចងចាំមាំមួនខ្ជាប់ខ្ជួនល្អជាដើម ។

ការដឹងឬស្គាល់ដោយល្អ គឺការស្គាល់ឬការចេះដឹងអ្វីទាំងពួងដោយល្អ គឺចេះអ្វីចេះច្បាស់ ដែលហៅថា "សុបញ្ញា" ឬ "សុវិជ្ជា" ។

បញ្ញានេះឯង បើសំដែងតាមលក្ខណៈ មានពីរយ៉ាងគឺ

១ – ឆេទនលក្ខណបញ្ញា ប្រាជ្ញាមានកិរិយាកាត់ផ្ដាច់នូវសេចក្ដីសង្ស័យងឿងឆ្ងល់ចេញបានជាលក្ខណៈ ។

២ – ឱភាសលក្ខណបញ្ញា ប្រាជ្ញាមានកិរិយាភ្លឺស្វាងអាចកំចាត់បង់នូវមន្ទិលគ្រប់យ៉ាងមានអវិជ្ជាជាដើម ជាលក្ខណៈ ។

តអំពីនេះទៅ សូមសំដែងអំពីពន្លឺរស្មីនៃប្រាជ្ញា ដូចតទៅនេះ:

# នត្ថិ បញ្ញា សមា អាភា

"ពន្លឺទាំងឡាយស្មើដោយពន្លឺគឺប្រាជ្ញាមិនមានឡើយ" ។ ពន្លឺទាំងឡាយក្នុងលោក មានពន្លឺព្រះអាទិត្យ ព្រះចន្ទនិងពន្លឺអគ្គិសនីជាដើម សម្រាប់បំភ្លឺតែភ្នែករបស់ជនានុជនទាំងពួង ឲ្យឃើញបានតែរូបផ្សេងៗ ប៉ុណ្ណោះ ពុំអាចនឹងឲ្យឃើញដល់ហេតុនិងផលទាំងពួងក្នុងលោកនេះ និងលោកខាងមុខបានឡើយ ។ ឯពន្លឺពោលគឺបញ្ញាអាចដឹកនាំសន្តានចិត្តរបស់ជនទាំងពួងឲ្យឃើញនូវហេតុនិងផលក្នុងលោកទាំងពីរបាន ។

ហេតុដូច្នោះ បញ្ញាទើបឈ្មោះថាជារតនៈរបស់ចិត្ត គឺជាពន្លឺរបស់ចិត្ត អាចដឹកនាំចិត្តឲ្យពិចារណាឃើញថា របស់នេះជាហេតុនៃសេចក្តីសុខ របស់នេះជាហេតុនៃសេចក្តីទុក្ខជាដើម ឧទាហរណ៍ដូច ការប្រព្រឹត្តសុចរិតត្រឹមត្រូវល្អ ជាហេតុនៃសេចក្តីសុខ; ការប្រព្រឹត្តទុច្ចរិតអាក្រក់ ជាហេតុនៃសេចក្តីទុក្ខជាដើម ។ ពន្លឺគឺបញ្ញានេះឯង អ្នកប្រាជ្ញទាំងឡាយសរសើរថា ជាពន្លឺយ៉ាងឆ្នើម ជាងពន្លឺដែលមាននៅក្នុងលោក ។

ក្នុងលោកយើងនេះ របស់អ្វីសុទ្ធសឹងកើតមកអំពីហេតុ ឯហេតុនោះមានច្រើនយ៉ាងច្រើនប្រការណាស់ តែក្នុងទីនេះ ពោលតែហេតុ ២ យ៉ាង គឺហេតុនាំឲ្យថោកទាបនិងឲ្យទ័លក្រភោគសម្បត្តិ ១, ហេតុដែលនាំឲ្យថ្កុំថ្កើងរុងរឿង និងនាំឲ្យបរិបូណ៌ភោគសម្បត្តិ ១ ។

អស់លោកអ្នកសប្បុរសទាំងឡាយសឹងជ្រាបមកហើយថា ការនាំឲ្យថោកទាប មកអំពីល្ងង់ខ្លៅជាហេតុ, ការល្ងង់ខ្លៅ មកពីការខ្ជិលច្រអូស មិនស្វះស្វែងប្រឹងប្រែងរករៀនចំណេះវិជ្ជាសម្រាប់លោកជា

ហេតុ, ការនាំឲ្យទ័លក្រគោគសម្បទ មកពីគ្មានចំណេះវិជ្ជាសម្រាប់លោកនិងការខ្វិលប្រឹស្រគ្មានព្យាយាមជាហេតុ; ការនាំឲ្យជុំចើនរុងរឿង មកពីការមានចំណេះវិជ្ជាសម្រាប់លោកជាហេតុ; ការនាំឲ្យបរិបូណ៌ដោយគោគសម្បត្តិ មកពីការមានចំណេះវិជ្ជាសម្រាប់លោកជាហេតុផង ប្រកបដោយសេចក្តីព្យាយាមជាហេតុផង ។

ឯចំណេះវិជ្ជាសម្រាប់លោក និងគោគសម្បទនោះ ជាហេតុនាំឲ្យសម្រេចប្រយោជន៍បានច្រើនប្រការណាស់ គួរយ៉ាងដូចជាកូនប្រទេសនីមួយ ៗ ដែលមានសេចក្តីចំរើនដ៏ធំទូលាយ និងល្បីខ្ទរខ្ទាយឡើងបាននោះ ព្រោះគេមានចំណេះវិជ្ជាសម្រាប់លោក និងគោគសម្បទពេញបរិបូណ៌ហូរហៀរជាហេតុ ។

តាមដែលបានបរិយាយមកនេះ គួរឃើញថា ‹‹ហេតុ›› ជាដើមចមរបស់ផលគឺរបស់ដែលកើតមានឡើង; បើហេតុល្អ ផលដែលកើតឡើងក៏ល្អ; បើហេតុមិនល្អ ផលដែលកើតឡើងក៏មិនល្អ; បើហេតុមិនទាន់មាន ផលក៏មិនអាចកើតឡើងបាន ។ ហេតុជាពូជ ផលជាផ្លែ គឺពូជយ៉ាងណា វេលាមានផ្លែក៏យ៉ាងនោះដែរ ។ ដូចមានពុទ្ធភាសិតថា:

យាទិសំ វប្បតេ ពីជំ តាទិសំ លភតេ ផលំ

‹‹បុគ្គលសាបព្រោះពូជយ៉ាងណា ដល់វេលាបានផលគឺផ្លែក៏រមែងបានយ៉ាងនោះវិញ›› ។

ឯហេតុទាំងអស់នោះ អាស្រ័យបញ្ញាចក្ខុទើបមើលឃើញ មិនមែនអាស្រ័យមំសចក្ខុទើបមើលឃើញទេ; ឯក្មេងតូចៗ គ្រាន់តែចុះឲ្យ

ឃើញរូបប៉ុណ្ណោះ កាលឃើញរូបហើយ ទើបចិត្តស្ទុះទៅទទួលយកអំពីក្អែក ដើម្បីកត់សំគាល់ឲ្យដឹងថា រូបនេះមានវិញ្ញាណ - ឥតវិញ្ញាណ, ខ្មៅ - ស - ល្អ - អាក្រក់ជាដើម ហើយសោយអារម្មណ៍ផ្សេងៗ ទៅ ប៉ុន្តែនឹងអាចដឹងដល់ហេតុផលនៃរូបមានវិញ្ញាណ - ឥតវិញ្ញាណ ខ្មៅ - ស - ល្អ - អាក្រក់ជាដើមនោះ ថាមកអំពីហេតុយ៉ាងនេះយ៉ាងនោះពុំបានឡើយ; លុះតែបញ្ញា កើតមានឡើងក្នុងវេលាណា ទើបអាចដេញដោលឲ្យដឹងដល់ហេតុផលក្នុងវេលានេះបាន ។ ហេតុនោះហើយ បានជាអ្នកប្រាជ្ញទាំងឡាយមានព្រះពុទ្ធជាដើម ពោលសរសើរថា បញ្ញាជីវឹ ជីវិតមាហុ សេដ្ឋំ "អ្នកដែលមានជីវិតរស់នៅដោយប្រាជ្ញា អ្នកប្រាជ្ញពោលថាជីវិតរបស់អ្នកនោះ ប្រសើរបំផុត (ក្នុងលោកនេះ) ។

ដូច្នេះ កាលបើបុគ្គលប្រឹងប្រែងនឹងធ្វើកិច្ចការអ្វីមួយ ដោយកម្លាំងចិត្តតែម្យ៉ាងនោះ មិនអាចនឹងកើតបានទេ; លុះតែប្រកបប្រាជ្ញាផង ទើបធ្វើការនោះឲ្យសម្រេចប្រយោជន៍ដ៏ធំទូលាយ អាចឡើងទៅកាន់ថ្នាក់ដ៏ខ្ពស់ឧត្តមបាន ។

ធម្មទេសនា ដែលសំដែងមកនេះ ក៏ល្មមសមគួរនឹងបញ្ចប់ហើយ មុននឹងបញ្ចប់ សូមឲ្យជាតិ - សាសនា និងមហាក្សត្រ នៃខេមរជាតិយើង តាំងនៅក្នុងសេចក្ដីសុខចំរើន សព្វប្រការអស់កាលជាយូរអង្វែងទៅ ដោយអំណាចនៃធម្មទេសនានេះ ។

---

ប្រជុំធម៌ឧបាសក

# ប្រស្នាសួរ-ឆ្លើយ

ព្រះទេពសត្ថា កិម-តូរ បន្ទូមង្គលោ

ក្រុមជំនុំព្រះត្រៃបិដកនៅពុទ្ធសាសនបណ្ឌិត្យ

*រៀបរៀង*

---

## អារម្ភកថា

បុព្វហេតុដែលនាំឲ្យខ្ញុំរៀបរៀង ប្រជុំធម៌ឧបាសក នេះឡើង ដោយសេចក្ដីយល់ឃើញថា ឧបាសកឧបាសិកា ដែលជាអ្នកមានសទ្ធា រក្សាសីលតាមថ្នាក់តាមជាន់របស់ខ្លួន ពុំសូវសម្បូរសៀវភៅជាច្បាប់សម្រាប់សិក្សាគ្រាន់នឹងជៀងផ្ចាត់នូវសីលរបស់ខ្លួន បើទុកជាមានខ្លះ ក៏មិនទាន់ធ្លួនល្មមដល់អ្នកត្រូវការសិក្សាដែរ ព្រោះហេតុនោះបានជាខ្ញុំខំព្យាយាមដកស្រង់នូវពួកធម៌សម្រាប់ឧបាសកឧបាសិកាប្រតិបត្តិ អំពីគម្ពីរផ្សេង ៗ មករៀបរៀង កំណត់ឲ្យឈ្មោះថា ប្រជុំធម៌ឧបាសក ។

ប្រជុំធម៌ឧបាសកនេះ ខ្ញុំយល់ថាមានប្រយោជន៍យ៉ាងសំខាន់របស់ឧបាសកឧបាសិកា ទុកដូចជាបន្ទាត់សម្រាប់ដឹកតម្រង់ នូវកាយវាចាចិត្តរបស់អ្នករក្សាសីល ក៏បាន, ទុកដូចជាឱសថសម្រាប់កំចាត់រោគគឺកិលេសរបស់អ្នករក្សាសីល ក៏បាន, ទុកដូចជាគ្រឿងយ៉ាងវិសេស សម្រាប់ឲ្យទាំងចាស់ក្មេងនៃពួកឧបាសកឧបាសិកា ក៏បាន ប្រសិនបើមានសៀវភៅនេះជាប់នៅខ្លួន ។

ទីបំផុតនេះ សូមឲ្យពុទ្ធបរិស័ទ អ្នកសិក្សាធម៌នេះ បានដល់នូវសេចក្ដីសុខសេចក្ដីចំរើនជាតិយោភាគ. អស់កាលជានិច្ចនិរន្តរ៍កុំបីឃ្លៀងឃ្លាត ។

ថ្ងៃទី ៩ វិច្ឆិកា ២៤៩៥/១៩៥២

គិម តូរ

*

* *

## ១ — ឧបាសកវិធី

សួរ. គ្រហស្ថបែបណា ឈ្មោះថា ឧបាសក ព្រោះហេតុអ្វី?

ឆ្លើយ. គ្រហស្ថអ្នកដល់នូវសរណៈទាំង ៣ (បើបុរស) ឈ្មោះថាឧបាសក (បើស្ត្រី) ឈ្មោះថា ឧបាសិកា, ដូចព្រះពុទ្ធដីកាដែលព្រះសម្ពុទ្ធទ្រង់ត្រាស់ចំពោះមហានាមថា "ម្នាលមហានាម! គ្រហស្ថណា ដែលបានដល់នូវព្រះពុទ្ធ, ព្រះធម៌និងព្រះសង្ឃជាសរណៈ (ជាទីពឹង) គ្រហស្ថនោះ បាននាមថាឧបាសក; ព្រោះហេតុដែលបានចូលទៅអង្គុយជិតព្រះរត្នត្រ័យ ។

ស. ពាក្យថាឧបាសក ប្រែថា ដូចម្ដេច? បានសេចក្ដីយ៉ាងណា?

ឆ. ប្រែថា "អ្នកចូលទៅអង្គុយជិតព្រះពុទ្ធព្រះធម៌ព្រះសង្ឃ"; បានសេចក្ដីយ៉ាងនេះថា: បុគ្គលដែលចូលទៅអង្គុយជិតព្រះពុទ្ធព្រះធម៌និងព្រះសង្ឃនោះ មិនមែនចូលទៅអង្គុយជិតជានិច្ចដោយរូបកាយទេ គឺលោកសង្គ្រោះយកនាមកាយវាប្រមាណ សូម្បីបុគ្គលនោះឋិតនៅ

ករទីឆ្ងាយក៏ដោយ។ចុះ ឲ្យតែមានសន្តានចិត្តប្រព្រឹត្តជាប់ទោរទន់ទៅរក
គុណព្រះរត្នត្រ័យជានិច្ច ឬចិត្តនោះឱនទៅគោរពយកគុណព្រះរត្នត្រ័យ
ជាសរណៈអស់កាលជានិច្ច បុគ្គលនោះឈ្មោះថា ឧបាសក ។

## ២— សរណៈ

ស. ពាក្យថា សរណៈ ប្រែថា ដូចម្តេច?

ឆ. ប្រែថា ការទីពឹង ឬទីរលឹក ។

ស. បើកុំប្រែដូច្នោះ និងប្រែដូចម្តេចបានខ្លះទៀត? ចូរអធិប្បាយ!

ឆ. ប្រែបានច្រើនយ៉ាង គឺប្រែថា "បៀតបៀន, កំចាត់បង់, ទីជ្រកកោន គ្រឿងការពារ គ្រឿងគ្រប់គ្រង, រក្សា" ជាដើម ។

អធិប្បាយថា: ពួកសត្វណា ដែលមានសន្តានចិត្តទោរទន់ទៅរកគុណព្រះរត្នត្រ័យគឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដែលឈ្មោះថា សរណៈ ៗ នោះ អាចបៀតបៀនធ្វើឲ្យវិនាសនូវភ័យ សេចក្តីតក់ស្លុត សេចក្តីទុក្ខ ទុគ្គតិ និងកិលេសរបស់ពួកសត្វនោះបាន ។

ម្យ៉ាងទៀត សរណៈនេះជាឈ្មោះនៃព្រះរត្នត្រ័យ ព្រោះថាព្រះពុទ្ធទ្រង់កំចាត់បង់នូវភ័យរបស់ពួកសត្វ, ព្រះធម៌អាចចម្លងពួកសត្វឲ្យផុតចាកកន្តារៈ (ផ្លូវឆ្ងាយដាច់ស្រយាល ឬផ្លូវលំបាក) គឺភព, ព្រះសង្ឃអាចធ្វើពួកសត្វឲ្យទទួលនូវផលដ៏ធំទូលាយបាន ។

ពាក្យថា សរណៈនេះ ប្រែបានច្រើនយ៉ាងក៏ពិតមែន ប៉ុន្តែសេចក្តីអធិប្បាយរបស់ពាក្យប្រែទាំងនោះ រួមមកបានសេចក្តីតែមួយ, តួយ៉ាងដូចមនុស្សមានរោគហើយចូលទៅរកពេទ្យឲ្យព្យាបាល ពេទ្យនោះឈ្មោះ

ថាជាអ្នកកំចាត់បង់នូវភេតក៏បាន, ឈ្មោះថាជាទីពឹងរបស់អ្នកមានភេតក៏បាន ; ពុំនោះសោត មនុស្សសត្វត្រូវកំដៅថ្ងៃហើយចូលទៅជ្រកក្នុងម្លប់ឈើ ឬក្នុងផ្ទះ ម្លប់ឈើនឹងផ្ទះនោះ ឈ្មោះថាជាទីកំចាត់បង់នូវកំដៅថ្ងៃក៏បាន, ឈ្មោះថាជាទីពឹងរបស់មនុស្សសត្វអ្នកត្រូវកំដៅថ្ងៃក៏បានដូចេ្នះជាដើមយ៉ាងណាមិញ ; ចំណែកខាងព្រះរត្នត្រ័យ ឈ្មោះថាជាគ្រឿងកំចាត់បង់នូវភ័យនឹងសេចក្ដីតក់ស្លុតជាដើមរបស់ពួកសត្វក៏បាន, ឈ្មោះថាជាទីពឹងពំនាក់របស់ពួកសត្វក៏បាន ក៏យ៉ាងនោះដែរ ។

## ៣– សរណគមន៍

ស. ពាក្យដែលធ្លាប់ហៅថា សរណគមន៍ ៗ នោះ ប្រែថា ដូចម្ដេច? ចែកដោយអាការប៉ុន្មានយ៉ាង? អ្វីខ្លះ?

ឆ. ប្រែថា ការដល់នូវសរណៈ ចែកដោយអាការ ៤ យ៉ាងគឺ

១– អត្តសន្និយ្យាតនៈ ២– តប្បរាយនៈ

៣– សិស្សភាវូបគមនៈ ៤– បណិបាតៈ ។

ស. បណ្ដាអាការទាំង ៤ យ៉ាង ដែលបានរាប់មាតិកាមកនេះ ក្នុងអាការនីមួយ ៗ មានសេចក្ដីផ្សេងគ្នាយ៉ាងណាខ្លះ?

ឆ. មានសេចក្ដីផ្សេងគ្នាយ៉ាងនេះគឺ

១– អត្តសន្និយ្យាតនៈ ដល់នូវសរណៈ ដោយការប្រគល់ខ្លួនចំពោះព្រះរត្នត្រ័យ ដូចមានបាលីថា អជ្ជាទិ កត្វា អហំ អត្តានំ ពុទ្ធស្ស (ធម្មស្ស សង្ឃស្ស) និយ្យាទេមិ ខ្ញុំព្រះករុណា សូម

ប្រគល់ខ្លួនចំពោះព្រះពុទ្ធ ( ព្រះធម៌ ព្រះសង្ឃ ) ចាប់ដើមតាំងពីថ្ងៃនេះទៅ ។

២— តប្បរាយនៈ ដល់នូវសរណៈ ដោយការយកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃទាំងនោះឲ្យជាទីប្រព្រឹត្តទៅក្នុងខាងមុខ ដូចមានបាលីថា អជ្ជាទិំ កត្វា អហំ ពុទ្ធបរាយណោ ធម្មបរាយណោ សង្ឃបរាយណោ ឥតិ មំ ធារេថ ខ្ញុំព្រះករុណា មានព្រះពុទ្ធប្រព្រឹត្តទៅក្នុងខាងមុខ មានព្រះធម៌ប្រព្រឹត្តទៅក្នុងខាងមុខ មានព្រះសង្ឃប្រព្រឹត្តទៅក្នុងខាងមុខ សូមព្រះអង្គទ្រង់ចាំទុកនូវខ្ញុំព្រះករុណា ដូច្នេះចុះ ចាប់ដើមតាំងពីថ្ងៃនេះទៅ ។

៣— សិស្សភាវូបគមនៈ ដល់នូវសរណៈ ដោយការចុះចូលធ្វើជាសិស្សនៃព្រះរតនត្រ័យ ដូចមានបាលីថា អជ្ជាទិំ កត្វា អហំ ពុទ្ធស្ស អន្តេវាសិកោ ធម្មស្ស សង្ឃស្សាតិ មំ ធារេថ ខ្ញុំព្រះករុណា សូមជាសិស្សនៃព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ សូមព្រះអង្គទ្រង់ចាំទុកនូវខ្ញុំព្រះករុណា ដូច្នេះចុះ ចាប់ដើមតាំងពីថ្ងៃនេះទៅ ។

៤— បណិបាតៈ ដល់នូវសរណៈ ដោយការធ្វើសេចក្តីគោរពយ៉ាងក្រៃលែង ដូចមានបាលីថា អជ្ជាទិំ កត្វា អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មំ ពុទ្ធាទីនំយេវ តិណ្ណំ វត្ថូនំ ករោមិ ឥតិ មំ ធារេថ ខ្ញុំព្រះករុណា សូមធ្វើនូវការថ្វាយបង្គំដោយ

គោរព នូវការក្រោកឡើងទទួល នូវអញ្ជលិកម្ម និងសាមីចិកម្ម ចំពោះវត្ថុស័ក្តិសិទ្ធិទាំង ៣ មានព្រះពុទ្ធជាដើម សូមព្រះអង្គទ្រង់ចាំទុកនូវខ្ញុំព្រះករុណា ដូច្នេះចុះ តាំងដើមតាំងពីថ្ងៃនេះទៅ ។

ស. អាការទាំង ៤ យ៉ាង ដូចបានពោលមកនេះ បុគ្គលដែលបានដល់នូវសរណៈ លុះតែប្រកបគ្រប់ដោយអាការទាំង ៤ នោះ ទើបបានឈ្មោះថា ជាអ្នកជាប់សរណគមន៍ ឬ?

ឆ មិនមែនដូច្នោះទេ បុគ្គលដល់នូវសរណៈ ដោយអាការណាមួយក៏បានឈ្មោះថាជាអ្នកជាប់សរណគមន៍ដោយពិត ។

ស. កាលជាន់ពុទ្ធសម័យ (សម័យដែលព្រះពុទ្ធកំពុងគង់ព្រះជន្មនៅ) មានបុគ្គលណាខ្លះ បានដល់នូវសរណៈ ដោយអាការបែបណាខ្លះ? ចូរអធិប្បាយ!

ឆ. កាលជាន់ពុទ្ធសម័យ ព្រះមហាកស្សបត្ថេរ កាលលោកតាំងនៅក្នុងនាមជាបព្វជិតមាណព បានដល់នូវព្រះពុទ្ធជាសរណៈ ដោយការចូលទៅសុំធ្វើជាសិស្ស ហៅថា សិស្សភាវូបគមនៈ ។

កាលអាឡវកយក្ស (១) ចេញពីស្រុកមួយទៅកាន់ស្រុកមួយ ចេញពីបុរីមួយទៅកាន់បុរីមួយ ក៏តែងនមស្ការចំពោះព្រះពុទ្ធផង ព្រះធម៌ផង ព្រះសង្ឃផង ឈ្មោះថាដល់នូវសរណៈ ដោយការយកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ប្រតិត្តទៅក្នុងខាងមុខ ហៅថា តប្បរាយនៈ ។

---

១ រឿងនេះ មានសេចក្តីពិស្តារក្នុងអាឡវិកសូត្រ គម្ពីរសំយុត្តនិកាយ ។

កាលព្រហ្មាយុព្រាហ្មណ៍ (១) ក្រោកចាកអាសនៈ ធ្វើសំពត់ឧត្តរាសង្គ (សំពត់បង់ក) ទៀងស្មាម្ខាងក្រាបថ្វាយបង្គំទៀបព្រះបាទានៃព្រះដ៏មានព្រះភាគ ជប់ព្រះបាទាព្រះអង្គដោយមាត់ផង ច្របាច់ដោយដៃផង ហើយបន្លឺឈ្មោះរបស់ខ្លួនថា បពិត្រព្រះគោតមដ៏ចំរើនខ្ញុំព្រះអង្គឈ្មោះព្រហ្មាយុព្រាហ្មណ៍ដូច្នេះជាដើម ឈ្មោះថា ដល់នូវសរណៈដោយការថ្វាយបង្គំដោយគោរព ហៅថា បណិបាតៈ ។

សៈ ការថ្វាយបង្គំដោយគោរពដែលមិនកើតជាសរណគមន៍ តើមានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?

ឆ. មាន ៣ យ៉ាងគឺ ១ — ញាតិបណិបាតៈ បុគ្គលថ្វាយបង្គំដោយគិតថា ព្រះពុទ្ធជាញាតិរបស់អាត្មាអញ ដូច្នេះក៏មិនកើតជាសរណគមន៍; ២ — ភយបណិបាតៈ បុគ្គលថ្វាយបង្គំដោយភ័យខ្លាចគិតថា ព្រះសមណគោតម ព្រះអង្គមានអានុភាពច្រើន ប៉ុនអម្បាលព្រះមហាក្សត្រិយ៍ម្ដេចគង់បូជា កាលបើអាត្មាអញមិនថ្វាយបង្គំ ទ្រង់ទីនៈធ្វើសេចក្ដីវិនាសដល់អាត្មាអញមិនខាន ហើយថ្វាយបង្គំទៅ ក៏មិនកើតជាសរណគមន៍ដែរ; ៣ — អាចរិយបណិបាតៈ បុគ្គលថ្វាយបង្គំដោយគិតថា ព្រះពុទ្ធជាអាចារ្យ កាលព្រះអង្គនៅជាពោធិសត្វបានបង្រៀនសិល្បៈដល់អាត្មាអញ លុះព្រះអង្គបានត្រាស់ជាព្រះពុទ្ធទ្រង់ប្រៀនប្រដៅធម៌អាចឹងក៏អាត្មាអញទៀត ការថ្វាយបង្គំដោយគិតយ៉ាងនេះ ក៏មិនកើតជាសរណគមន៍ដែរ ។

---

១ មានសេចក្ដីស្ដារក្នុងព្រហ្មាយុសូត្រ គម្ពីរមជ្ឈិមនិកាយ ។

ស. ចុះថ្វាយបង្គំដោយគិតដូចម្តេច ទើបកើតជាសរណគមន៍បាន?

ឆ. ថ្វាយបង្គំដោយគិតថា ព្រះពុទ្ធជាទក្ខិណេយ្យបុគ្គលប្រសើរបំផុតក្នុងលោក ដូច្នេះទើបកើតជាសរណគមន៍ ហៅថា ទក្ខិណេយ្យបាណិបាត ។

## ៤— ប្រភេទរបស់សរណគមន៍

ស. ប្រភេទរបស់សរណគមន៍ចែកចេញជាប៉ុន្មានយ៉ាង? អ្វីខ្លះ? ក្នុងសរណគមន៍នីមួយៗ មានសេចក្តីផ្សេងគ្នាយ៉ាងណា?

ឆ. ចែកចេញជា ២ យ៉ាងគឺ លោកុត្តរសរណគមន៍ ១ លោកិយសរណគមន៍ ១; មានសេចក្តីផ្សេងគ្នាយ៉ាងនេះ: សរណគមន៍របស់អរិយបុគ្គលដែលឃើញនូវសច្ចៈទាំង ៤ មាននិព្វានជាអារម្មណ៍ អាចផ្តាច់បង់នូវឧបក្កិលេសក្នុងខណៈនៃមគ្គ រមែងសម្រេចក្នុងព្រះរត្នត្រ័យបានទាំងអស់ នេះឈ្មោះថា លោកុត្តរសរណគមន៍ ។ ឯសរណគមន៍របស់បុថុជ្ជន ដែលមានពុទ្ធគុណជាដើម ជាអារម្មណ៍ គ្រាន់តែសង្កត់បន្ទ្រាមនូវឧបក្កិលេសប៉ុណ្ណោះ តែមិនទាន់កាត់ផ្តាច់ឧបក្កិលេសបាននៅឡើយ; ម្យ៉ាងទៀត ការបាននូវសទ្ធាមានសេចក្តីជឿជាក់ចំពោះព្រះរត្នត្រ័យមួយ, សម្មាទិដ្ឋិ មានសេចក្តីយល់ឃើញត្រូវដែលមានសទ្ធាជាមូលមួយ, ការធ្វើទិដ្ឋិឲ្យត្រឹមត្រូវចំពោះបុញ្ញកិរិយាវត្ថុទាំង ១០ មួយ នេះឈ្មោះថា លោកិយសរណគមន៍ ។ (មានត)

## ទាបកថារឿងព្រះពុទ្ធរូបបុរាណ

ឃុនអត្ថកោវិទ ជា-យឿវ នៅពុទ្ធសាសនបណ្ឌិត្យ

ប្រែពាកទស្សនាវដ្ដី ដំណឹងសាសនា ឆ្នាំទី ១ ច្បាប់ទី ៦ ភាសាថៃ

(តមក)

ព្រោះហេតុដូច្នោះ ក្នុងកាលដែលផ្លាស់មកជាសម័យគុប្ត: គឺតមកពីសម័យគន្ធារ: ក៏មកដល់សម័យអមរាវតី ចីពរព្រះពុទ្ធរូបនៅជាទំរង់ក្រិកគឺចីពរជ្រួញអង្កាញ់ លុះមកដល់សម័យរាជវង្សគុប្ត: គេមិនចូលចិត្តចីពរជ្រួញអង្កាញ់ គេធ្វើព្រះពុទ្ធរូបគ្រងចីពរស្តើង ឲ្យឃើញទ្រង់ទ្រាយរាងកាយជាក់ច្បាស់ ៗ ព្រះពុទ្ធរូបរបស់ក្រិក:នោះ សូម្បីជាស្នាដៃជាងជាតិក្រិកអ្នកសាងក៏ពិតតែគេអនុលោមតាមតម្រាឥណ្ឌាច្រើនយ៉ាងដែរ ដូចពាក្យថា ឧណ្ណា លោមា ភមុកន្តរេ "ធ្វើព្រះឧណ្ណាលោម នៅរវាងព្រះភូមោ" ឧណ្ហីសសីសោ "ព្រះកេសាដូចទ្រង់ព្រះឧណ្ហីស (មកុដ)" គេទើបធ្វើឲ្យមានព្រះមោលីឡើង ៗ

លុះមកដល់សម័យគុប្ត: ជាសម័យដែលប្រទេសឥណ្ឌាមានសេចក្តីចំរើនរុងរឿង ដោយសារមានស្តេចផែនដី ១ ព្រះអង្គក្នុងព្រះវង្សនោះ ទ្រង់ព្រះនាមថា ព្រះបាទចន្ទ្រគុប្ត:ទី ២ ទ្រង់មានអានុភាពជាពន្លឹក ហើយជាស្តេចមួយ ដែលមានក្នុងនិទានរបស់ឥណ្ឌា ហៅថា 'ព្រះបាទវិក្រមាទិត្យ", ក្នុងសម័យស្តេចអង្គនេះ ជាសម័យដែលល្បីល្បាញកេរ្តិ៍ឈ្មោះខាងសិល្បវិទ្យា មានកវីឯក ៩ នាក់ ហៅថា នវរតនកវី ទាំង

សិល្បកម្មក៏កើតឡើងយ៉ាងបរិបូណ៌ នៅតាមគុហារូងភ្នំផ្សេងៗ គេក៏បានសាងព្រះពុទ្ធរូបទុកនៅទីនោះជាច្រើន ដែលមានឈ្មោះល្បីល្បាញជាងគេ គឺគុហាឈ្មោះអជន្តៈ ក្រោយអំពីនោះ ក៏សឹងមានព្រះពុទ្ធរូបដែលមានជាយចីពរតែម្ខាង ទីងមានជាយចីពរទាំងសងខាង ជាព្រះសម័យប្រទានពរ សម័យប្រទានអភ័យ ទីងសម័យបឋមទេសនា ដែលមានទ្រង់ទ្រាយដូចយើងហៅថា ព្រះពុទ្ធរូបសម័យទ្វារវតីនោះឯង ដែលពីដើមយើងជឿថា ព្រះពុទ្ធរូបសម័យនេះហើយ ដែលផ្សាយមកដល់ស្រុកយើងជាដំបូង ។ តាមគម្រាពុទ្ធចេតិយស្យាមរបស់សម្តេចក្រមពញាតម្រង់រាជានុភាពថា ការប្រកាន់ចូលចិត្តដូច្នោះ ក៏ជាការពិតម្យ៉ាងដែរ តែដែលពិតម្យ៉ាងទៀតនោះ យើងបានប្រទះឃើញព្រះពុទ្ធរូបសម័យអមរាវតី ក្នុងអាណាចក្រថៃច្រើនកន្លែង គឺមួយអង្គឃើញនៅស្រុកពង់ទឹក (ផុងទឹក), ១ អង្គទៀត ឃើញនៅខេត្តនគររាជ, ឃើញនៅនគរបឋម (ណៈខនប៉ៈឋុំ) ក៏ច្រើនអង្គ, ដែលថាព្រះពុទ្ធរូបបោះពុម្ព ក្នុងពិពិធភណ្ឌស្ថានថៃជាតិមានដល់ ១៦ អង្គ ខ្ញុំបានទូលសម្តេចក្រមពញាតម្រង់រាជានុភាពថា ព្រះពុទ្ធរូបអមរាវតីនេះមានមកដល់ប្រទេសថៃហើយ គង់មានគេសាងក្នុងប្រទេសថៃស្រេចទៅហើយ ព្រោះមានស្នាដៃពួកស្រុកយើងធ្វើច្រើនអង្គ ដូចព្រះពុទ្ធរូបរបស់ព្រះគុល្យការគោរទេជាដើម ជាបែបអមរាវតីដោយពិត ហើយខ្ញុំបានយកទៅថ្វាយសម្តេចក្រមព្រះពញាតម្រង់រាជានុភាពទត, ទ្រង់ពេញព្រះទ័យ តែមិនទ្រង់ទទួលថាត្រឹមត្រូវទេ គ្រាន់តែត្រាស់ថា បានប្រទះឃើញច្រើនជាការល្អគួរដែរ ៗ ដំបូង

ខ្ញុំបានជឿតាមលោកអ្នកធំជាន់មុនថា សូម្បីជាបែបអមរាវតីក៏ពិតមែន តែជាសម័យទ្វារវតី គេធ្វើតាមបែបអមរាវតី ៗ តមកមានអ្នកពាជការម្នាក់ជាតិបារាំងសែស ជាកូឈ្មួយតាំងហ្វាងកណ្ណារក្សាពិពិធភណ្ឌគី·មេត៍ នៅប្រទេសបារាំងបានចូលមកក្រុងថៃ ខ្ញុំបាននាំទៅមើលបុរាណវត្ថុនៅនគរបឋម, កាលគេឃើញព្រះអមរាវតីហើយ គេសួរខ្ញុំថា ព្រះពុទ្ធរូបនេះគួរបាត់ជាព្រះសម័យណា ខ្ញុំប្រាប់ថាសម័យទ្វារវតី តែគេធ្វើតាមបែបអមរាវតី គេប្រាប់ខ្ញុំថា មិនមែនដូច្នោះទេ ជាព្រះអមរាវតីពិតប្រាកដ ព្រោះដូច្នោះគួរពួកយើងចូលចិត្តជាង ចំណែកខ្ញុំៗចូលចិត្តសិប់ណាស់ទៅហើយ ខ្ញុំបាននាំបារាំងនោះមកមើលព្រះអមរាវតីទាំង ២ អង្គ ក្នុងពិពិធភណ្ឌស្ថានដែលបានមកពីពង់ទឹកនឹងនគរពេជ នឹងព្រះបោះពុម្ព ១៦ អង្គទៀត គេប្រាប់ខ្ញុំថា ជាព្រះសម័យអមរាវតីទាំងអស់ ៗ ខនេះជាហេតុឲ្យយើងជឿបានយ៉ាងប្រាកដថា ព្រះអមរាវតីបានមកដល់ប្រទេសថៃហើយ គេបានកសាងត ៗ គ្នាមកយ៉ាងជាក់ច្បាស់ ព្រោះដូច្នោះខ្ញុំបានតែងតម្រា ប្តូរប្រវត្តិព្រះពុទ្ធរូបជាន់ក្រោយ ៗ មក បានបន្ថែមរឿងព្រះអមរាវតីចុះទៅក្នុងតម្រានោះទៀត, ទាំងនេះក៏ព្រោះត្រួតត្រាផ្ទៀងផ្ទាត់ទៅបានលទ្ធផលយ៉ាងល្អដូចពោលមកហើយ ៗ

តពីសម័យអមរាវតី ក៏មកដល់សម័យគុប្តៈ បានមកដល់ប្រទេសថៃក្នុងគ្រាដែលអាណាចក្រទ្វារវតីរុងរឿង ដែលយើងហៅថាព្រះសម័យទ្វារវតីរហូតដល់សព្វថ្ងៃនេះ ៗ ពាក្យថា "ទ្វារវតី" ជាឈ្មោះអាណាចក្រ មានប្រាកដក្នុងសេចក្តីកត់ហេតុរបស់ចិនថា តាំងនៅក្នុងចន្លោះ

ប្រទេសភូមានឹងប្រទេសខ្មែរ បានទទួលអារ្យធម៌មកពីឥណ្ឌា ៗ ផល នៃការត្រួតត្រាស្រាវជ្រាវ ធ្វើឲ្យយើងបានប្រទះឃើញព្រះពុទ្ធរូប ដែលជាឥទ្ធិពលរបស់ឥណ្ឌាច្រើនកន្លែង, ដែលមាននៅក្នុងស្រុកនគរបឋម ហើយនឹងស្រុកជិតខាងគ្នានោះ ច្រើនតែជាព្រះពុទ្ធរូបសម័យគុប្តៈ ដូចព្រះដែលហៅថាពញ្ញាកុងពញ្ញាពាន ព្រះដ៏រនៅក្នុងវិហារវត្តវៃ" ស្រុកនគរបឋម នឹងព្រះដទៃៗទៀតជាច្រើន, ដែលយកមកតាំងប្រឡងក្នុងទីនេះ ក៏មានព្រះទ្វារវតីជាច្រើនដែរ ៗ ព្រះទ្វារវតីនៅប្រទេសយើង គឺព្រះបែបឥណ្ឌាសម័យពវង្សគុប្តៈនោះឯង តែថាជាព្រះដែលសាងនៅស្រុកអាយ, អង្គខ្លះគេធ្វើល្អ ដូចព្រះពុទ្ធរូបដែលធ្វើនៅឥណ្ឌា, គេនិយាយថា ជាស្នាដៃជាទ់ពួកអាចារ្យធ្វើ ឬជាស្នាដៃជាងឥណ្ឌា ដែលចូលមកនៅក្នុងប្រទេសនេះក៏សឹងបាន ៗ ព្រោះក្នុងវេលានោះគេជឿថាមានពួកឥណ្ឌាចូលមកនៅធ្វើជាគ្រូអាចារ្យច្រើននាក់, តមកពួកអ្នកស្រុកធ្វើខ្លួនឯង ស្នាដៃទើបមិនត្រឹមត្រូវតាមភ្នាត ៗ យើងទើបចែកព្រះសម័យទ្វារវតីចេញជា ២ ផ្នែក គឺដែលមានទម្រង់ដូចព្រះសម័យគុប្តៈពិតនោះ ១ ផ្នែក ដែលចូលចិត្តថាជាស្នាដៃជាទ់ពួកអាចារ្យ ឬជាងឥណ្ឌាធ្វើខ្លួនឯង នឹងស្នាដៃពួកអ្នកស្រុកធ្វើ ១ ផ្នែក ពួកលោកដែលជាអ្នករួបរួមព្រះពុទ្ធរូប ហើយជាអ្នកជំនាញក្នុងរឿងនោះអាចនឹងមើលបានគ្រប់គ្នា ៗ

ឥឡូវនេះនឹងពោលពីការសិក្សា: ការសិក្សានោះយើងត្រូវមើលរបស់ធំៗដែលគេធ្វើជាគោលជាចារិក នៃសម័យដែលពោលមកហើយ

នោះ ដូចជាយើងនឹងមើលរូបពញាកុងពញាពាន ត្រូវចាំឲ្យបានថា គេធ្វើព្រះភក្ត្រដូចម្ដេច សរសៃព្រះកេសដូចម្ដេច ព្រះហស្ដយ៉ាងណា ចីវរយ៉ាងណា ទ្រង់គង់បែបណា ជាព្រះសម័យណា នេះជាវិធីសិក្សា ។ ឯការដែលយើងត្រូវសិក្សានោះដូច្នេះគឺ ត្រូវមើលរបស់ធំៗ ជាតួយ៉ាងមកហើយទើបមកមើលរបស់តូចៗ កាលយើងឃើញរបស់តូច ត្រូវសង្កេតឲ្យដឹងថា ដូចនឹងព្រះណា តាមដែលយើងធ្លាប់សិក្សាមកនោះហើយត្រូវចាំឲ្យបានយ៉ាងជាក់ប្រាកដ រួចតាំងចិត្តសង្កេតទាំងព្រះកេស, ព្រះមោលី, ព្រះឧណ្ណាលោម ព្រះហស្ដ, ព្រះបាទ, ចីវរ, ត្របកឈូក, សង្កេតអង្គធំហើយ ទើបមកសង្កេតអង្គតូច ដែលយើងបានចួបប្រទះគ្រប់កន្លែង; ដែលសិក្សារបៀបនេះហៅថាជាថ្នាក់ប្រតិបត្តិ ។

តពីសម័យទ្វារវតី ក៏មកដល់សម័យស្រីវិជ័យជាសម័យទី ២ ជាស្នាដៃរបស់ជាងនៃអាណាចក្រស្រីវិជ័យ ។ អាណាចក្រស្រីវិជ័យ តាំងរាជធានីនៅក្នុងកោះសុម៉ាត្រា ខាងទិសបស្ចិមនៃស្រុកប៉ាឡេមប៉ាំង ។ ក្នុងសម័យនេះ បានផ្សាយវប្បធម៌ឡើងមកដល់កោះមឡាយូរបស់ថៃ គឺស្រុកតៈគួប៉ា ស្រុកនគរស្រីធម្មរាជ ស្រុកដៃយា (ឆៃយ៉ា) នឹងស្រុករៀងស្រះ ។ ក្នុងស្រុកទាំងនេះ គេបានប្រទះឃើញបុរាណវត្ថុប៉ែកខាងព្រះពុទ្ធសាសនា ដូចយ៉ាងដែលប្រទះឃើញនៅកោះសុម៉ាត្រា នឹងកោះជ្វាជាច្រើន ។ ខនេះជាគោលចារិកគ្រប់គ្រាន់ សសេចក្ដីឲ្យឃើញថាព្រះពុទ្ធសាសនាប៉ែកខាងមហាយានបានផ្សាយមកខាងប្រទេសនេះ ក្នុងសម័យស្រីវិជ័យ ។ ព្រះពុទ្ធសាសនាមហាយាននេះ ជារឿងដែលយើង

ត្រូវតែជឿដោយខានមិនបាន ព្រោះហេតុថាមានព្រះពុទ្ធរូប ២ សម័យ គឺសម័យស្រីវិជ័យ និងសម័យលពបុរី ព្រោះដូច្នោះត្រូវតែពោលដល់ប្រវត្តិព្រះមហាយានបន្តិចបន្តួចផង គឺថាព្រះពុទ្ធរូបក្នុងពុទ្ធសាសនាប៉ែកខាងមហាយាន កើតឡើងដោយការប្រណាំងគ្នា រវាងព្រះពុទ្ធសាសនានិងសាសនាព្រាហ្មណ៍ ។ សាសនាព្រាហ្មណ៍ និងព្រះពុទ្ធសាសនានេះមានគតិស្រដៀងគ្នា គឺទាំងពីរសាសនាប្រដៅឲ្យជឿកម្មដូចគ្នា តែអធិប្បាយប្រដៅផលរបស់កម្មផ្សេងគ្នា គឺព្រះពុទ្ធសាសនាប្រដៅឲ្យពឹងខ្លួនឯងថា បើយើងធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ និងបានល្អបានអាក្រក់ក៏ព្រោះខ្លួនឯង អ្នកដទៃគ្រាន់តែទំនុកបម្រុងប៉ុណ្ណោះ បើយើងធ្វើមិនល្អ អ្នកដទៃទំនុកបម្រុងក៏មិនបាន ពាក្យទាំងនេះចូលក្នុងបទថា អត្តា ហិ អត្តនោ នាថោ "ខ្លួនពឹងខ្លួន" គឺព្រះពុទ្ធសាសនាប្រដៅឲ្យជឿកម្មផល ចំណែកសាសនាព្រាហ្មណ៍ប្រដៅថា ការដែលនឹងបានល្អបានអាក្រក់ ឬបានសេចក្តីសុខទុក្ខនោះ ស្រេចនឹងព្រះជាម្ចាស់ បើយើងបួងសួងបន់ស្រន់ឲ្យជាទីពេញចិត្ត ហើយព្រះអង្គក៏ជួយបណ្តាលឲ្យយើងបានល្អ ឬបានសេចក្តីសុខ បើអ្នកណាធ្វើមិនឲ្យជាទីពេញចិត្តរបស់ព្រះជាម្ចាស់ ៗ ក៏ធ្វើឲ្យបានសេចក្តីទុក្ខ ; ព្រះពុទ្ធជាម្ចាស់ កាលស្តេចចូលនិព្វានទៅហើយនោះ ក៏គង់នៅតែព្រះធម៌ យើងមានតែព្រះធម៌ជាទីពឹង ព្រះធម៌មិនមានរូបកាយខ្លួនប្រាណ មនុស្សល្ងង់អាប់ឥតបញ្ញា សំឡឹងមើលមិនឃើញ និងមើលឃើញបានតែអ្នកដែលមានបញ្ញាប៉ុណ្ណោះ ព្រោះហេតុដែលមានអ្នកល្ងង់ច្រើនជាងអ្នកប្រាជ្ញ ទើបបានអ្នកប្រដៅសាសនា

ព្រាហ្មណ៍ជាន់ក្រោយ គេដឹកនាំមនុស្សឲ្យចូលសាសនាគេបានយ៉ាងច្រើនតែលែង សាស្ត្រាចារ្យប៉ែកខាងព្រះពុទ្ធសាសនា ឃើញថាទីងទាញ់ប្រៀបសាសនាព្រាហ្មណ៍ ទើបគិតចាត់វិធានការប៉ែកខាងព្រះពុទ្ធ-សាសនាឲ្យពិស្តារឡើង ដូចតែខែគោលដែលប្រកាន់ថា យេ ប អតីតា សម្ពុទ្ធា យេ ប ពុទ្ធា អនាគតា ប្រែថា “ព្រះពុទ្ធអង្គមានមកហើយក្នុងកាលអតីត ក្នុងបច្ចុប្បន្នក៏មាន ហើយនឹងមានក្នុងអនាគតទៀត” ដូចេះ ពួកមហាយានយកបទនេះទៅតែងអធិប្បាយជាថ្មីទៀតថា ព្រះពុទ្ធជាម្ចាស់មាននៅទូទៅក្នុងទីទាំងពួង ហើយបែងភូមិព្រះពុទ្ធជាម្ចាស់ចេញជា ៣ ជាន់ គឺ

១ — ព្រះសយម្ភូពុទ្ធ ព្រះពុទ្ធកើតព្រមនឹងផែនដី ហៅថា ព្រះអាទិពុទ្ធ,

២ — ព្រះធ្យានីពុទ្ធ ព្រះពុទ្ធកើតដោយអំណាចឈានសមាបត្តិរបស់ព្រះអាទិពុទ្ធនៅឋានសួគ៌មាន ៥ អង្គ គឺ ព្រះវៃរោចនៈ ១ ព្រះអក្សោភយៈ ១ ព្រះរត្នសម្ភវៈ ១ ព្រះអមិតាភ ១ ព្រះអមោឃសិទ្ធ ១,

៣ — ព្រះមានុស្សីពុទ្ធ គឺព្រះពុទ្ធអង្គដែលទ្រង់ចុះមកត្រាស់ក្នុងមនុស្សលោក (ព្រះពុទ្ធរបស់មនុស្ស) ។

ព្រះពុទ្ធ ២ ពួកខាងដើមមិនដែលចុះមកពីឋានសួគ៌ទេ, ដែលធ្លាប់ចុះមកតែពួកទី ៣ គឺព្រះមានុស្សីពុទ្ធប៉ុណ្ណោះ ។

ក្រៅពីព្រះពុទ្ធទាំង ៣ ភូមិនេះ នៅមានព្រះពោធិសត្វជាច្រើនអង្គ

ទៀតជាឧបបាតិកៈរបស់ព្រះធ្យានីពុទ្ធ តែដែលសំខាន់នោះមាន ៥ អង្គ ហៅថាធ្យានីពោធិសត្វ គឺ

១— ព្រះសមន្តភទ្រពោធិសត្វ អ្នករក្សាសាសនារបស់ព្រះកកុសន្ធៈ;

២— ព្រះវជ្របាណីពោធិសត្វ អ្នករក្សាសាសនារបស់ព្រះកោនាគមនៈ;

៣— រត្នបាណីពោធិសត្វ អ្នករក្សាសាសនាព្រះកស្សបៈ;

៤— ព្រះអវលោកិតេស្វរៈ អ្នករក្សាសាសនាព្រះស្រីសាក្យមុនីគោតម;

៥— ព្រះវិស្វបាណីពោធិសត្វ អ្នករក្សាសាសនារបស់ព្រះអរិយមេត្តេយ្យនាអនាគត ។

តាមដែលពិតនោះព្រះពុទ្ធរូបរបស់មហាយានមិនមែនដទៃឡើយ គឺ

អង្គទី ១ ព្រះវៃរោចនៈគឺព្រះសម័យបឋមទេសនានេះឯង, ព្រះមានុស្សពុទ្ធរបស់ព្រះវៃរោចនៈ គឺព្រះកកុសន្ធៈ;

អង្គទី ២ ព្រះអក្សោភយៈ គឺព្រះសម័យមារវិជ័យ, ព្រះមានុស្សពុទ្ធៈរបស់ព្រះអក្សោភយៈ គឺព្រះកោនាគមនៈ;

អង្គទី ៣ ព្រះរត្នសម្ភវៈ គឺព្រះសម័យប្រទានពរ, ព្រះមានុស្សពុទ្ធៈរបស់ព្រះរត្នសម្ភវៈ គឺព្រះកស្សបៈ;

អង្គទី ៤ ព្រះអមិតាភៈ គឺព្រះសម័យសមាធិ, ព្រះមានុស្សពុទ្ធៈ

របស់ព្រះអមិតាភៈ គឺព្រះគោតម ;

អង្គទី ៥ ព្រះអមោឃសិទ្ធ គឺព្រះសម័យប្រទានអភ័យ, ព្រះមានុស្សីពុទ្ធៈរបស់ព្រះអមោឃសិទ្ធ គឺព្រះអរិយមេត្តេយ្យ ដែលនឹងមកត្រាស់នាអនាគត ។

តាមដែលពិតនោះ គេយកព្រះពុទ្ធរូបសម័យផ្សេង ១ ដែលពោលមកហើយនោះទៅសម្គាល់ឡើង ដើម្បីប្រណាំងនឹងសាសនាព្រាហ្មណ៍ ហើយដើម្បីពន្យល់ជនានិករថា ព្រះពុទ្ធដែលបរិនិព្វានទៅហើយនោះ ដូចព្រះទីបង្ករ ព្រះវិបស្សី ព្រះសិខី ព្រះវេស្សភូ ជាដើម រហូតដល់ព្រះគោតម សុទ្ធតែជាព្រះមានុស្សីពុទ្ធទាំងអស់ ដែលមាននៅនាឋានសួគ៌សព្វថ្ងៃនេះ ក៏អាចយកជាទីពឹងបានដែរ ហើយបើនៅផែនដីយើងនេះកើតកលិយុគកលិយាម មានកើតចម្បាំងកំរងដល់ជាដើម ព្រះអាទិពុទ្ធក៏ឲ្យព្រះពោធិសត្វចុះមកជួយ ព្រោះព្រះពោធិសត្វជាតួការកៈរបស់ព្រះអាទិពុទ្ធ នឹងព្រះធ្យានីពុទ្ធ ជាអ្នកធ្វើការទាំងអស់ ក្នុងមនុស្សលោក គឺជាអ្នកសាងលោក ព្រោះពុទ្ធសាសនាខាងមហាយាននេះ មានការសាងលោក ដូចសាសនាព្រាហ្មណ៍ដែរ ហើយអ្នកដែលសាងលោកនោះ គឺព្រះពោធិសត្វ; លោកសព្វថ្ងៃនេះ គេប្រកាន់ថាជាលោកទី ៤ គឺថាក្នុងកប្បនេះ មានព្រះពុទ្ធ ៥ ព្រះអង្គ ដែលត្រាស់ទៅហើយ ៤ អង្គក្នុងកាលឥឡូវនេះ, នៅក្នុងសម័យព្រះគោតម គឺអង្គទី៤, លោកទី ៤ នេះព្រះពោធិសត្វព្រះនាមអវលោកិតេស្វរៈជាអ្នកសាង សម្រាប់ឲ្យព្រះអមិតាភៈ គឺព្រះមានុស្សីពុទ្ធគោតមជាអ្នកចុះមកត្រាស់ក្នុងលោក ។ (មានត)

# ផ្នែកអក្សរសាស្ត្រ

## បញ្ញាបរិយាយ

ព្រះឧបាលិវង្ស ស្វៃ-ហាយ ក្រុមជំនុំព្រះត្រៃបិដក
រៀបរៀង

យើងជាជនជាតិខ្មែរ បានទទួលយកព្រះពុទ្ធសាសនាមកសិក្សារៀនសូត្រប្រតិបត្តិអស់កាលយូរវង់ ២០ សតវត្សមកហើយ ។ ព្រះពុទ្ធ-សាសនាគេចារិកក្នុងសាស្ត្រា (គម្ពីរ) នោះសុទ្ធតែជាភាសាមគធៈ ដែលហៅថា ភាសាបាលី ។ ព្រឹត្តិការណ៍របស់ភាសាខ្មែរយើង ដែលជាប់ទាក់ទងដោយភាសាបាលី និង ភាសាសំស្ក្រឹតច្រើនពេកណាស់ សឲ្យឃើញច្បាស់ថា វប្បធម៌ផ្នែកខាងអក្សរសាស្ត្ររបស់ខ្មែរយើងប្រាកដជាចេញមកអំពីភាសាបាលីនិងសំស្ក្រឹត ដោយមានភាសាបាលីនិងសំស្ក្រឹតជាប្រភព គឺជាដែនកើតនៃភាសាខ្មែរ ។

ព្រោះហេតុនោះ បានជាភាសាខ្មែរយើង លាយឡំដោយបាលី និងសំស្ក្រឹតជាចំនួនច្រើន ។ ពាក្យខ្មែរដែលប្រើនិយាយសព្វថ្ងៃនេះចំនួន ១០០ ម៉ាត់ មានពាក្យបាលីនិងសំស្ក្រឹតលាយចូលប្រហែល ៤០ ម៉ាត់ ។ អ្នកដែលមិនបានរៀនវេយ្យាករណ៍បាលីនិងសំស្ក្រឹតក្តី អ្នកដែលបានរៀនក្តី កាលបើត្រូវការនិយាយ ឬសរសេរពាក្យពេចន៍ណាមួយក៏សុទ្ធតែជាប់ទាក់ទងដោយភាសាបាលី ឬសំស្ក្រឹតប្រហែល ៗ គ្នា សូម្បីតែសាមីខ្លួនអ្នកនិយាយ ឬអ្នកសរសេរ ក៏ឥតដឹងថាជាភាសាបាលី ឬសំស្ក្រឹតសោះ ដោយហេតុតែធ្លាប់ប្រើមកអស់កាលយូរ ជៀមជាំស៊ប់ស៊ាំ

ណាស់ហើយ ដូចពាក្យថា "កាយ, ចិត្ត, រូប, វេទនា, សញ្ញា, សង្ខារ, វិញ្ញាណ, សុខ, ទុក្ខ, រោគ, ភ័យ, ប្រាជ្ញា, បុណ្យ, គេហ៍រឈ្មោះ ប៉ុណ្ណោះជាដើម សុទ្ធតែជាបាលីនិងសំស្ក្រឹតពិតមែន ប៉ុន្តែអាចស្តាប់យកសេចក្តីបានទាំងអស់ឥតសង្ស័យឡើយ ។

ដំណើរដែលនាំឲ្យកើតសេចក្តីចេះដឹង យល់កិច្ចការខ្លួនទៅទាំងផ្លូវលោកទាំងផ្លូវធម៌ ហៅថា "បញ្ញាបរិយាយ" ឬហេតុដែលនាំឲ្យដុះដាលរីកគំនិត លូតលាស់ឡើងនៃការចេះដឹង ក៏ហៅថា "បញ្ញាបរិយាយ" ។ ការស្តាប់ដោយត្រចៀក, ការរៀនទន្ទេញដោយមាត់, ការមើលដោយភ្នែក ការដឹងហើយដញ្ជូនគិតពិចារណាឿយ ៗ ទាំងនេះសុទ្ធតែជាហេតុនៃការចេះដឹងខ្លួនទៅ ។ អក្សរសាស្ត្រ ឬ គម្ពីរដីកាដែលសម្រាប់រៀន សម្រាប់មើល ក៏ហៅថាជាគ្រឿងប្រដាប់សម្រាប់នាំឲ្យចេះដឹង នាំឲ្យយល់កិច្ចការគ្រប់យ៉ាង គឺថា ការចេះដឹងក្រោកប្រាជ្ញប្រើនតិចទាំងអស់ មានអក្សរសាស្ត្រជាប្រែកត ។ មួយទៀតដំណើរទំនងឬហេតុការណ៍ដែលគេផ្សេងៗ ដើម្បីឲ្យកើតសេចក្តីចេះដឹង ឲ្យមានការយល់ដុះធ្លាយ ហៅថា "បញ្ញាបរិយាយ" ។

ការដឹងច្បាស់ នូវហេតុការណ៍របស់លោក ឬ របស់សាសនាហៅថា "បញ្ញា" ។ ពាក្យថា "បញ្ញា" នេះជាភាសាបាលី ប៉ុន្តែយើងជាជនជាតិខ្មែរ ស្តាប់បានយល់សេចក្តីស្ទើរតែគ្រប់គ្នា ។ ពាក្យថា "ប្រាជ្ញា" ជាភាសាសំស្ក្រឹត នេះក៏យើងយកមកប្រើប្រាស់ញឹកញយ ដោយហេតុតែយើងស្តាប់បានដូចពាក្យថា បញ្ញា ដែរ ។

ហេតុដែលនាំឲ្យកើតបញ្ញាមាន ៦ យ៉ាង:

១ — អក្សរសាស្ត្រ ឬ គម្ពីរដីកា;

២ — ការរៀន ការស្តាប់;

៣ — ការត្រិះរិះពិចារណា;

៤ — ការបំពេញកិច្ចការ;

៥ — ការមើលច្បាប់ច្រើន;

៦ — ការសាកសួរចំពោះលោកអ្នកចេះ ។

អធិប្បាយពង្រីកសេចក្តីចំពោះអត្ថបទមួយៗ

១ — អក្សរសាស្ត្រ ឬ គម្ពីរដីកា សំដៅយកក្បួនច្បាប់ គម្ពីរដីកា ដែលសំដែងអំពីអក្សររបស់ជាតិដែលនិយាយអំពីស្រៈ ព្យញ្ជនៈ ឬហៅថា វេយ្យាករណ៍របស់អក្សរដែលសម្រាប់ប្រើ សរសេរដាក់ពាក្យពេចន៍មានរបៀបតាមអក្ខរប្បភេទ ត្រូវតាមវិធីអក្ខរាវិរុទ្ធ ។ អក្សរសាស្ត្រដែលមានរបៀបរៀបរយល្អ, ដែលចំរើនរុងរឿងផ្សាយដល់ជនបរទេសទៅបានក៏ព្រោះអាស្រ័យមនុស្សជាម្ចាស់ប្រទេស ជាអ្នកយកចិត្តទុកដាក់រៀបចំ, គោរពលើកតម្កើង, ស្រឡាញ់ក្នុងការសិក្សាអក្សរភាសារបស់ខ្លួន ។ អ្នកណាដែលលង់ខ្លៅក្នុងអក្សរជាតិរបស់ខ្លួន ដោយសេចក្តីធ្វេសប្រហែសក្តី ដោយសេចក្តីមើលងាយថាអក្សរជាតិរបស់ខ្លួនថោកទាបក្តី អ្នកនោះឈ្មោះថាជាអ្នកមិនគោរពកោតក្រែងចំពោះអក្សរសាស្ត្ររបស់ខ្លួន ឬឈ្មោះថាជាអ្នកប្រមាថមើលងាយអក្សរសាស្ត្ររបស់ខ្លួនដូច្នេះ

ក៏បាន ។ អ្នកដែលសរសេរអក្សររបស់ជាតិដោយខ្ជីខ្ជា មិនគិតអំពីអក្ខរាវិរុទ្ធ គឺថាសរសេរគ្រីសគ្រាំសឲ្យតែរួចពីដៃ មិនគិតពីខុសត្រូវ, អ្នកនេះយើងអាចសំគាល់បានថា ទុកដូចជាអ្នកប្រមាថមើលងាយ ដល់អក្សរជាតិរបស់ខ្លួន ។ កាលបើគេហ៊ានប្រមាថមើលងាយអក្សរជាតិយ៉ាងនេះហើយ សូម្បីមនុស្សជាតិរបស់ខ្លួនក៏គេអាចប្រមាថមើលងាយដែរ គឺថា អ្នកណាមើលងាយអក្សរសាស្ត្ររបស់ជាតិ អ្នកនោះទុកដូចជាមើលងាយដល់ជាតិទាំងមូលរបស់ខ្លួនដូច្នេះក៏បាន ។

អក្សរសាស្ត្ររបស់ជាតិ គួរយើងយកចិត្តទុកដាក់គោរពលើកតម្កើងជាងអក្សរសាស្ត្រជាតិដទៃ គួរស្រឡាញ់ពេញចិត្តក្នុងការសរសេរក្ដី ក្នុងការមើលអានក្ដីឲ្យបានត្រឹមត្រូវជាងអក្សរជាតិដទៃ ។ បើមិនយល់ មិនចេះក្នុងពាក្យណាមួយ ត្រូវពិនិត្យរកមើលវចនានុក្រម ឬបទានុក្រម, បើនៅតែមិនទាន់យល់ ត្រូវសាកសួរដេញដោលរៀនចំពោះលោកអ្នកចេះដឹងតទៅទៀត ឲ្យទាល់តែយល់ចេះចាំជាក់លាក់ឡើង ទើបឈ្មោះថាជាអ្នកស្រឡាញ់អក្សរសាស្ត្ររបស់ខ្លួន ទាំងឈ្មោះថាជាអ្នកស្រឡាញ់ជាតិរបស់ខ្លួនដែរ ។ កាលបើអ្នកមិនស្រឡាញ់អក្សរសាស្ត្ររបស់ខ្លួនហើយ ក៏គួរឲ្យគេទាយបានថាជាអ្នកមិនស្រឡាញ់ជាតិផងដែរ ។

អក្សរសាស្ត្រនេះរាប់ថាជាមូលដ្ឋានមួយដ៏ប្រសើរដែលជាហេតុនាំឲ្យកើតបញ្ញាស្មារតីបរិបូណ៌ បើកុំតែមានអក្សរសាស្ត្រ មនុស្សយើងមិនខុសពីសត្វប៉ុន្មានទេ ។ ករណីនេះឃើញថាបញ្ញា មានអក្សរសាស្ត្រជាប្រភព ដោយពិត ។

២– ការរៀន ការស្ដាប់, ការនេះបានដល់ការសិក្សាដោយពិនិត្យមើលច្បាប់ទម្លាប់ផ្លូវលោកក្ដីផ្លូវធម៌ក្ដី ឧស្សាហ៍មើលឲ្យញឹកញយ មិនខ្ជិលច្រអូសក្នុងការមើលសៀវភៅ ៗ ការសិក្សាក្នុងផ្លូវលោក ឬក្នុងផ្លូវធម៌នេះ រាប់ថាជាផែនការមួយសម្រាប់ពត់ទិសស្រ័យសន្ដានរបស់ខ្លួនឲ្យបានបទល្អ ដើម្បីអប់រំទ្រឹយឲ្យល្អតទៅ ៗ ការរៀនឬការស្ដាប់នេះជាករណីយកិច្ចដែលត្រូវបំពេញតាមវ័យខានមិនបាន តាមចំណាស់របស់ខ្លួន ដែលអាចបំពេញបាន ៗ ការសិក្សានេះចាត់ជាអង្គការប្រចាំជីវិតរបស់មនុស្ស រាប់ថាជាជំហានទី ១ របស់ប្រទេសជាតិ ដោយហេតុថាប្រទេសជាតិនីមួយ ៗ ដែលអាចចំរើនរុងរឿងទៅបាននោះ ព្រោះអាស្រ័យការសិក្សាជាមូលហេតុ ៗ ការសិក្សាក្នុងជាន់ដំបូង ត្រូវសិក្សាអក្សរសាស្ត្រ រួចទើបឡើងទៅរកថ្នាក់វិទ្យាសាស្ត្រ ឬវិជ្ជាថ្នាក់ខ្ពស់ ៗ តទៅទៀត ដែលប្រទេសជាតិត្រូវការតាមកាលៈទេសៈ ៗ ប្រទេសជាតិមានការសិក្សានេះជាពន្លឺរស្មី ៗ ការសិក្សាជាផ្លូវធំទូលាយ នាំឲ្យមនុស្សមានប្រាជ្ញាស្មារតីបរិបូណ៌ ឲ្យមានសមត្ថភាពគ្រប់គ្រាន់ ៗ

ការស្ដាប់នោះទោះបីស្ដាប់ធម៌ទេសនាក្ដី ស្ដាប់សេចក្ដីថ្លែងការណ៍ ឬសន្និសីទក្ដី សុទ្ធតែមានប្រយោជន៍ ដើម្បីបំពេញសតិបញ្ញា ៗ ការស្ដាប់នេះកាលបើស្ដាប់ដោយគោរព ផ្ទៀងផ្ទាត់ដោយម៉ត់ចត់ ព្រមទាំងឧស្សាហ៍ស្ដាប់ដោយញឹកញយ សុទ្ធតែជាហេតុនាំឲ្យកើតប្រាជ្ញា ព្រោះលោកអ្នកសំដែង រមែងមានសេចក្ដីយល់ហេតុការណ៍ជ្រៅជ្រះដោយកន្លែង ៗ ជាងអ្នកស្ដាប់ក៏មាន ថ្លែកសេចក្ដីពីអ្នកស្ដាប់ដែលធ្លាប់ចេះដឹង

ក៏មាន ។ ការឧស្សាហ៍ស្ដាប់នេះទុកថាជាហេតុមួយនាំឲ្យមានប្រាជ្ញា ដោយបានចម្លើយសេចក្ដីយល់ ឬជាកិច្ចប្រយោជន៍អំពីការស្ដាប់ ។

៣– ការត្រិះរិះពិចារណារកហេតុផល ការនេះទុកថាជារបស់ចាំបាច់ខានពុំបាន ព្រោះថា រឿងក៏ណាមួយ ឬហេតុការណ៍អ្វីក៏ដោយ ដែលប៉ះប្រទះមកលើយើង ត្រូវតែចាប់យកហេតុការណ៍នោះ ៗ មក ត្រិះរិះពិចារណាមើលសិនជាដំបូង ដើម្បីស្វាបសួរឲ្យឃើញសមហេតុសមផល ទើបជឿយកជាការបាន មិនត្រូវចេះតែជឿដោយឥតត្រិះរិះពិចារណានោះឡើយ ។ ការត្រិះរិះពិចារណានេះ ជាផលដែលកើតមកអំពីការរៀនច្រើន ស្ដាប់ច្រើន ពិតមែន ប៉ុន្តែលោកកប់ថា ការត្រិះរិះនេះជាសម្ភារនៃបញ្ញា គឺថាជាទីកើតព្រួតលាស់ឡើងនៃបញ្ញា ។

៤– ការបំពើនញឹកញយ: ពាក្យនេះចេញពីបាលីថា "ភាវនា" ដែលធ្លាប់ប្រែថា "ការចំរើន" បានសេចក្ដីថា ការរៀន, ទន្ទេញ, មើលច្បាប់, ស្វាធ្យាយន៍, ស្ដាប់រឿយៗ មិនបោះបង់ មិនទម្លាក់ចោលនូវធុរៈដែលល្អមានប្រយោជន៍ ។ ករណីយកិច្ចណាមួយ ទោះបីលំបាកឬចង្អៀតយ៉ាងណាក៏ដោយ ពុំមែនលើសវិស័យរបស់មនុស្សឡើយ ។ កាលបើគេចាប់ធ្វើដោយព្យាយាមមុឺងម៉ាត់តស៊ូមិនឈប់ មិនលះបង់យូរៗទៅប្រាកដជាចឹកស្កាត់យល់ច្បាស់លាស់ពុំខាន ព្រោះហេតុនោះការចំរើនញឹកញយ គឺការធ្វើ ឬការរៀនជាដើមឲ្យច្រើនឡើងនេះឈ្មោះថាជាមគ្គុទ្ទេសមួយដ៏ប្រសើរ សម្រាប់ឲ្យកើតប្រាជ្ញាស្មារតី ។

៥– ការមើលច្បាប់ច្រើន: ពាក្យថា "ច្បាប់" នេះ ពុំបានសំដៅចំពោះច្បាប់ក្រមព្រហ្មទណ្ឌ ឬច្បាប់រដ្ឋប្បវេណីប៉ុណ្ណោះទេ ទោះបីគម្ពីរដីកា, សៀវភៅធម៌អាថ៌, សារពត៌មាន ឬទស្សនាវដ្ដីណាមួយ ក៏ហៅថា "ច្បាប់បានទាំងអស់" ។ ការមើលច្បាប់ច្រើនទុកជាមេរៀនមួយដែលអាចជួយយោងស្មារតីបញ្ញាឲ្យមានបរិបូណ៌ឡើង ។ ការមើលធម៌អាថ៌ ឬមើលសៀវភៅផ្សេងៗក្ដី, មើលសារពត៌មានណាមួយក្ដី ក្នុងប្រទេសយើងសម័យបច្ចុប្បន្ននេះពុំទាន់សម្បូរ ព្រោះប្រជាជនមិនទាន់ស្រឡាញ់ពេញចិត្តក្នុងការនេះនៅឡើយ ។

បណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ ជាមន្ទីរផ្ទុកសៀវភៅច្បាប់ទម្លាប់អក្សរជាតិក៏មាន ជាអក្សរបរទេសក៏មាន ទុកសម្រាប់ឲ្យជនសាធារណ: មកមើល ទាំងបណ្ណាល័យជាតិខាងលិចវត្តភ្នំក្រុងភ្នំពេញ ក៏មានសៀវភៅសម្រាប់ឲ្យមើលដូចគ្នាដែរ ប៉ុន្តែមិនសូវមានអ្នកទៅមើលច្រើនគុះគរសោះ ។ ក្នុងថ្ងៃមួយៗ មានម្នាក់ ឬពីរបីនាក់ទៅមើល ជួនកាលស្ងាត់ឈឹងមិនមានមនុស្សទៅមើលសោះក៏មាន មិនគុះគរដូចពេងល្ខោនពេងកុនទេ ឃើញថាចាញ់ពេងល្ខោនកុនឆ្ងាយណាស់, នៅក្នុងកប៉ាល់ ក្នុងរថភ្លើង ឬក្នុងយន្តហោះរបស់ប្រទេសដែលមានវឌ្ឍនធម៌ មានឧត្តមគតិ គេឃើញអ្នកជិះកាន់សៀវភៅ ឬសារពត៌មានមើលក្នុងយាននោះស្ទើរពល់ដៃ មិនសូវមានអ្នកណាមួយទំនេរ ឥតមើលសៀវភៅទេ ។

នៅក្នុងកប៉ាល់ ក្នុងរថភ្លើងរបស់ប្រទេសយើង មានមនុស្សជិះទៅមកច្រើនគុះគរដូចគេដែរ ប៉ុន្តែពុំសូវមានអ្នកកាន់សៀវភៅមើលទេ ។

ការមើលច្បាប់ទម្លាប់ច្រើន ជាគុណមួយធំទូលាយណាស់ នាំឲ្យចេះដឹងរឿងរ៉ាវ ជាព្រឹត្តិការណ៍ក្នុងសាកលលោក ដែលជាហេតុធ្វើខ្លួនយើងឲ្យមានខ្លឹមសារ ញុំាងខ្លួនយើងឲ្យឈ្លាសវៃទាំងផ្លូវលោកផ្លូវធម៌ មិនឲ្យខ្លួនយើងធ្លាក់ទៅជាមនុស្សឆ្វេង ឬមនុស្សល្ងើយ ។ ការមើលច្បាប់ទម្លាប់ច្រើន នាំឲ្យចំណេញការចេះដឹងយល់កិច្ចការគ្រប់ចំពូក មិនខាតក្រាក់កាសដូចមើលល្ខោនមើលកុនឡើយ ។

៦ – ការសាកសួរបំពោះលោកអ្នកចេះ, ការសាកសួរពប់ថាជាការចាំបាច់មួយ ហើយទុកជាមេរៀន ដែលនាំឲ្យកើតប្រាជ្ញាភ្លឺថ្លាចេះចាំយល់ការពក់ព្រៅច្រើន ។ ក្នុងផ្លូវអក្សរសាស្ត្រក្តី ផ្លូវសាសនាក្តី កាលបើអ្នកណានៅពុំទាន់ចេះពុំទាន់យល់ អ្នកនោះទោះបីមានឋានៈខ្ពង់ខ្ពស់ដោយយសស័ក្តិប៉ុណ្ណាក៏ដោយ ត្រូវតែសាកសួរដេញដោលចំពោះលោកអ្នកចេះជាងខ្លួនដោយបំណងឲ្យចេះដឹង មិនត្រូវប្រកាន់ឫកពា ឬអៀនខ្មាសទេ ។

វេលានេះប្រទេសកម្ពុជាយើងបានឯករាជ្យពេញបរិបូណ៌ហើយ គួរយើងខ្មែរដឹងខ្លួនថាខ្លួនយើងរួចពីអាយ័តគេ មានឋានៈស្មើមុខនឹងជនដែនប្រទេសឯករាជ្យក្នុងសកលលោកហើយ ដូច្នេះគួរយើងប្រឹងប្រែកបព្យាយាមបណ្តុះ ហេតុនាំឲ្យកើតមានបញ្ញាទាំង ៦ ប្រការ នេះ ក្នុងខ្លួនឡើងដើម្បីឲ្យសមនឹងប្រទេសយើងដែលឯករាជ្យ កំពុងត្រូវការគេជនជាតិដែលមានចំណេះមានសមត្ថភាព ឲ្យទៅបំរើប្រទេស ។

---

# ពេជ្រព្រះភជា

លោក ស៊ុង - ហ៊ាង ប្រែរៀបរៀង

លោក យូរ - អ៊ុង ពិនិត្យកែសម្រួល

(តមក)

---

លោកនន្ទិ បានពោលពាក្យសុំទោសបិតាខ្ញុំ ហើយទទួលសារភាពថា លោកមិនមានចេតនានឹងចាប់ទោសបិតាខ្ញុំទេ ព្រោះដែលលោកមកនោះ ដោយមានបំណងចង់ដឹងបុត្រប្រុសរបស់លោកដែលជាមនុស្សអាក្រក់ក្នុងរឿងនេះប៉ុណ្ណោះ ព្រោះពេជ្រដែលប្រដាប់មកុដ បានបាត់ទៅក្នុងខណៈដែលលោកមិនទាន់បានទទួលមកុដ អំពីដៃរបស់បុត្រប្រុស ព្រោះវេលានោះលោកកំពុងឈឺធ្ងន់ ក្រោកមិនរួច លុះលោកជាសះស្បើយហើយក៏សួររកមកុដ បុត្រប្រុសក៏នាំមកប្រគល់ឲ្យភ្លាម, ក្នុងខណៈទទួលមកុដមកពិនិត្យមើលទៅ លោកពុំឃើញពេជ្រដែលប្រដាប់មកុដ; លោកសួររក, បុត្រក៏ប្រាប់ថា ខ្លួនបានទទួលមកព្រមទាំងមកុដ និង ពិនិត្យត្រួតត្រាមើលត្រឹមត្រូវហើយ កាលមកដល់ផ្ទះឃើញបិតាឈឺជាទម្ងន់ ក៏នាំទៅដាក់ទុកក្នុងបន្ទប់ដេកលើខ្នងទូដ៏ខ្ពស់ជាទីកំបាំងភ្នែក ដោយនឹកថាគ្មាននរណាដឹងឡើយ តាំងអំពីពេលនោះមកមិនបានទៅចាប់ពាល់ទៀតសោះ ទាល់តែបិតាសួររក ទើបទៅនាំយកមកជូនលោក, អមាត្យនន្ទិមិនជឿនូវសំដីរបស់បុត្រប្រុសថានិយាយពិតត្រង់ លោកមានសេចក្ដីក្រោធខឹងជាខ្លាំង ចូលចិត្តថាបុត្ររបស់លោកប្រព្រឹត្តទុច្ចរិត នាំពេជ្រ

ទៅលាក់ទុកជាថ្នាកដ  កាលលោកនិយាយប្រាប់បិតាខ្ញុំហើយ  ក៏ពោលពាក្យសុំទោស, បិតាខ្ញុំតបថា មិនប្រកាន់ទោសលោកទេ, កន្លែពេលដែលបានដឹងរឿងនេះ  បិតាខ្ញុំសួរលោកថា  បើយ៉ាងនេះតើនឹងធ្វើដូចម្តេច ?  លោកតបដោយសេចក្តីគួរអាណិតថា  ខ្ញុំព្រមទទួលទោសអំពីព្រះរាជា  ខ្ញុំមិនអាចនឹងទៅរកពេជ្រពីទីណាបានទេ  ទោះបីពេជ្រនោះមាន  ក៏ខ្ញុំមិនអាចនឹងរកប្រាក់ទៅទិញគេបានឡើយ  អមាត្យនន្ទិមានសេចក្តីទុក្ខខ្លាំងពេកក៏លាបិតាខ្ញុំទៅ  បិតាខ្ញុំបានចេញជូនដំណើរនន្ទិអមាត្យ ។  ដើរទៅដោយអាការយ៉េងយ៉ោង  ដែលគួរអាណិតអាសូរសូម្បីបិតាខ្ញុំសូមឲ្យលោកឈប់បន្តិចសិន  នឹងប្រើមនុស្សឲ្យយករថសេះជូនទៅ  លោកក៏មិនព្រមសោះ"  មាណពនិយាយមកដល់ត្រឹមនេះក៏ឈប់មួយស្របក់  ហើយក្រោកឡើងងើយមុខមើលមេឃ, វេលានោះជាពេលដែលព្រះអាទិត្យកំពុងលុបជ្រែងក្នុងព្រះសុមេរុ  មានរស្មីស្រទន់នៅលើផ្ទៃមេឃ  ពេលស្រមោលទៅបិទបាំងលោក  ការងងឹតក៏ចូងចូលមកយ៉ាងឆាប់រហ័ស  មាណពទើបបបួលបាលិតអមាត្យឡើងទៅលើផ្ទះបន្ទ ៖

"ឈប់ ១ ស្របក់ចុះលោក !  សន្ទនាគ្នាខាងលើស្រួលជាង  ខ្ញុំត្រេកអរនឹងបញ្ចេញនូវសេចក្តីតានតឹង  ដែលមានមកយូរយារហើយនោះពោលចេញខ្ទះ" ។

មាណពនិងអមាត្យ  នាំគ្នាឡើងទៅសន្ទនានៅកើយមុខ ត្រង់ទិសឧត្តរ  សម្លឹងមើលទៅខាងក្រោមក៏ឃើញស្ទឹងប្រចាំក្រុងវេសាលីកំពុងហូរត្របាញ់  សមគួរដល់ការអង្គុយមើល  ដើម្បីបញ្ចេញ ឬ បន្ទយនូវអារ

ម្មណ៍របស់អ្នកសន្ទនាគ្នា បានយ៉ាងស្រួល, មាណពទើបផ្ដើមនិយាយតទៅ ៖

“ក្នុងអាណាខេត្តអាស្សូរ អមាត្យនន្ទិវៃ្រកពេក, លោកបាននាំម្កុដដែលប្រាសចាកពេជ្រឡើងទៅថ្វាយព្រះរាជា ហើយក្រាបទូលរាយសេចក្ដីដែលបុត្រប្រុសរបស់លោកទទួលមក រហូតដល់បានជូនមកឲ្យដល់លោកទៀត ព្រះរាជាក៏ទ្រង់ព្រះពិរោធខ្លាំង ទ្រង់បញ្ជាឲ្យឃុំឃាំងនូវលោកនន្ទិនឹងបុត្រប្រុស ព្រោះទ្រង់មិនជឿថាជាសេចក្ដីពិត ។ ការណ៍ដែលមិនមានស្នាមគំនូសនៃការបាត់ពេជ្រសូម្បីឈឹងនេះ ព្រះរាជាក៏ទ្រង់ព្រះរាជបញ្ជាឲ្យស៊ើបអង្កេតឡើង តែទោះបីស៊ើបអង្កេតយ៉ាងណា អមាត្យនន្ទិក៏នៅតែនិយាយចាំពាក្យដដែលថា បុត្រប្រុសរបស់ខ្លួនជាអ្នកទទួលទៅអំពីបិតាខ្ញុំ, លោកនន្ទិអមាត្យឆ្លើយឲ្យការណ៍ដោយស្មោះត្រង់ ដោយមិនបានចាប់ពឹកនឹកគិតថា ក្រែងបុត្រប្រុសរបស់ខ្លួននឹងទទួលគ្រោះ ឬការណាទេ បុត្រប្រុសរបស់នន្ទិអមាត្យក៏និយាយនឹងជំហរដូចគ្នាថាមិនបានទៅចាប់ពាល់ម្កុដនោះទៀតឡើយ កាលមកដល់ផ្ទះក៏ដាក់ទុកលើខ្នងទូក្នុងបន្ទប់របស់ខ្លួនតាំងចិត្តថាចាំបិតាសះជាសិន ទើបនឹងនាំយកទៅប្រគល់ឲ្យក្នុងពេលដែលបិតាត្រូវការ, ការស៊ើបអង្កេតមិនបានគោលចារិកភស្តុតាងអ្វីសោះ សឹងតែមានខែលដែលគួរឲ្យគិតថា នន្ទិអមាត្យជាមនុស្សស្មោះត្រង់យូរយារណាស់មកហើយ តាំងពីបានទទួលកាន់ការរាជការផែនដី មិនធ្លាប់ប្រព្រឹត្តទុច្ចរិត ឬមានគំនិតអាក្រក់ក្នុងពេលណាមួយទេ បើប្រសិនលោកនេះជាអ្នកទុច្ចរិតមែន ម្ដេចក៏មិនមានទ្រព្យស្ដុកស្ដម្ភសម្បូរ

សប្បាយនឹងគេ ហេតុម្ដេចមកមានគំនិតមិនស្មោះត្រង់នឹងព្រះរាជាដោយពេជ្រប្រដាប់មកុដក្នុងវ័យចាស់ជរាហើយ; បុត្រប្រុសរបស់នន្ទិអមាត្យទៀត ក៏នៅក្នុងតំណែងជាទាហានឯករក្សាព្រះអង្គ មិនធ្លាប់ប្រព្រឹត្តអាក្រក់មកឡើយ មនុស្សនេះក្រែមអ្នកណានឹងឃើញថាជាអ្នកទុច្ចរិតបាន តែដល់មានរឿងនេះឡើង ក៏មិនផុតអំពីការជាប់ពិរុទ្ធក្នុងរឿងទាក់ទងនឹងពេជ្របាត់ក្នុងពេលនេះ, បណ្ដាមនុស្សទាំង ២ នាក់នេះមិនដឹងជាមនុស្សណាខុស ឬក៏ខុសទាំងពីរនាក់ ព្រោះហេតុនេះឯង ក្នុងទីបំផុត ព្រះរាជាទ្រង់ព្រះបញ្ញាឲ្យពិចារណាទោស នៃនន្ទិអមាត្យនឹងសុវពលទាហានឯករបស់ព្រះអង្គជាការដាច់ខាត ដែលជាហេតុញុំាងការលំបាកឲ្យកើតមានដល់ពួកនាម៉ឺន ជាអ្នកប្រឹក្សារកផ្លូវដាក់ទោស ព្រោះនាម៉ឺនទាំងនោះជាអ្នកស្និទ្ធស្នាលព្រមទាំងដឹងអធ្យាស្រ័យល្អរបស់នន្ទិអមាត្យ តាំងអំពីបានទទួលធ្វើរាជការមកជាមួយគ្នា មិនធ្លាប់មានអ្នកណាអាក់អន់ចិត្តនឹងគាត់ជាហេតុឲ្យចងអាឃាតឡើយ, រឿងរបស់នន្ទិអមាត្យនេះនាម៉ឺនក៏បានដឹងគ្រប់គ្នា, ការពិចារណាដាក់ទោសទៀត ក៏ផុតនឹងវិនិច្ឆ័យបាន ព្រោះទាំងពីរនាក់មិនឆ្លើយបដិសេធ ឆ្លើយទទួលសារភាពត្រឹមតែឲ្យការណ៍ដែលរឹងដំហរគ្រប់ពេល, ដោយគុណធម៌ខ្ពង់ខ្ពស់ដែលនន្ទិអមាត្យធ្លាប់ប្រព្រឹត្តមក ជាគ្រឿងដាស់តឿនចិត្តនាម៉ឺនទាំងឡាយ នាម៉ឺនទាំងនោះទើបបានទូលព្រះរាជា សូមដាក់ទោសត្រឹមតែស្មានស្រាលៗ គឺឲ្យដកចេញពីតំណែងទាំងឪពុកទាំងកូន, ឯការដាក់ទោសស្មានដទៃ ថ្វាយចំពោះព្រះរាជាទ្រង់វិនិច្ឆ័យដោយព្រះប្រាជ្ញាព្រះអង្គឯង ” ។

កាលនិយាយមកដល់ត្រឹមនេះ មាណពក៏បែរមកខាងបាលិតអមាត្យ ហើយសួរថា:

“លោកល្មមជាបបានទេថា ព្រះរាជាទ្រង់ដាក់ទោសនន្ទិអមាត្យនឹងទាហានឯករបស់ព្រះអង្គស្ថានណា ?” ។

“ខ្ញុំយល់ឃើញស្របតាមការយល់ឃើញរបស់នាម៉ឺនទាំងឡាយ” លោកអមាត្យតប ។

“មែនលោក, នរណា ១ ក៏និយាយដូចលោកដែរ ព្រោះការដកចេញចាកយសនឹងតំណែងរាជការ ក៏ជាទោសធ្ងន់ល្មមសមគួរសម្រាប់នន្ទិអមាត្យហើយ តែនន្ទិអមាត្យនឹងបុត្រប្រុសរបស់លោកជាអ្នកមានគ្រោះអាក្រក់ពន់ពេក ព្រះរាជាមិនបានដាក់ទោសតែស្ថាន ១ ទេ ព្រះអង្គទ្រង់ព្រះបញ្ជាឲ្យយកខ្លួនទៅឃុំឃាំងក្នុងគុក ទាល់តែស៊ើបអង្កេតរកសេចក្ដីពិតឃើញ ជាការទុន្ទានយ៉ាងធ្ងន់សម្រាប់បុគ្គលអ្នកមានសេចក្ដីស្មោះត្រង់សុចរិត, អើលោក! ខ្ញុំប្រាថ្នានឹងសូមសេចក្ដីយល់អំពីលោក សូមលោកប្រើប្រាជ្ញាត្រិះរិះមើល ក្រែងលោមានសេចក្ដីយល់ឃើញខ្លះ ហើយលោកប្រាប់ខ្ញុំជាថ្មីថា នន្ទិអមាត្យនឹងបុត្រប្រុសលោកជាអ្នកបរិសុទ្ធ ឬជាអ្នកទុច្ចរិត? ។

ក្នុងពេលព្រលប់មើលគ្នាឃើញស្ទុង ដែលមានពន្លឺព្រះច័ន្ទបញ្ចាំងចូលមកក្នុងបន្ទប់ អមាត្យបាលិតដកដង្ហើមញាប់ ៗ បែបដូចជាមានអាការគិតខ្លាំង, មាណពទំរេតផ្អែកទៅលើក្អាក់ដៃកៅអី ភ្នែកសម្លឹងទៅមេឃឆ្ងាយ ត្រចៀកចាំស្ដាប់សំដីរបស់បាលិតអមាត្យ ដោយតុណ្ហីភាព ។

មិនមានសម្លេងណា ចូលមកទំលាយនូវសេចក្ដីស្ងៀមស្ងាត់ក្នុងខណៈនេះ ក្រៅពីខ្យល់ជំនោរបក់មកត្រសៀកៗ ស្រូបយកក្លិននៃបុប្ផជាតិក្នុងព្រឹមកមួយដងៗ ក្លិនក្រអូបនោះជារបស់នាំឲ្យរីករាយចិត្ត; ជនទាំង ២ នាក់ ដែលបានស្រូបក្លិននោះហើយ អាចរសាយសេចក្ដីបង្អៀតបង្អល់ក្នុងចិត្តទៅបានខ្លះ ។

បាលិតអមាត្យតបថា “ក្រណាស់ មាណព; ផុតបញ្ញារបស់ខ្ញុំ, ជាសេចក្ដីកំបាំងដែលលំបាកនឹងប្រាប់គ្នា សូម្បីតែនឹងកាត់ស្មាន ឬល្បងតាយមើល ក៏មិនឃើញមានផ្លូវសោះ បើនឹងដាក់ទោសថា កូនប្រុសរបស់លោកនន្ទិជាមនុស្សទុច្ចរិតទៅ ក្រែងមានអ្នកដទៃនៅក្នុងផ្ទះលួច ឬមនុស្សក្រៅផ្ទះមកលួច” ។

‘មិនមានទេលោក, អំពីមនុស្សក្នុងផ្ទះខ្ញុំមិនទាន់បានប្រាប់លោក, នន្ទិអមាត្យជាអ្នកសន្ដោស, ក្នុងផ្ទះរបស់លោកមានមនុស្សបំរើម្នាក់ជាស្ត្រីជរា, បន្ទប់ដែលបុត្រប្រុសរបស់លោកនៅ ហើយដែលនាំពេជ្រទៅទុក ក៏មានកូនសោចាក់យ៉ាងមាំមួន ហើយជាបន្ទប់ជាន់លើមិនមាននរណាឡើងចុះទៅធ្វើការរវីករវរនៅទីនោះឡើយ” ។

“បើដូច្នោះ មាណពឯងធ្លាប់បានគិតទុកយ៉ាងដូចម្ដេច?” បាលិតអមាត្យសួរ ។

“ខ្ញុំតាលបញ្ញាហើយ មិនដឹងគិតយ៉ាងដូចម្ដេចទេ ព្យាយាមគិតរាយបញ្ហាក្នុងរឿងនេះគ្រប់ផ្លូវអស់ហើយ ក៏មិនអាចនឹងដោះស្រាយតាម

គន្ធណាៗបាន លោកបានស្តាប់ខ្ញុំនិយាយហើយ ម្តេចគង់មិនអាចនឹងយល់ឃើញបាន តើឲ្យខ្ញុំយល់ឃើញដូចម្តេចកើត” មាណពតបវិញ ។

គួរអាណិតនន្ទិអមាត្យពន់ពេក ដកណាស់ហើយមកត្រូវឃុំឃាំង, បុត្រប្រុសរបស់លោកជាទាហានឯក មិនគួរនឹងមាត់វែង គួរតែអាណិតឪពុករបស់ខ្លួន បើខ្លួនមិនខុសក៏គួរសារភាពខ្លួនថាខុសតែម្នាក់ឯង ដើម្បីសង្គ្រោះឪពុកឲ្យរួចពីទោសទុក្ខ, បើនេះនន្ទិអមាត្យនឹងត្រៀមត្រិះគិតយ៉ាងណាទៅ? រូបមាណពពោលតទៅទៀតៈ

“ម៉ែនទៅ នន្ទិអមាត្យជាអ្នកស្មោះត្រង់ ត្រូវត្រៀមត្រិះគិតជាខ្លាំង ឯសុរពលជាបុត្រប្រុសលោក កាលខ្ញុំទៅសួរនាំកងទ័ពឃុំឃាំង បាននិយាយប្រាប់ខ្ញុំថា ចង់ទទួលជាអ្នកទុច្ចរិតតែម្នាក់ឯងដែរ តែមិនអាចនឹងទទួលបាន ព្រោះខ្លួនបរិសុទ្ធពិតៗ មិនមែនជាមិនមានសេចក្តីអាណិតអាសូរឪពុកនោះទេ មិនតែប៉ុណ្ណោះ សុរពលបានស្បថស្បែប្រាប់ខ្ញុំថា ខ្លួនជាទាហានរក្សាពាក្យសត្យជានិច្ច សេចក្តីស្មោះត្រង់ស្រឡាញ់ក្តី ចំពោះព្រះរាជាក៏មាំមួន; មុនដែលខ្ញុំនឹងលាត្រឡប់មកផ្ទះវិញ សុរពលចាប់ដៃខ្ញុំមានក្រសែភ្នែកហាក់ដូចជាចង់អង្វរខ្ញុំឲ្យជួយធុរៈអ្វីមួយ កាលខ្ញុំញាក់មុខឲ្យសញ្ញាថាចង់និយាយអ្វីនិយាយមកចុះ សុរពលក៏ពោលថា គេមានប្អូនស្រីម្នាក់ ឥឡូវនេះគេនឹងឪពុកគេមិនដឹងថា ព្រះរាជានឹងឃុំឃាំងទុកយូរត្រឹមណាទេ បើខ្ញុំមិនរង្កៀសអាណិតអាសូរគេនឹងបិតាគេហើយ សូមជួយយកធុរៈមើលថែទាំប្អូនស្រីគេឲ្យផង ខ្ញុំមានចិត្តជ្រះថ្លាដោយនឹកថាមិនជាក្រលំបាកអ្វីឡើយ, ទើបប្រាប់ថា ណ្ហើយចុះ

សុរពលខ្ញុំនឹងយកចិត្តទុកដាក់មើលថែទាំប្អូនស្រីអ្នកឯង ដូចជាប្អូនរបស់ខ្ញុំ សុរពលត្រេកអរនឹងខ្ញុំយ៉ាងក្រៃលែង, ថ្ងៃនោះខ្ញុំបានសួរនាំតែសុរពលប៉ុណ្ណោះ ចំណែកនន្ទិអមាត្យមិនព្រមនិយាយអ្វីនឹងខ្ញុំសោះ អង្គុយព្រងើយក្រងទយុំយាំង ខ្ញុំចូលទៅលាលោកៗ គ្រាន់តែញាក់មុខប៉ុណ្ណោះ ខ្ញុំបានជំរាបលោកថា ខ្ញុំទទួលភារៈជាអ្នកមើលថែទាំបុត្រស្រីរបស់លោក សូមលោកកុំព្រួយបារម្ភឡើយ ពេលនោះលោកបានបែរមុខមកសម្លឹងមើលខ្ញុំៗ មើលទៅឃើញលោកមានទឹកមុខរីករាយ ” ។

*

* *

## សេចក្តីស្រឡាញ់ពិតប្រាកដឬទេ ?

— ៤ —

ខ្ញុំត្រឡប់មកដល់ផ្ទះក្នុងវេលាល្ងាចណាស់ហើយ ប្រញាប់ទៅជម្រាបឱ្យបិតាខ្ញុំជ្រាបថា ខ្ញុំបានត្រឡប់មកពីសួរនាំនន្ទិអាមាត្យនឹងសុរ-ពល, បិតាខ្ញុំពេញចិត្តនឹងខ្ញុំដែលបេះប្រព្រឹត្តសមគួរក្នុងការទៅសួរនាំលោកនន្ទិអមាត្យជំនួសលោក, លោកនិយាយថា “ ដែលកូនឯងបានធ្វើយ៉ាងនេះ លោកនន្ទិនឹងដឹងថាយើងមិនលះបង់ចោលលោក ក្នុងគ្រាមានវិបត្តិមកដល់ខ្លួនលោក ” ហើយសាកសួរបន្តិចបន្តួចខ្លះទៀត ខ្ញុំក៏បានជំរាបគាត់ថា សុរពលផ្ដាក់ផ្ញើប្អូនស្រីនឹងខ្ញុំ ឲ្យខ្ញុំជួយយកធុរៈមើលថែទាំជំនួសផង តើការណ៍នេះខ្ញុំគួរធ្វើដូចម្ដេច សូមលោកឪពុកពន្យល់ខ្ញុំផង ។

(មានត)

# រឿងសាមកុក

## កណ្ឌទី ២៤

ឧកញ៉ាវិបុលរាជសេនា ញ៉ុក-ថែម ប្រែរៀបរៀង

(តមក)

---

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
នឹងចេះឧបាយកលបំណាន
ទាំងមានសន្ដានស្នេហាជាតិ ។

គួនអ៊ូថា លោកមេវត្តនេះ ជាពួកម៉ាកនៅស្រុកទេសជាមួយនឹងយើង បែកគ្នាមកជាយូរហើយ ទើបនឹងបានមកជួបគ្នាថ្ងៃនេះបានជាត្រូវសាកសួរសុខទុក្ខខ្លះ ៗ លោកគ្រូចិនកៅចេងក៏រៀបទីកន្លែងឲ្យគួនអ៊ូអង្គុយ ហើយចាក់ទឹកតែឲ្យគួនអ៊ូផឹក ៗ គួនអ៊ូថាបងថ្លៃខ្ញុំទាំង ២ នៅលើរថមុខវត្តឯណោះមិនបានផឹកផង ខ្ញុំនឹងផឹកមុនធ្វើម្ដេចបាន ៗ លោកគ្រូចិនកៅចេងក៏យកទឹកតែនាំគួនអ៊ូចេញទៅឲ្យបងថ្លៃលើរថផឹកទាំង ២ នាក់ លោករកឱកាសស្ងាត់នឹងប្រាប់គួនអ៊ូពុំបាន ព្រោះពៀនហ៊ីចេះតែតាមមើលបើនឹងនិយាយក្រែងពៀនហ៊ីឮ ព្រោះពួកម៉ាកពៀនហ៊ីដើរទៅមកមិនដាច់ ៗ លោកគ្រូចិនកៅចេងក៏យកចង្អុលដៃ ចង្អុលទៅត្រង់គ្រឹះគួនអ៊ូសៀត ហើយក៏ញាក់ភ្នែកឲ្យដឹង ៗ គួនអ៊ូក៏យល់សេចក្ដីថា

ពៀនហ៊ុនឹងធ្វើអន្តរាយ បានជាបង្គាប់ទាហានឲ្យកាន់អាវុធតាមគួនអ៊ូទៅ លោកគ្រូបិនកៅចេងនឹងគួនអ៊ូក៏ត្រឡប់ចូលទៅវត្តវិញ ។ ពៀនហ៊ុដំណប គួនអ៊ូថា ខ្ញុំបាទឲ្យរៀបក្រយាជូនលោកពីសារៀបទុកជាស្រេចហើយ អញ្ជើញលោកចូលទៅខាងក្នុងចុះ ។

គួនអ៊ូបានស្តាប់ហើយក៏ឥតកោតញញើតឡើយ ចូលទៅអង្គុយជាមួយនឹងពៀនហ៊ុ ឃើញពួកម៉ាកពៀនហ៊ុឈរតំរៀបគ្នា សុទ្ធតែសៀតគ្រឹះលាក់បង្កប់ក្នុងអាវ ឃើញដងលេចចេញមកខាងក្រៅ គួនអ៊ូក៏សួរពៀនហ៊ុថា ដែលអ្នកអញ្ជើញយើងមកបរិភោគនេះជាល្អឬអាក្រក់? ពៀនហ៊ុតក់ស្លុតក្នុងចិត្តញ័ររន្ធត់អស់ទាំងខ្លួនមិនឆ្លើយថាអ្វីសោះ ។

គួនអ៊ូឃើញពៀនហ៊ុជាប់ពិរុទ្ធដូច្នោះ ក៏ស្រែកគំហកថា អញគិតថាឯងជាមនុស្សល្អ អញក៏ធ្វើត្រង់ល្អចូលមក គួរឬឯងគិតប្រទូសរ៉ាយដល់អញ? ពៀនហ៊ុឃើញគួនអ៊ូដឹងរឿងហើយក៏ស្រែកហៅទាហានថា ពួកយើងចុះដៃជាប្រញាប់ ! ទាហានដែលឈរនោះមិនទាន់នឹងកំរើកខ្លួន គួនអ៊ូស្ទុះទៅកាប់ស្លាប់ជាច្រើននាក់ ពៀនហ៊ុភ័យណាស់ស្ទុះរត់ទៅចូលក្នុងកឹង គួនអ៊ូបោលគ្រឹះពីដៃគន្ទាក់យកដាវដេញតាមទៅ ពៀនហ៊ុឃើញគួនអ៊ូដេញជិតក៏យកកូនឃ្លុបត្រឡប់បោលតម្រង់មកវិញ គួនអ៊ូយកដាវវាយទាត់កូនឃ្លុបខ្ទាតចេញ ក៏កាប់ពៀនហ៊ុដាច់ពាក់កណ្តាលខ្លួនស្លាប់ ហើយត្រឡប់ទៅឯបងថ្លៃឃើញទាហានពៀនហ៊ុព័ទ្ធជុំវិញជាច្រើន គួនអ៊ូក៏ដេញកាប់សម្លាប់ទាហានទាំងនោះបែករត់ទៅខ្លះ ស្លាប់ពិការខ្លះ ហើយគួនអ៊ូក៏ចូលទៅទូលលោកគ្រូបិនកៅចេងថា គ្រានេះ

បើកុំតែលោកឲ្យដំណឹងខ្ញុំៗ ក៏នឹងអន្តរាយជីវិត ។ លោកគ្រូបិនកៅចេងថា ខ្លួនអាត្មាភាពនឹងទៅក្នុងវត្តនេះតទៅ ពួកម៉ាកតៀនហ៊ុកក៏នឹងគុំគួនធ្វើអន្តរាយជាមិនខាន អាត្មាភាពនឹងទៅរកវត្តឯទៀតនៅហើយ ។ គួនអ៊ូក៏លាលោកគ្រូចិនកៅចេងចេញទៅ នាំទេបងថ្លៃនិងអាហារតម្រង់តាមផ្លូវទៅស្រុកអៀងយ៉ុង ។

ឯអងសិកចៅហ្វាយស្រុកអៀងយ៉ុង ដែលជាដទួងនឹងហាន់ហុកនោះ លុះឮដំណឹងថា គួនអ៊ូសម្លាប់ហាន់ហុកស្លាប់ ក៏ទុកគិតតែក្នុងចិត្តថា " គួនអ៊ូនេះមានថ្វីដៃខ្លាំងពូកែមែន បើនឹងចាប់យកខ្លួនចំពោះមុខមិនបានទេ ត្រូវតែធ្វើកលឧបាយឲ្យគួនអ៊ូទុកចិត្តសិន ហើយសឹមចាប់សម្លាប់ចេញ " គិតហើយក៏កេណ្ឌប្រមូលអាហារ ឲ្យទៅស្កាត់នៅគយតាមផ្លូវជាច្រើនតំបន់ កុំឲ្យគួនអ៊ូរត់រួចទៅបាន លុះអងសិកដឹងដំណឹងថា គួនអ៊ូមកដល់ស្រុកហើយ ក៏ឡើងសេះនាំអាហារចេញទៅទទួលគួនអ៊ូ ដោយសុភាព ហើយសួរថា អ្នកមកនេះនឹងទៅណា ? ។ គួនអ៊ូតបថា យើងលាមហាឧបាជនឹងនាំបងថ្លៃទៅរកឡោពីងស្រុកគីជីវ ។ អងសិកថា អ្នកមកតាមនេះជាផ្លូវដាច់ស្រយ៉ាលឆ្ងាយណាស់ ពេលក៏ជិតយប់ហើយ សូមអញ្ជើញអ្នកនឹងបងថ្លៃទៅសំណាក់ក្នុងស្រុកនេះសិន ព្រឹកឡើងសឹមអញ្ជើញទៅ ។ គួនអ៊ូបានស្តាប់អងសិកនិយាយ ក៏មិនមានសេចក្តីសង្ស័យ ទើបឆ្លើយថា បើអ្នកអនុគ្រោះហើយ យើងក៏សំណាក់នៅទីនេះ ១ យប់ចុះ ។ អងសិកក៏នាំគួនអ៊ូនិងគ្រួសាឡោពី ចូលទៅក្នុងស្រុក ហើយចាត់ចែងទីដំណេកនិងទីបរិភោគ ខណៈនោះអងសិកក៏

ត្រឡប់មកឲ្យរៀបចំចំណីអាហារអញ្ជើញគួនអ៊ូបរិភោគ មនុស្សបំរើក៏ទៅអញ្ជើញគួនអ៊ូៗក៏នឹកតែក្នុងចិត្តថា "ពៀនហ៊ុហៅយើងទៅបរិភោគអាហារ ក៏គិតប្រទូសរ៉ាយយើងម្ដងហើយ ឥឡូវអងសិកឲ្យហៅយើងទៅបរិភោគម្ដងទៀត ខ្លាចក្រែងធ្វើជាកលឧបាយដូចពៀនហ៊ុទៀតទេដឹង" គួនអ៊ូកកនឹកក្នុងខណៈនោះក៏ឲ្យពិភាល់សង្ស័យ ទើបប្រាប់ទៅមនុស្សបំរើនោះថា ដែលអងសិកឲ្យហៅយើងទៅទទួលទានអាហារនោះយើងមានសេចក្ដីអរគុណច្រើនណាស់ តែថាបងថ្លៃយើងជាស្រីគ្មាននរណានៅកំដរសោះយើងនឹងទៅពុំបាន ៗ មនុស្សបំរើនោះក៏វិលទៅប្រាប់អងសិកៗ ក៏ឲ្យលើកយកចំណីអាហារទៅជូនគួនអ៊ូដល់ទីកន្លែង គួនអ៊ូក៏ឲ្យយកសម្រាប់នោះជូនទៅឲ្យបងថ្លៃពិសា ៗ លុះពេលយប់គួនអ៊ូបង្គាប់ទាហានឲ្យនាំគ្នាដេក ឯខ្លួនគួនអ៊ូក៏ដោះក្រែសចេញអង្គុយអុជទៀនមើលសៀវភៅយាមក្បែរបងថ្លៃនៅខាងក្រៅ ៗ

អងសិកទើបបង្គាប់ហោប៉ាន់ថា ឥឡូវគួនអ៊ូរត់ពីមហាឧបរាជមកសម្លាប់ហាន់ហុកចៅហ្វាយស្រុកនិងនាយគយល្បាតទាំង ២ នាក់ស្លាប់ទៅហើយ បើយើងនឹងព្រួតចាប់យកខ្លួនបញ្ជូនទៅទីក្រុងវិញ គួនអ៊ូមានថ្វីដៃខ្លាំងពូកែណាស់ ទោះបីយើងនឹងចាប់ខ្លួនបានគង់តែទាហានយើងស្លាប់ជាច្រើននាក់មិនខាន ចាំយើងរិះគិតមានសម្លាប់គួនអ៊ូចេញក្នុងវេលាយប់នេះពេលយាម ៣ អ្នកឯងត្រូវលើកទាហាន ១ ពាន់ឲ្យកាន់ឧសនឹងចំបើងម្នាក់មួយបាច់ ទៅឡោមព័ទ្ធទីកន្លែងដែលគួនអ៊ូសំណាក់ ហើយយកភ្លើងដុតព័ទ្ធជុំវិញទីនោះឲ្យគួនអ៊ូនិងពួកម៉ាកស្លាប់តែម្ដង បើកាលណា

ផុតភ្លើងនេះឲ្យផុតផាវផាសញ្ញាយើងនឹងលើកទាហានទៅជួយ ។ ហោប៉ានក៏លើកទាហាន ១ ពាន់ កាន់ឧសនឹងចំបើងគ្រប់ដៃ ទៅគរទុកជុំវិញទីសំណាក់គួនអ៊ូ តែនៅមិនទាន់ផុតភ្លើង ។

ហោប៉ានត្រិះរិះគិតក្នុងចិត្តថា "មនុស្សនានាក៏បានឮល្បីថា គួនអ៊ូនេះជាមនុស្សមានថ្វីដៃខ្លាំងពូកែខាងសឹកសង្គ្រាមណាស់ យើងក៏មិនដែលជួបប្រទះឃើញរូបរាងសោះ បើដូច្នេះយើងចាំទៅលបមើលឲ្យឃើញច្បាស់សិន" គិតហើយហោប៉ានក៏ចូលទៅសួរនាយទ្វារថា គួនអ៊ូនៅឯណា? នាយទ្វារប្រាប់ថា គួនអ៊ូអង្គុយមើលសៀវភៅខាងល្វែងក្រៅ ។ ហោប៉ានក៏លបដើរចូលទៅឈរមើលឃើញគួនអ៊ូអង្គុយមើលសៀវភៅលើកៅអី ដៃម្ខាងច្បូតពុកមាត់ ។

ហោប៉ានពិនិត្យមើលទាល់តែភ្ញាក់ស្មារតី ហើយស្រែកសរសើររូបឆោមគួនអ៊ូថា ល្អប្រហែលទេពតា ។ គួនអ៊ូបានឮសំឡេងក៏ភ្ញាក់ស្មារតីភ័យណាស់ ស្រែកសួរទៅវិញថា នរណាចូលមកមានការអ្វី? ហោប៉ានក៏ចូលទៅលុតជង្គង់គំនាប់ហើយឆ្លើយថា ខ្ញុំបាទឈ្មោះហោប៉ាននាយទាហានអនិសិក ។ គួនអ៊ូឮថា ឈ្មោះហោប៉ានក៏នឹកចាំបាន ហើយសួរថា អ្នកឯងជាកូនហោហ៊្វូឬ? ហោប៉ានឆ្លើយថាបាទ ។ គួនអ៊ូក៏យកសំបុត្រដែលហោហ៊្វូផ្ញើមកនោះ ហុចឲ្យទៅហោប៉ាន ។ ទទួលយកមកមើលឃើញសេចក្តីថា "ហោហ៊្វូជាបិតា ផ្ញើសំបុត្រនេះមកដល់ហោប៉ានជាកូនឲ្យបានដឹង ដ្បិតគួនអ៊ូនេះមានថ្វីដៃខ្លាំងពូកែណាស់ តាំងចិត្តក៏ជាមនុស្សកតញ្ញូទៀងត្រង់នឹងផែនដី បើគួនអ៊ូមកដល់ទីតំបន់ណា ហើយហោប៉ាន

បានជួបប្រទះក៏កុំឲ្យគិតប្រទូសរ៉ាយ ត្រូវតែរកឧបាយជួយទំនុកបំរុងគួនអ៊ូឲ្យបានចេញទៅដោយស្រួល ព្រោះតំណាទៅឯមុខនឹងបានជាទីពឹងពំនាក់" ហោបាន់ដឹងកូនសំបុត្រដូច្នោះក៏ភ័យស្លុតក្នុងចិត្ត ទើបចូលមកជិតគួនអ៊ូហើយខ្សឹបថា "ខ្ញុំបាទមិនដឹងសោះជាឈ្មោះលោកល្អបរិសុទ្ធ កុំអីជីវិតលោកនឹងក្ស័យក្នុងទីនេះ ព្រោះអង់សិកគិតធ្វើប្រទូសរ៉ាយលោកឲ្យទាហានយកឧសនឹងចំបើងមកគរដុតភ្លើងឲ្យលោកស្លាប់ ឥឡូវលោកបួរត្រៀមខ្លួនទុកជាប្រញាប់ចុះ ខ្ញុំបាទនឹងទៅគិតឃាត់ហាមទាហានទាំងពួង ហើយនឹងហួសទៅបើកទ្វារស្រុកទុកឲ្យលោកចេញទៅដោយស្រួល" និយាយហើយក៏លាចេញទៅតាក់ការមួយរំពេច ។

គួនអ៊ូបានឮហោបាន់ពណ៌នាប្រាប់សព្វសេចក្ដី ក៏ភ័យតក់ស្លុតរន្ធត់ចិត្ត ទាំងមានសេចក្ដីត្រេកអរគុណនឹងហោបាន់ពន់ប្រមាណណាស់ ទើបក្រោកឡើងពាក់គ្រឿសកាន់ដាវ ហើយអញ្ជើញបងថ្លៃឲ្យឡើងជិះរថឲ្យទាហានឃុំនាំចេញទៅមុខ គួនអ៊ូក៏ជិះសេះការពារពីក្រោយ លុះទៅដល់ឃើញទ្វារស្រុកចំហក៏មានអំណរណាស់ ទើបឲ្យទាហានបររថចេញផុតអំពីទ្វារក្រុងទៅ ។ ហោបាន់ឃើញគួនអ៊ូចេញហួសទៅហើយ ក៏វិលត្រឡប់មកប្រាប់ទាហានឲ្យដុតភ្លើងគ្រប់គ្នាឡើង ។ គួនអ៊ូចេញទៅចម្ងាយផ្លូវប្រហែល ៣០ សិន (១.២០០ ម.) ត្រឡប់ទៅឃើញភ្លើងឆេះកណ្ដាលស្រុកភ្លឺដូចថ្ងៃ ក៏ចូលចិត្តថាហោបាន់ធ្វើឧបាយលុបលាងសេចក្ដីកុំឲ្យអ្នកផងដឹងគំនិតខ្លួន ។

ឯអង់សិកបានឮសំឡេងផាវហើយឃើញពន្លឺភ្លើងឆេះឡើង ក៏លើក

ទាហានស្រូតដល់ទីសំណាក់គួនអ៊ី ទាហានទាំងពួនស្រែកថា គួនអ៊ីរត់ពះភ្លឹងចេញរួចទៅហើយ ។ អង់សិកឮដូច្នោះ ក៏បរសេះនាំទាហានស្រុតតាមទៅដល់ក្រៅស្រុក ហើយស្រែកថា គួនអ៊ីមានថ្វីដៃខ្លាំងពូកែ ហេតុម្តេចក៏លបរត់ទៅមិនទៅចាំតដៃនឹងយើងសិន ។ គួនអ៊ីតបថា អញគ្មានធ្វើខុសអ្វីនឹងឯងសោះ ហេតុអ្វីឯងមកគិតប្រទូសរ៉ាយអញ ។ អង់សិកខឹងណាស់មិនឆ្លើយតបថាអ្វីសោះ ក៏បរសេះកាត់ខ្លួនចូលច្បាំងនឹងគួនអ៊ីៗញាក់សេះពថយមកតទល់យកដាវទាត់ខ្លួនធ្លាក់ពីដៃអង់សិក ហើយលើកដាវកាប់អង់សិកដាច់ពាក់កណ្ដាលខ្លួនស្លាប់នៅទីនោះ ទាហានទាំងអស់ក៏រត់បែកខ្ចាត់ខ្ចាយអស់ទៅ ។ គួនអ៊ីបរសេះតាមបងថ្ងៃទៅទៀត គង់ចិត្តនោះនឹកដល់គុណហោប៉ាន់មិនភ្លេច ។

ឯឡៅអៀនចៅហ្វាយស្រុកតង់គុនដឹងដំណឹងថា គួនអ៊ីរត់ពីមហាឧបរាជហែកទំលាយគយល្បាតមក បានសម្លាប់នាយគយទាំងចៅហ្វាយស្រុកស្លាប់ជាច្រើនតំបន់ ឡៅអៀនក៏ឃុំទាហានប្រហែល ៣០ នាក់ចេញមកចាំស្កាត់ផ្លូវ ។ គួនអ៊ីឃើញឡៅអៀនក៏សួរថា សព្វថ្ងៃនេះ អ្នកនៅរក្សាស្រុកសុខសប្បាយទេឬ? ឡៅអៀនឆ្លើយថា សុខសប្បាយជាទេ ចុះអ្នកមកនេះនឹងទៅណា ? ។ គួនអ៊ីតបថា យើងបានលាមហាឧបរាជ ដើម្បីនឹងទៅរកឡៅពីដាចង់យើង ។ ឡៅអៀនតបថា ឡៅពីទៅកាស្រ័យនៅទឹងអ៊ុនសៀវ ឥឡូវអ៊ួនសៀវនឹងមហាឧបរាជធ្វើសឹកសង្គ្រាមនឹងគ្នា ខ្ញុំយល់ថា មហាឧបរាជមិនបើកឲ្យអ្នកទៅតាម

ស្រលទេ ទុកជាអ្នកបានរត់មកដល់ទីនេះក៏នឹងមិនផុតទៅបាន ព្រោះហៃហ៊ុឡុនទឹងជិនគីតាំងទ័ពនៅតំបន់ត្រើយទន្លេហាងហោ ។

គួនអ៊ូតបថា ពីដើមមហាឧបរាជទទួលប្ដេជ្ញាទុកនឹងយើង ឥឡូវយើងឮដំណឹងបងយើងហើយ យើងក៏ត្រូវចេញមកតាមសញ្ញា អ្នកបូរអាណិតជួយចាត់រកទូកចម្លងជូនយើងទៅត្រើយម្ខាង ត្រង់កំពង់ខាងត្បូង ឬខាងជើង ល្មមឲ្យផុតពីទ័ពហៃហ៊ុឡុនចុះ ។ ឡៅអៀនថា ទូករបស់យើងក៏មាននៅស្រាប់ តែដែលនឹងចម្លងជូនអ្នកទៅ ទោសក៏ត្រូវមានដល់យើង ។ គួនអ៊ូតបថា ស្រុកដែលអ្នករក្សានៅនេះក៏ជាស្រុកមុខគយ ខ្លួនយើងក៏បានយកអាសាសម្លាប់ឆាទ់លៀង, ប៊ុនជីវ ដែលជាទាហានឯកអ៊ូនសៀវស្លាប់ ហើយអ្នកទើបបានសេចក្ដីសប្បាយដោយសារយើងដែរ ហេតុម្ដេចក៏ភ្លេចមិនគិតដល់គុណយើងផង គ្រាន់តែឲ្យចម្លងជូនទៅប៉ុណ្ណោះមិនបាន" ហើយគួនអ៊ូមិនបានគិតញញើត ទើបឲ្យទាហានបររថបង្ហួសទៅដល់មាត់ទន្លេហាងហោ ។

ឯជិនគីដែលហៃហ៊ុឡុនឲ្យឃុំទាហានមកតាំងបន្ទាយនៅតំបន់ ១ លុះឮដំណឹងថា គួនអ៊ូនាំបងថ្លៃមកដល់មាត់ទន្លេហើយ ក៏ឡើងសេះលើកទាហានចេញពីបន្ទាយហើយក្ដែងស្រែកសួរថា នរណាហ៊ានដើររម្លងមុខទ័ពយើង មកនេះនឹងទៅណា? គួនអ៊ូស្រែកតបថា យើងឈ្មោះគួនអ៊ូនឹងសុំឆ្លងទៅត្រើយម្ខាង ដើម្បីទៅរកឡៅពីជាបងយើងនៅស្រុកខាងជើង ។ ជិនគីសួរថា មានសំបុត្រមហាឧបរាជបើកគយមកដែរឬទេ? គួនអ៊ូប្រាប់ថា យើងមិនមែនជាខ្ញុំកំដរស៊ីបៀវត្សរ៍របស់មហាឧបរាជកាលណា

ត្រូវការអ៊ីទឹងសុំសំបុត្រនាំឲ្យរវល់ ៗ ជនគីស្រែកថា យើងជាទាហាន
រង់ហែហ៊ុំទុនជាមេទ័ពបង្គាប់យើងមកនៅក្រោទីនេះ មិនឲ្យនរណាដែល
មិនមានសំបុត្របើកគយមកនោះឆ្លងទៅមកបានទេ គុំថាតែមនុស្សដើរដី
ដូចយ៉ាងអ្នកឯងនេះឡើយ ទោះជាសត្វមានស្លាបហើរលើអាកាស
ក៏ទៅមិនរួចទឹងដៃយើងឡើយ ៗ គួនអ៊ីបានស្តាប់ដូច្នោះ ខឹងខ្លាំង
ណាស់ ឆ្លើយថា ដែលយើងមកនេះខ្លួនមិនបានឮដំណឹងល្បីឈ្មោះ
យើងខ្លះទេឬ? អ្នកដែលឃាត់ខាំងទទឹងយើងៗ សម្លាប់ចោលជាច្រើន
នាក់មកហើយ ៗ ជនគីថា ដែលខ្លួនសម្លាប់បាននោះតែទាហានណា
ដែលគ្មានថ្វីដៃ ឯមនុស្សយ៉ាងយើង អ្នកមិនធ្វើម្តេចបាន ៗ គួនអ៊ីថា
ដែលខ្លួនអួតថាខ្លាំងពូកែនោះ បើប្រៀបទឹងថ្វីដៃអាន់លៀង, ប៉ុនធីរ
បានឬទេ? ជនគីបានស្តាប់ក៏ខឹងណាស់ ទើបបរសេះកាន់ដាវចូលច្បាំង
ទឹងគួនអ៊ីបាន ១ ក្បួន គួនអ៊ីលើកដាវកាប់ត្រូវជនគីដាច់កធ្លាក់ពីលើសេះ
ស្លាប់ ទាហានទាំងអស់ក៏បែកបាក់ខ្ចាត់ខ្ចាយរត់ទៅ គួនអ៊ីក៏ស្រែកឃាត់
ទាហានដែលរត់នោះឲ្យឈប់ថា អ្នកទាំងពួងមិនបានធ្វើខុសអ្វីកុំគប្បីរត់
ខ្លាចយើងឡើយ យើងមិនបានធ្វើអន្តរាយអ្វីទេ ចូរជួយរកទូកចម្លងយើង
ទៅត្រើយម្ខាងចុះ ។ ទាហានទាំងពួងបានស្តាប់គួនអ៊ីស្រែកដូច្នេះ ក៏
បបួលគ្នាបាត់រកទូកចម្លងជូនគួនអ៊ីទៅត្រើយម្ខាង ៗ

(មានត)

# រឿងបល្ល័ង្កទិព្យ សាមសិបពីររឿង

រឿងព្រេងគតណ្ឋៀ

## លោកសម៉ិន ម្ចៀនជឹមៈតែង
## លោកវ៉ាយ-ប៊ុក ក្រមការ ដើមខ្សែប្រែរៀបរៀង

(តមក)

---

## និទាននៃរូបទេពនិម្មិតទី ២៣

( តមក )

ដល់ពេលជិតមរណៈ នាយពាណិជនោះក៏បានពោលទៅកាន់បុត្រទាំង ៤ ថា "ឱកូន, ក្រោយដែលបិតាធ្វើកាលកិរិយាទៅកាន់បរលោក កូនត្រូវតែរួបរួមសាមគ្គី កុំឈ្លោះទាស់ទែងគ្នា ៗ ផលប្រយោជន៍ដែលបានមកពីគ្រួសារដែលសាមគ្គីគ្នា មានសារៈសំខាន់បំផុត គឺការដែលជួយគ្នាទៅវិញទៅមក, មនុស្ស បើទុកជាមានគ្នាចំនួនតិច ក៏គង់អាចបំពេញកិច្ចការដែលលំបាកឲ្យសម្រេចទៅបាន, ប្រៀបដូចជាសរសៃតិណជាតិរួបរួមប្រមូលជាបាច់ អាចការពារមិនឲ្យភ្លៀងហូរទទឹកបាន ; សរសៃតិណជាតិដដែលនេះ បើឋិតនៅពត់ពយ មិនអាចការពារនូវទឹកភ្លៀងបានទេ បើតាមសភាពផ្ទុយវិញ ទឹកភ្លៀងអាចធ្វើឲ្យស្វាប់នូវតិណជាតិបាន ។ ហេតុដូច្នេះ កូនត្រូវតែឋិតនៅស្រុះស្រួលរួបរួមគ្នាជាសុខចុះ ។ បើជោគវាសនា ជំទាស់មិនឲ្យកូននៅរួបរួមគ្នាបានទេ បិតាបានកប់ថូកែវ ៤ នៅក្រោមបន្ទប់ដេកបិតា, ថូកែវនោះមានចារិកអក្សរដាក់ឈ្មោះកូនឯង

ទាំង ៤ នាក់, ដូច្នេះ បើអ្នកបានរកឃើញហើយ ចូរយកថូកែវនោះតាមឈ្មោះសត្វៗ ខ្លួនចុះ" ។ ក្រោយដែលបានផ្ដាំកូនដូច្នេះហើយ នាយពាណិជក៏ធ្វើមរណកាលទៅ ។

ពីរបីថ្ងៃក្រោយមក កូនទាំងបីនោះឈ្មោះទាស់ទែងគ្នា បែកបាក់គ្នា ហើយទៅកកាយដីក្រោមបន្ទប់ដេកឪពុក បានយកថូកែវរបស់ខ្លួនមក; នៅក្នុងថូកែវកូនច្បងមានដី, ក្នុងថូកែវកូនទីពីរមានធ្យូង, ក្នុងថូកែវមានទម្រង់ដូចនាពនៃកូនទីបីមានដាក់ឆ្អឹង; ក្នុងថូកែវកូនទីបួនមានដាក់ចំបើង ។ កូនប្រុសទាំងបួននាក់ មិនយល់នូវបំណងរបស់បិតា ក៏បានចូលទៅសាកសួរបណ្ឌិតជាច្រើនអំពីរឿងនេះ តែគ្មានបណ្ឌិតណាម្នាក់អាចពន្យល់បំភ្លឺឱ្យជាក់ច្បាស់បានសោះឡើយ ។ ក្នុងរយៈវេលាជាច្រើនថ្ងៃ, ជនទាំងបួននាក់ក៏បិតនៅឯកឯងពីគ្នា មានចិត្តព្រួយបារម្ភជាខ្លាំង ។

មានកាលមួយថ្ងៃ អ្នកទាំងបួននាក់បានចូលទៅកាន់ក្រុមព្រះរាជទីប្រឹក្សានៃព្រះបាទវិក្រមាទិត្យ ហើយសាកសួរសមាជិកអមព្រះអង្គ តែព្រះរាជទីប្រឹក្សាទាំងនោះ មិនអាចពន្យល់ឱ្យដឹងច្បាស់លាស់ថាតើថូកែវនោះមានន័យយ៉ាងណាសោះឡើយ ។

មានព្រាហ្មណ៍ពីរនាក់នៅក្នុងនគរប្រតិស្ឋាន មានប្អូនស្រីម្នាក់មេម៉ាយ, នាងនោះមានរូបឆោមលោមពណ៌ស្រស់ប្រិមប្រិយ. នាងបានរួមសង្វាសជាមួយនឹងព្រះរាជបុត្រនៃស្ដេចនាគ ដែលយាងចេញអំពីបាតាល ។ នាងក៏មានផ្ទៃពោះ ។ ព្រាហ្មណ៍ទាំងពីរនាក់កាលបានឃើញប្អូនស្រីខ្លួនមានគភ៌ ក៏កើតមានសេចក្ដីខ្មាសគេ ទើបដកខ្លួន

ថយទៅនៅកន្ទុំមណ្ឌលមួយឆ្ងាយពីប្រទេស ។ ដល់ថ្ងៃក្រោយមកនាង

បានឆ្លងទន្លេ បានបុត្រប្រុសមួយសន្មតថា សាលវាហនៈ (Câlâvahana) ។

សាលវាហនៈ ឋិតនៅជាមួយមាតាឯគេហដ្ឋាននាយស្មូនឆ្នាំង ហើយ

បានពុះដំណឹងអំពីរឿងថ្នូកែវប្អូននោះ ក៏បានចូលទៅកាន់ទ្វីប្រីក្សាព្រះ

មហាក្សត្រិយ៍ឯនគរប្រតិស្ឋាន ពោលថា: "សូមអភ័យទោសព្រះរាជទី

ប្រឹក្សា ! ខ្ញុំនឹងពន្យល់បកអំពីន័យថ្មូកែវទាំងបួន" ។ កន្ទុំពេលនេះព្រះ

រាជទីប្រឹក្សាក៏បានសុំឲ្យព្រះអង្គម្ចាស់ពន្យល់; ព្រះអង្គម្ចាស់សាលវាហនៈ

ក៏ពោលថា "អ្នកដែលមានថ្មូកែវដាក់សុទ្ធតែដី ត្រូវបានគោគទ្រព្យខាង

សង្ហារិមៈនឹងអសង្ហារិមៈ ; អ្នកដែលមានថ្មូកែវដាក់សុទ្ធតែធ្យូង ត្រូវបាន

លោហធាតុទាំងប្រាំបី គឺ មាស ប្រាក់ ទង់ដែង សំរិទ្ធ ស្ពាន់

សំណ ដែក ; អ្នកដែលមានថ្មូកែវដាក់សុទ្ធតែឆ្អឹង ត្រូវបានដំរី សេះ

គោ ក្របី ពពែ ចៀម ទាសាទាសី គឺសត្វទ្វេបាទនិងចតុប្បាទ ;

អ្នកដែលមានថ្មូកែវពេញទៅដោយចំបើង ត្រូវបានសម្បត្តិខាងគ្រាប់ឈើ

គឺ ស្រូវ ល្ពៅ ស្រូវង តិណជាតិវ៉ៃស (Vesce) សណ្ដែកបាយ

ពពាយ ល្ង មូតាដ (Moutarde) ។ អ្នកទាំងបួននាក់ ដល់បាន

ឮព្រះអង្គម្ចាស់សាលវាហនៈកាត់សេចក្ដីដូច្នោះ ក៏សប្បាយចិត្តគ្រប់ៗគ្នា,

បានព្រមព្រៀងយកគ្រឿងមត៌កសព្វៗខ្លួនហើយ ក៏បានទទួលនូវសេចក្ដី

សុខជាកិយោគាគតទៅ ។

ព្រះបាទវិក្រមាទិត្យទ្រង់ព្រះសណ្ដាប់នូវមតិមហាជនចំពោះការ

កាត់សេចក្ដីខាងលើនេះ ទ្រង់ក៏ចាត់អមាត្យឲ្យទៅអញ្ជើញព្រះអង្គម្ចាស់

សាលវាហនៈឯនគរប្រតិស្ឋាន ។ តែព្រះអង្គម្ចាស់ស្តេចមិនបានយាងទៅតាមព្រះរាជតម្រាស់ទេ ទ្រង់មានព្រះបន្ទូលប្រាប់អមាត្យវិញថា "តើមានប្រយោជន៍អ្វីត្រង់ការចូលទៅគាល់ព្រះបាទវិក្រមាទិត្យ? បើទ្រង់ត្រូវការជួបនឹងយើង ម្តេចក៏ទ្រង់មិនស្តេចយាងមកកាន់ទីនេះ" ។ អមាត្យក៏វិលទៅក្រាបបង្គំទូលព្រះបាទវិក្រមាទិត្យ តាមបន្ទូលព្រះអង្គម្ចាស់សាលវាហនៈ ។ ព្រះបាទវិក្រមាទិត្យទ្រង់មានព្រះរាជហឫទ័យសង្ស័យពន់ពេកចំពោះបន្ទូលព្រះអង្គម្ចាស់ដែលនៅវ័យក្មេង ហើយទ្រង់អន់ព្រះរាជហឫទ័យ ទ្រង់ក៏ស្តេចយាងទៅដោយនាំទ័ព ៤ កងទៅកាន់នគរប្រតិស្ឋាន ។ ក្នុងពេលនោះព្រះអង្គម្ចាស់សាលវាហនៈ ទ្រង់មិនបានស្តេចទៅគាល់ព្រះបាទវិក្រមាទិត្យទេ ដោយទ្រង់ឥតរំភើបញាប់ញ័រសោះឡើយ ។ ព្រះបាទវិក្រមាទិត្យ ទ្រង់ព្រះក្រោធជាខ្លាំងក៏បានចាត់សេនាទាហានឲ្យទៅលោមព័ទ្ធនគរនោះ និងដំណាក់ព្រះអង្គម្ចាស់សាលវាហនៈ ។ ដល់ព្រះអង្គម្ចាស់ទ្រង់ទតទៅឃើញដំណាក់ទ្រង់ ដែលព្រះបាទវិក្រមាទិត្យទ្រង់ចាត់កងយោធាឲ្យមកលោមព័ទ្ធជុំវិញដូច្នោះ, ទ្រង់ក៏បានអធិដ្ឋានឫទ្ធានុភាពព្រះបិតាឲ្យបញ្ចូលជីវិតទៅក្នុងអត្តភាពដំរី, សេះ, ទាហានដែលធ្វើពីដីឥដ្ឋ ហើយទ្រង់មានបន្ទូលឲ្យចូលទៅតយុទ្ធ ។ ក្នុងរយៈវេលាជាច្រើនថ្ងៃ, កងទ័ពព្រះអង្គម្ចាស់សាលវាហនៈនឹងកងទ័ពព្រះបាទវិក្រមាទិត្យ ក៏តស៊ូគ្នាដោយក្បួនសង្គ្រាមប៉ុក ៗ ។ ទុកជាយ៉ាងណាក៏ដោយ ព្រះតេជានុភាពព្រះបាទវិក្រមាទិត្យមិនអាចផ្ចាញ់នូវកងទ័ពព្រះអង្គម្ចាស់សាលវាហនៈបានទេ ។

មានកាលមួយថ្ងៃ, ព្រះបិតានៃព្រះអង្គម្ចាស់សាលវាហនៈ, ព្រះរាជបុត្រស្ដេចកុជគ្គនាគ ដែលទ្រង់គង់នៅនគរបាតាល ទ្រង់ស្ដេចយាងមកកាន់ទីនោះនៅពេលព្រលប់ ហើយក៏ខាំកន្ទាហានព្រះបាទវិក្រមាទិត្យ ធ្វើឲ្យល្វីល្វើដោយនុសពុលនោះ, ហើយស្ដេចយាងវិលទៅកាន់នគរវិញ ។ ព្រះបាទវិក្រមាទិត្យ, ដល់ឃើញកន្ទាហានរបស់ព្រះអង្គល្វីល្វើដូច្នោះ, ទ្រង់បានសូត្រមន្តស្ដេចនាគរាជ "វាសុកី" ដើម្បីនឹងធ្វើឲ្យកន្ទាហានព្រះអង្គមានអានុភាពឡើងវិញ ដោយប្រោះទឹកអម្រឹត, មហារាជ "វាសុកី" ពេញព្រះរាជហឫទ័យទ្រង់បានព្រះរាជទានទូវទឹកអម្រឹតនោះទៅព្រះបាទវិក្រមាទិត្យ ហើយក៏កៀសព្រះអង្គបាត់ទៅ ។ ព្រះបាទវិក្រមាទិត្យ ទ្រង់បានទឹកអម្រឹតនោះ ក៏ស្ដេចយាងប្រញាប់ប្រញាល់ទៅជួយកន្ទ័តព្រះអង្គ ។ តែដល់ស្ដេចយាងបានពាក់កណ្ដាលផ្លូវ ស្រាប់តែមានបុគ្គលពីរនាក់ដែលព្រះអង្គម្ចាស់សាលវាហនៈទ្រង់បានបាត់មក, សូមមកសុំពីព្រះបាទវិក្រមាទិត្យ នូវទឹកអម្រឹតនោះ ។ ព្រះបាទវិក្រមាទិត្យទ្រង់បានសន្យាថា ទ្រង់ត្រូវតែព្រះរាជទានទូវរបស់ណាដែលគេសុំព្រះអង្គ ។ ព្រោះហេតុដូច្នេះ ដើម្បីកុំឲ្យក្បត់នូវកិច្ចសន្យានោះ, ទ្រង់ក៏បានព្រះរាជទានទូវទឹកអម្រឹតនោះទៅបុគ្គលពីរនាក់ ដែលសុំព្រះអង្គ ។ កិត្តិយសដ៏ពិតគឺមិនត្រូវប្រព្រឹត្តខុស នឹងពាក្យដែលពោល ។ មហារាជវិក្រមាទិត្យ កាលទ្រង់ធ្វើព្រះរាជដំណើរតែមួយព្រះអង្គឯងតាមផ្លូវបាទ ទ្រង់ព្រះតម្រិះដូចខាងលើ ។ ព្រះបាទវិក្រមាទិត្យ ទ្រង់ព្រះតម្រិះតទៅទៀតថា: ពេលណាមនុស្សខ្លួនកាត់សាគរគឺទុក្ខ

សោក ដែលលំបាកទឹងធ្ងន់ពេក ហើយបានធ្ងន់រូបដោយសារកម្លាំងគុណធម៌ ដែលបានមកពីការប្រព្រឹត្តនូវកិច្ចការជាកុសល, ពេលនោះគេនឹងឃើញអានុភាពរបស់សាស្ត្រ: ។

ក្នុងពេលនោះ ស្តេចនាគរ៉ាសូក៌ទ្រង់ស្តេចយាងពីនគរបាតាល បានបង្ហោរនូវភ្លៀងអម្រឹត ហើយធ្វើឲ្យពួកទាហានមហាពជវិក្រមាទិត្យ ដឹងខ្លួនភ្ញាក់ស្មារតីឡើង ហើយទ្រង់យាងវិលត្រឡប់ទៅវិញ ។ កងទាហានមហាពជវិក្រមាទិត្យ ដូចជាមនុស្សភ្ញាក់ពីនិទ្រា បានបញ្ចេញនូវសព្ទស្វរគឹកកងរំពងដូចធម្មតា ។ ព្រះបាទវិក្រមាទិត្យទ្រង់បានទតទៅឃើញកងទាហានបានដឹងស្មារតីគ្រប់ៗគ្នា, ទ្រង់ស្តេចយាងជាមួយពួកទាហាន វិលត្រឡប់ទៅកាន់ព្រះនគរវិញ ។

រូបទេពនិម្មិតទីម្ភៃបី ក្រាបបង្គំទូលព្រះមហាក្សត្រិយ៍ភោជៈថែមទៀតថា: បើទ្រង់មានព្រះរាជចរិយា ដូចព្រះបាទវិក្រមាទិត្យបែបនេះ, ទ្រង់អាចគង់នៅលើបល្ល័ង្កទិព្យនេះបាន ។

ព្រះបាទភោជៈទ្រង់ព្រះសណ្ដាប់នូវរឿងរ៉ាវ ដែលរូបទេពនិម្មិតទីម្ភៃបីថ្លែង ក៏ទ្រង់មិនបានទទួលនូវមុទ្ទាភិសេកក្នុងពេលនោះ ។

(មានត)

# រឿងសៅរ៍សោយ

## (សិរិសោរជាតក)

ព្រះមហាឧត្តមវិជ្ជា ផលញាណោ ប៊ុង-ប៉ម

អាចារ្យសាលាបាលីរងវត្តបទុមវតី ក្រុងភ្នំពេញ

រៀបរៀងតាមតម្រាយសាស្ត្រាស្លឹករឹត

តមកអំពីកម្ពុជសុរិយា លេខ ៩ ឆ្នាំ ១៩៥៥

---

សូមទោសអស់លោក-អ្នកអានទស្សនាវដ្ដីនេះ, ការអាក់ខានមិនបានចុះរឿងនេះជាប់ជាលំដាប់មកនោះ មកអំពីលោកអ្នករៀបរៀងរឿងនេះ ត្រូវនិមន្តទៅបន្តវិជ្ជាឯប្រទេសថៃ ហើយលោកមិនបានបញ្ជូនរឿងខាងចុងនេះមកពុទ្ធសាសនបណ្ឌិត្យ ឲ្យទាន់ពេលវេលាដែលត្រូវចុះផ្សាយ ។

---

គួរតែសេនីយ　អមាត្យមន្ត្រីគ្រប់ប្រាណ
បង្គំអវតាណ(១)　ទើបបានជាការគប្បី ។
បើទូលបង្គំ　ថ្វាត់ថ្វាយប្រណម្យនរបតី
ក៏គ្មានសិរី　មង្គលសួស្តីកើតបាន ។
មានតែរឹងរឹត　ធ្វើឲ្យបពិត្រក្សត្រក្សាន្ត
អាប់ឱនខ្លួនប្រាណ　ព្រោះបានអ្នកទោសគារវៈ ។
ផ្សិតហេតុព្រះអង្គ　មានយសខ្ពស់ខ្ពង់វង្សស័ក្តិ
សមតែសេវក　មន្ត្រីកវីព្រាហ្មណា ។
ដែលឥតៈទោសទុក្ខ　ផែកម្ចាំគុកទុក្ខា

---

១ អវតារ ។

ថ្វាយថ្វាត់ក្សត្រា ទើបជាមង្គលជោគជ័យ ។
ពេលនោះចក្រា បរមក្សត្រាកូវ័យ
នឹកគុណព្រះទ័យ មមៃឥតស្តីឡើយហោង ។
ថាអ្នកនេះណា អង់អាចប្រាជ្ញាកន្ទួង
មិនជាសម្បផង ទំនងជាពង្សក្សត្រា ។
ទាំងរូបភាពអង្គ ក៏ស្រស់ទ្រើសទ្រង់ឆាយា
ត្រៀវត្រាស់ណាស់ណា បែងបេះដោះសាសេចក្តី ។
ចិន្តាជាស្រេច ទើបស្តេចបែរគេចស្រដី
សួរស្ងៅទៅខ្ញី ថា រឺ ! មឹងមកពីណា ? ។
ក៏បានជាមឹង ធ្វើបុករង្គឹងខ្លាំងក្លា
ចរចេសចេស្តា អំណាចអាជ្ញាអញនៃ ។
ហ៊ានចុះឆ្មុតទឹក គ្មានកាំងក្លាំងក្លឹកទឹកភ័យ
កុងកាងម៉ាសម័យ ប្រដាប់សម្រាប់នត្តា ។
បូរអាសាសត្រូវ និយាយប្រាយប្រាប់ឆាប់ពី
មឹងកូនអ្នកណា បានជាហ៊ានក្លាឥតបី ។
ចមកពតបថា ថ្ងៃមួយនោះណាទាសី
នាំគ្នាឃ្មាតខ្ញី បីចៅចក្រីយកទៅ ។
ដាក់ផ្តុតបោលស្មោះ មិនថ្វាយទឹកដោះឲ្យចៅ
ហើយពរចេញទៅ ពួនទៅក្នុងទីដៃ ។
ព្រះចៅព្រះអង្គ ពុំបានសោយស្រង់ឡើយនៃ

ឃ្លានស្រែកពេកក្រៃ ក្បែតថ្ងៃស្រែកយំពុំស្បើយ ។
ឯពួកស្រីស្ទំ ពាំទំសម្ងំកន្ទើយ
ពុំអើពើឡើយ បណ្ដោយឲ្យយំឯកា ។
ខ្ញុំយល់ហោះហោង ក៏ទៅត្រកងនត្តា
នាំឃ្លាតយាត្រា តម្រង់ទៅត្រង់អាងវៃ ។
ដាក់ចៅសោកា ឲ្យស្រង់ធាកនោះនៃ
កុមារអេរក្រៃ ក៏ស្រង់អស់អង្គកាយ ។
ទទះលោតលេង កញ្ច្រោកកញ្ច្រេងសប្បាយ
ទឹកសោតខ្លាត់ខ្លាយ មកត្រូវទូវកាយខ្ញុំខ្ញី ។
ខ្ញុំទូលហេតុការណ៍ ដោយស្មោះអស់អាថ៌សេចក្ដី
សូមព្រះចក្រី ទ្រង់ជ្រាប់សេចក្ដីនេះផង ។

ពេលនោះកូវទ័យ កិន្នរត្តក្បែតថ្ងៃប្រាសប្រួន
ទុក្ខាសោសង បន្ទូលរំងស្ងួនទៅថា ។
អើ! ក្មេងទាំងនេះ លើកលុបឈប់ស្ទះសិនណ៎
យើងសួរមឹងថា គោត្រនាមនោះណាឈ្មោះអ្វី?
មឹងកូនអ្នកណា ចូលមកផ្ដោយើងខ្ញី
អស្សុរេះអស់ក្ដី ឥតបីគោរពយើងឡើយ ។
មឹងហានរំប្រាណ ទឹងកូនកល្យាណត្រាណត្រើយ
បុត្រយើងហើយ ព្រងើយកន្ទើយសំងំ ។
យង់ឃ្នងផងផ្ដួ ពុំចេះដាក់ត្លួគួរសម

ពុំថ្វាយបង្គំ　　នូវយើងជាធំឡើយណា ៗ<br>
　　ក្សត្រថៃសិសៅរ៍　　ស្តាប់ហើយឆ្លើយទៅវិញថា<br>
ខ្ញុំទូលក្សត្រា　　តែនាមសាត្វាប៉ុណ្ណោះ ៗ<br>
ឯគោត្រត្រកូល　　ខ្ញុំពុំព្រមទូលឡើយសោះ<br>
តែខ្ញុំចំពោះ　　នាមឈ្មោះសិសៅរ៍រាជា ៗ<br>
ធ្លាប់រុងរឿងក្តាត់　　សោយរាជសម្បត្តិនៅនា<br>
អនន្តភាព　　ទើបតែឃ្លាតឃ្លាមករហោង ៗ<br>
　　កិន្នរត្តក្សត្រថៃ　　ព្រះអង្គទ្រង់ភ័យកន្ទង<br>
ញាប់ដៃជើងផង　　ខ្ទបខ្ជាបអំណាចបារមី ៗ<br>
ចុះចាកទីនាំង　　ព្រះរាជបល្ល័ង្កមកខ្ញី<br>
ឱនក្រាបសិរសី　　ទៀបបាទក្សត្រថៃហើយណា ៗ<br>
លើកដៃប្រណម្យ　　ថ្វាត់ថ្វាយបង្គំទូលថា<br>
បពិត្រក្សត្រា　　ជាមហាក្សត្រក្លាឫទ្ធិក្រៃ ៗ<br>
ខ្លួនខ្ញុំពុំបាន　　ដឹងជាក្សត្រក្សាន្តឡើយនៃ<br>
សូមទ្រង់អភ័យ　　សន្តោសទោសតែរ៍ផងក៏ ៗ<br>
ស្មានជាព្រះអង្គ　　ពុំមានពូជពង្សវង្សា<br>
ច្នេះសូមក្សត្រា　　មេត្តាសន្តោសប្រោសប្រាណ ៗ<br>
ត្រាស់ចប់ចមទៅ　　អញ្ជើញសិសៅរ៍អរគោណ (១)<br>
គង់បល្ល័ង្កបាន　　ឯតួក្សត្រក្សាន្តឯងណា ៗ

---

១ អរគារ ។

ទ្រង់គង់ទំពាប    តាមថ្នាក់សភាពអាត្មា
ស្រែបស្តេចសួរថា    បពិត្រក្សត្រាប្បាស់ប្បន ។
ម្តេចទ្រង់លះកាត់    បោះបង់សម្បត្តិមកហោង
ដើរដោសដោយជង    ផ្ដួលផ្ញើក្សត្រៃពេងកា ។
ផ្ញៀតផ្ញើកគោកយ៉ាក    លំបិនលំបាកអាត្មា
សូមទ្រង់មេត្តា    ប្រាប់ហេតុនោះណាផងនៃ ។
ព្រះពោធិសត្វ    អធិប្បាយថ្វាយថ្វាត់វៃ ។
ថាខ្ញុំនេះនៃ    មិនជឿសំដីហោព ។
ស្តេចត្រាស់អស់គល    ទូលពិតឥតសល់ឡើយណា
រឿងដែលក្សត្រា    ទុក្ខាសន្ធំពុំស្បើយ ។
ដល់ពេលនេះខ្ញុំ    បានជប់ប្រាប់ខែហើយ
ឥតបានស្រាន្តស្បើយ    ឧពល្ហៃល្ហើយមួយថ្ងៃ ។
គិនវត្តនោះណា    ស្តាប់មហាក្សត្រាថ្វាថ្ងៃ
សង្វេគពេកក្រៃ    ក្តួចគិតអាណិតក្សត្រា ។
ព្រះទ័យអន់អួល    ទន្ទឹះខ្សឹកខ្សួលឧព
ស្រក់ទឹកនេត្រា    ពុំចេញពាចាស្រដី ។
ស្រែបស្តេចត្រាស់ថា    ហៃអស់សេនាមន្ត្រី
ចូរឆាប់ៗខ្ញុំ    ចាត់ការសង់កដពេងរម្យ ។
រៀបចំប្រាសាទ    ប្រសើរស្អាតស្អាតឧត្តម
ពួកគ្រែបៀមចំ    ទទួលបរម៉ុកជា ។

ទាំងត្បូតទ្រ្តី  ស្រៃឡ្យខ្ទុយបុរមនា
ភ្លេងចាមភ្លេងជ្វា  គឹកកងរំពងខ្ទាំងក្ដាត់ ៗ
រៀបស្រេចស្ដេចតាំង  ឲ្យយកក្លស់ប៉ាំងពោធិសត្វ
ទីងនាងសុទត្ត  ទេវីវរ័តនជាយា ៗ
ពលរេហ៍ហែហុំ  ស្នូរភ្លេងរងំរមនា
មន្ត្រីយោធា  ដង្ហែពជាអវិតាណ (១) ៗ
នីងនាងសុទត្ត  សោយរាជសម្បត្តិវុឌ្ឍឋាន
អភិសេកក្សត្រក្សាន្ត  លុះបាន ៧ ថ្ងៃណា ៗ
គ្រឿងកកុធកណ្ឋ  គឺមកុដសុវណ្ណ, ខាន់ថ្លា,
ស្វេតច្ឆត្រសោភណា,  ទីងមហាសុពណ៌បាទុករ័តន៍,
វាលវីជនី  សម្រាប់នាទីមហាក្សត្រ
មន្ត្រីនាំថ្វាត់  ថ្វាយក្សត្រក្រូវ័យថ្ងៃថ្លា ៗ
បច់កិច្ចស្រេចថ្វាត់  ព្រះបាទកិន្នរត្តក្សត្រា
ត្រាស់បើសេនា  ឲ្យឃ្លាតយាត្រាទៅទ្វី ៗ
ស្វែងរកប្រញាប់  ប្រដាប់សម្រាប់បក្រី
ដែលមនុស្សអប្រិយ  ប្រញីជណ្ដើមយកទៅ ៗ
សេនាបតី  ស្ដាប់ហើយថយខ្ទីពុំនៅ
ត្រឡប់សំដៅ  ទៅពីផ្ដោះទៅបាត់បែង ៗ
បញ្ជូនភ្នាក់ងារ  ទីងបរិវារខ្នះខ្នែង

១ អវិតារ ៗ

រហ័សស្ទុះស្ទួន ខ្ទួសពួកខ្ទៃទិសា ។
ឯព្រះសិរសៅរ៍ ផុតគ្រោះអស់ក្តៅហើយណា
ប្រដាប់ប្រដា ដែលប្រែក្រឡានោះនៃ ។
ក៏ប្រែក្រឡា ដូចដើមធម្មតាវៃ ។
អ្នកយកទីទៃ ឃើញពិតកិតភ័យមហិមា ។
ពុំហ៊ានលាក់ទុក ខ្លាចតទៅមុខវេទនា
ទើបម្ចីលីលា ចេញចាកគ្រឹហាជាមួន ។
នាំគ្រឿងទាំងនោះ ប្រឹងថ្វាយបំពោះបព្វាស់ប្បន
ដើរដោយដុងដង បំណាងតម្រង់បុរី ។
ក៏មកចួបគ្នា នៅនាមាគ៌ាមួយខ្វី
ចួនជាសេនីយ ដែលលោកមន្ត្រីប្រើទៅ ។
ឃើញជាក់នេត្រា សួរដឹងហើយណាពុំទៅ
បង់នាំយកទៅ សំដៅលំនៅកំនងជ័យ ។
ព្រះបាទកិន្នរត្ត ឃើញព្រមបមក្សត្រគ្រាជក្រែ
ទ្រង់ជាក់ពិន័យ ម្នាក់ៗ វៃៗមួយពាន់ ។
តែពោធិសត្វ សិរសៅរ៍វរ័តន៍ឃាត់ទាន់
ទ្រង់ត្រាស់ស្រួពន់ រំពាន់សំដែងថ្លែងថា ។
បពិត្រព្រះអង្គ សូមទ្រង់សន្តោសទោសា
កុំជាក់អាជ្ញា ដល់គ្នាឡើយណាព្រះអង្គ ។
ដែលទូលបង្គំ ជួបមុខទុក្ខធំពុំបង់

វេទនាយូរលង់ សូមទ្រង់ជាបកុងសន្តាន ។
ថាព្រោះអំពើ ដែលខ្ញុំនេះធ្វើមកថ្កាន
ទើបខ្ញុំត្រូវបាន ទុក្ខនឹងពុំក្សាន្តដល់ម្តង ។
ប្ដេះសូមគម្តែង ទ្រង់ប្រោសដោះលែងទៅហោង
កុំឃុំកុំចង អស់អ្នកស្រែផងគ្រប់គ្នា ។
ត្រាស់បប់នរបតី ប្រើសង្ឃការីលីលា
ទៅអាកធនា និមន្តសង្ឃជាប្រញាប់ ។
ទីងនេនជំទង់ ពីរត្តដែលទ្រង់បានធ្លាប់
ពីងពាក់ប្រថាប់ មកជាឆាប់ ៗ គ្រប់អង្គ ។
អមាត្យម្ចីម្ចា នុនកបក្រោះណាត្រាប់ត្រង់
ភ្លោះចំតម្រង់ ទៅនិមន្តសង្ឃសារិកា ។
នាំគ្នារបល់ សំដៅទៅដល់ហើយណា
វន្ទាបេក ទូលក្តីប្រថ្នានោះហោង ។
កាលណោះអស់សង្ឃ និមន្តគ្រប់អង្គជាម្តង
តាំងនេននោះផង ភ្លោះផ្លូងតម្រង់សីមា ។
លុះបានទៅដល់ យង់យល់មណ្ឌលក្សត្រា
ទើបរៀបអាត្មា ម្ចីម្ចាយាត្រាគ្រប់ប្រាណ ។
ព្រះបាទក្សត្រថ្ងៃ ទ្រង់ត្រេកពេកក្រៃប្រមាណ
នមស្ការស្រេចបាន ក្សត្រក្សាន្តទ្រង់បានត្រាស់វៃ ។
ឲ្យរៀបចង្ហាន់ ប្រគេនលោកឆាន់ទីទៃ

ស្រេចថ្វាត់ក្រែតថ្ងៃ ដេស្ទជ័យថ្វាយត្រៃចីវរ ៗ
ដ៏ល្អបញ្ចង់ ព្រះសង្ឃគ្រប់អង្គត្រេកអរ
ទទួលចីវរ សោមនស្សស្មោះសរអរក្តាត់ ៗ
ហើយសព្វនរបតី ទ្រង់ប្រើមន្ត្រីឲ្យបាត់
ជួសជុលសាងវត្ត ដែលទ្រង់ធ្លាប់គង់នោះឋាន ៗ
សាងកុដិ, សាលា, វិហារ, បដិមា ស្អាតស្អាន
ស្រេចថ្វាត់ក្រែតក្សាន្ត ទ្រង់បានថ្វាយសង្ឃគង់នៅ ៗ
បំរុងរក្សា ឲ្យបានសុខាតទៅ
ហើយព្រះបមពៅ តម្រូវឲ្យនេនៈនោះណា ៗ
លាសិក្ខមកឋាន ទ្រង់តាំងកុងឋានបុត្រា
ស្រឡាញ់រក្សា ដូចជាឱរសព្រះអង្គ ៗ
យូរទៅបមពៅ ហ្មងសៅនឹកទៅស្រុកទ្រង់
នឹកទីធ្លាប់គង់ នឹកបត្តរង្គសេនា ៗ
នឹកជនប្រុស-ស្រី នាហ្មឺនមន្ត្រីសេវកា
នឹកដល់កល្យាណ៍ អនន្តកនិដ្ឋាក្សាប្រិយ ៗ
ឱស្រស់មណី ! អនន្តទេវីពិសី
បងចាកបុរី ឃ្លាតស្រីក្សត្រីពុំងា ៗ
ម៉្ងះសមតោមត្មៅ នាងសៅហ្មងនៅកំព្រា
ដ្បិតបងឃ្លាតឃ្លា ឃ្លាតខ្លួនស្ងួនក្សាយូរហើយ ៗ
ម៉្ងះឆ្មើមថ្មើមថ្ងៃ សង្រែងសារែងឥតស្បើយ

ពុំដឹងរឿងឡើយ ថាបងបានស្បើយល្ហើយទុក្ខ ៗ
រូបរស់ដីរ៉ា គ្រងពងរង្សាជាសុខ
ម៉្លេះសមទ្រលុក កណ្ដែនកណ្ដុកទុក្ខ ៗ
គិតថ្វាត់ក្សត្រា ទើបប្រើសេនាមន្ត្រី
នាំសារបេក្រី ទៅថ្វាយមហេសីឯនាយ ៗ
មន្ត្រីតូចធំ ក្រាបថ្វាយបង្គំរៀនរាយ
នាំគ្នាដជាយ ទៅនគរនាយនោះខ្ញី ៗ
លុះបានទៅដល់ យន់យល់និរមលក្សត្រី
ទើបនុនសិរសី បង្គំស្រស់ស្រីធីតា ៗ
ថ្វាយសារបេក្រី ហើយទូលក្សត្រីថ្ងៃថា
បពិត្រធីតា ដ្បិតមហាក្សត្រាច្បាស់ច្បួន ៗ
ជាព្រះស្វាមី នៃម្ចាស់ក្សត្រីនោះហោង
ប្រើយើងខ្ញុំផង ឲ្យចូលមកគាល់ក្សត្រី ៗ
មន្ត្រីស្ដីការ ទូលឆ្ពោះអស់អាថ៌សេចក្ដី
ក្សិណានោះស្រស់ស្រី ព្រះទ័យអរក្រៃកន្ទួន ៗ
ទ្រង់ទតកដសារ ទើបប្រាប់រាំរពលផង
ឲ្យរៀបចាប់ហោង គ្រប់កងយោធាជាចាប់ ៗ
សេនាបតី ទូលលាក្សត្រីក្រឡាប់
រៀបពលប្រញាប់ តែងគ្រឿងប្រដាប់គ្រប់ប្រាណ ៗ
គឺពលដំរី រែងឫទ្ធិតតបីប្រៀបបាន

ណាន់ណែនដែនដាន ប្រមាណប្រាំមួយហ្មឺននាក់ ។
ពលសេះពេញពាស ពាក់មួកផ្ដៅមាសជៀនដាក់
គ្រោះស្បែកក៏ពាក់ ប្រាំមួយហ្មឺននាក់ដូចគ្នា ។
តមកពលរថ ប្រាំមួយហ្មឺនគត់ឥតកា
នាំគ្នាមម្មា លីលាឡើងលើរថា ។
រថនោះសឹងពាស ដោយស្បែករមាសស្បែកខ្លា
ចន្ទោលនោះណា ប្រដាប់ប្រដាទង់ជាយ ។
ពួកពលថ្មើរជើង ប្រជុំគ្នាឡើងរៀងរាយ
ពុំមានភយមាយ តីពលដល់នាយបញ្ជា ។
សុទ្ធសឹងហៅហាន ចំណានមុះមុតយុទ្ធនា
អាវុធសោភា កាន់អាវុធគ្រប់ដៃ ។
ពួកពលទាំង ៤ ជួបជុំក្រមក្សួនហើយនៃ
អមាត្យធ្មេតវៃ ទៅទូលស្រីថ្ងៃវិញថា ។
បពិត្រក្សត្រ ! មន្ត្រីសេនិយសេនា
ចាត់រៀបត្រៀបត្រា តើទ្រង់ប្រាថ្នាការអ្វី ? ។
ព្រះនាងបញ្ជា ថាបួរនាំគ្នាឃ្លាតខ្ចី
ទៅអចលបុរី ដើម្បីទទួលពជា ។
ដង្ហែតអីព្រះអគ្គ ស្ដេចទ្រង់នៅគង់ជន្មា
សំណាក់នៅនា អចលភាពនោះឯង ។

(មានត)

# សកម្មភាព នៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

## បរិយាយពីរបាំរបស់ខ្មែរ

លោក ប៉ាប-ពិន រៀបរៀង

---

នៅចុងឆ្នាំ ១៩៥៣ ខ្ញុំបានបរិយាយតាងនាមក្រុមជំនុំទំនៀមទម្លាប់ខ្មែរម្តងហើយ អំពីនាដសិល្បៈ (សិល្បៈខាងរាំ), គីតសិល្បៈ (សិល្បៈខាងច្រៀង), តូរ្យាង្គសិល្បៈ (សិល្បៈខាងតូរ្យតន្ត្រី) និងអំពីដើមកំណើតល្ខោនជារបាំរបស់ខ្មែរ ដោយបានបញ្ជាក់ថា ល្ខោនខ្មែរកើតមានឡើង តាំងពីរជ្ជកាលព្រះបាទជ័យវរ្ម័នទី ២ គឺព្រះកេតុមាលា ជាមហាក្សត្រខ្មែរសោយរាជ្យដំបូងបំផុត នៅអង្គរ រវាងឆ្នាំ ៨០២ ដល់ ៨៦៩, តែនៅសល់របាំខ្មែរជាច្រើនទៀតដែលពុំទាន់បានបរិយាយ ។

ក្នុងចំណោមរបាំដែលសល់នោះ ខ្ញុំសូមបរិយាយវេលានេះអំពីល្បែង ៥ យ៉ាង គឺ ១- ល្ខោនខោល, ២- ល្ខោនយន្ត, ៣- ណាំងស្បែក និងណាំងទ្រលុង ៤- កន្ទ្រៃ ៥- រាំស្នែងទន្សោង ដើម្បីសំដែងនូវឧត្តមគតិនៃរបាំទាំងនេះ ដែលជាអារ្យធម៌ជាគ្រឿងសំគាល់ និងជាក្តែកប្រមុះ របស់ខេមរជាតិ ហើយដែលជាកស្តុតាងអាចបង្ហាញសកលលោកឲ្យឃើញថា ជាតិខ្មែរ មិនមែនជាជាតិព្រៃផ្សៃ ទាំងមិនមែនជាជាតិទើបនឹងកើតថ្មីទេ គឺប្រាកដជាជាតិចាស់បុរាណមានអារ្យធម៌ជាមរតករបស់ខ្លួន ដោយមាននាដសិល្បៈជាគ្រឹះស្ថានសិល្បៈរបស់ជាតិចម្រើនដល់កំពូលបំផុត តាំងពីព្រេងមកហើយ ។

ប្រាំ ៥ យ៉ាងនេះ សព្វថ្ងៃរបាំខ្លះសូន្យរូបអស់រលីងទៅហើយ នៅសល់តែឈ្មោះ បើមិនកត់ត្រាទុកទេ តទៅមុខនឹងសូន្យទាំងឈ្មោះទៅទៀតពុំខាន, ហេតុដូច្នេះ បានជាក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ស្រាវជ្រាវរូបរួមកត់ត្រារក្សាទុកទាំងរបាំដែលបាត់បង់ ទាំងរបាំដែលនៅមានសព្វថ្ងៃជាឯកសារសម្រាប់ប្រទេសខ្មែរ ដូចរៀបរាប់ដោយសង្ខេបតទៅនេះ :

១— ល្ខោនខោល: ជាមហោស្រពព្រះរាជទ្រព្យសម្រាប់លេងក្នុងព្រះរាជពិធីផ្សេង ៗ មានព្រះរាជពិធីតាំងតុចម្រើនព្រះជន្មជាដើម, ល្ខោននេះបានជាហៅថាល្ខោនខោល ព្រោះជាល្ខោនមានតួអ្នករបាំសុទ្ធតែប្រុស តាមគន្ថីបញ្ជីនៃព្រះបរមរាជវាំងថា យ៉ាងច្រើនបំផុតមានដល់ ៦៥ នាក់ គឺ ៤ នាក់ជាមេល្ខោន, ២ នាក់ជាអ្នកពោល, ៥ នាក់ជាគ្រូល្ខោន, ៨ នាក់ជាអ្នកភ្លេង, ៥ នាក់ជានាយរោង, ២០ នាក់ជាស្វា, ១៥ នាក់ជាយក្ស, ៦ នាក់ជាត្លុក, រួមជា ៦៥ នាក់ ។

ល្ខោនវង់នេះ ឥតមានលេងរឿងដទៃក្រៅរឿងរាមកេរ្តិ៍ទេ, ខាងភ្លេងទៀតក៏ប្រើតែភ្លេងពិណពាទ្យមួយយ៉ាង ។ ឯគ្រឿងប្រដាប់សម្រាប់លេងមានច្រើនបែប ខាងពួកមុខ មានមុខយក្ស មុខស្វា ជាដើម, ខាងពួកមកុដ មានមកុដព្រះរាម មកុដព្រះលក្ស្មណ៍ មកុដព្រះនាងសីតា ជាដើម សព្វគ្រប់តាមរឿងរាមកេរ្តិ៍ ។

សព្វថ្ងៃនៅប្រទេសកម្ពុជាយើង ទីដែលមានក្រុមល្ខោននេះ គឺនៅឃុំពាមឧកញ៉ាអុង ស្រុកល្វាឯម ខេត្តកណ្ដាល កាលបើរាជការត្រូវការលេងក្នុងព្រះរាជពិធីអ្វីតែងហៅក្រុមល្ខោននេះឲ្យមកលេងនៅមុខ

ព្រះបរមរាជវាំង ៗ វេលាលេងគេធ្វើរោងមួយធំខ្ពស់ដើម្បីឲ្យអ្នកមើលឃើញច្បាស់គ្រប់គ្នា ៗ

ក្រុមល្ខោននេះ ជាល្ខោនគ ព្រោះពួកអ្នកកំទាំងប៉ុន្មានមិននិយាយរឿងខ្លួនឯងទេ ឲ្យក្បាច់កំនិយាយជួស គឺពួកអ្នកកំគ្រាន់តែកំបាក់ក្បាច់តម្រូវទៅតាមរឿង បង្ហាញអ្នកមើលឲ្យយល់តាមដំណើររឿងរបស់ខ្លួនប៉ុណ្ណោះ មានរូបអ្នកពោលដោយឡែកសម្រាប់តែពោលទៅតាមរឿងតាមថ្នាក់ ឲ្យអ្នកមើលស្តាប់ដឹងរឿងបាន មិនដូចល្ខោនទំនើបដែលពួកអ្នកកំគេកំផងគេនិយាយរឿងរបស់គេផ្ទាល់ខ្លួនផងនោះឡើយ ៗ ល្ខោនខោលជាមហាស្រពបុរាណសម្រាប់ជាតិរបស់ខ្មែរ មានលំនាំស្រដៀងគ្នា នឹងល្ខោនបុរាណរបស់ឥណ្ឌា ដែលគេរក្សាទុកជាមហាស្រពសម្រាប់ជាតិរបស់គេនោះដែរ ៗ យើងពុំអាចដឹងប្រវត្តិសាស្ត្រល្ខោនខោលច្បាស់លាស់ទេ តែយើងអាចសន្និដ្ឋានថា ប្រហែលជាកើតមានឡើងក្នុងសតវត្សជាមួយគ្នានឹងល្ខោនធម្មតា ដែលយើងបានស្រាវជ្រាវបានពោលហើយពីខាងដើមថា "កើតមានឡើងតាំងពីរជ្ជកាលព្រះកេតុមាលា ជាព្រះមហាក្សត្រខ្មែរដំបូងបំផុតនៅអង្គរ រវាងគ្រិស្តសករាជ ៨០២ ដល់ ៨៦៩" នោះឯង ៗ ខ្មែរយើងគួររាប់អានមហាស្រពបុរាណរបស់យើង គួរសិក្សា គួរទស្សនា គួររក្សាទុកឲ្យឋិតថេរជាសម្បត្តិរបស់ខ្មែរយើង តទៅអនាគត ទាំងគួររៀបចំចំពោះរបៀបការប្តូរក្បាច់ណាដែលមិនល្អឲ្យល្អ ដែលមិនស្វាហាប់ឲ្យស្វាហាប់ឡើង ដើម្បីដាក់ទុកសម្រាប់បង្ហាញសកលលោកឲ្យឃើញស្នាដៃនាដសិល្បៈខ្មែរ ឲ្យសមតាម

ប្រវត្តិសាស្ត្រដែលសកលលោកបានដឹងថាខ្មែរធ្លាប់មាននាដសិល្បៈយ៉ាង ជំនាញតាំងពីសម័យអង្គររហូតមក ។

២.— ល្ខោនយន្ត : របាំនេះ បានជាហៅថា "ល្ខោនយន្ត" ពីព្រោះគេយកឈើស្រាល ១ មានល្អសជាដើមមកឆ្លាក់ជារូបមនុស្ស យក្ស សត្វ ប៉ុន ៗ កំភួនដៃ លាបថ្នាំពណ៌ធ្វើជារូបតំណាងរឿង សម្រាប់ទាញខ្សែយន្តលេងតាមរឿង ជាមហោស្រពព្រះរាជទ្រព្យសម្រាប់លេងក្នុងព្រះរាជពិធីផ្សេង ៗ មានព្រះរាជពិធីរាជាភិសេកជាដើម មានពួកអ្នករបាំសុទ្ធតែប្រុសដូចល្ខោនខោល ប្រមាណជា ១០ នាក់ អ្នកខ្លះជាអ្នកកាន់រូបតួឯក អ្នកខ្លះកាន់រូបនាង អ្នកខ្លះកាន់រូបនាយរោង អ្នកខ្លះកាន់រូបយក្សជាដើម ផ្លាស់គ្នាតាមរឿង ។ ល្ខោនយន្តលេងក្នុងពិណពាទ្យដូចល្ខោនខោលដែរ តែល្ខោនយន្តមិនលេងរឿងរាមកេរ្តិ៍ជារឿងធំទេ, លេងតែរឿងតូច ១ ដូចរឿងព្រះជិនវង្ស រឿងស័ង្ខសិល្បជ័យជាដើម ។ វេលាលេងគេធ្វើរោងមួយធំ ហើយខាងក្នុងរោងនោះ គេបាំងវាំងឈើឬវាំងក្តល់ មានកំពស់ត្រឹមក្បាលដែលធ្វើអ្នកមើលឲ្យមើលពីក្រៅទៅមិនឃើញមនុស្សអ្នកកាន់រូបឃើញតែរូបផ្សេង ១ ដែលពួកអ្នករបាំនៅខាងក្នុងគេទាញខ្សែយន្តឲ្យបាក់ក្បាច់យ៉ាងណា ១ តាមត្រូវការ ។ ល្ខោននេះក៏ជាល្ខោនគដូចល្ខោនខោលដែរ តែល្ខោនខោលអ្នកកាំដោយខ្សែក អ្នកពោលដោយខ្សែក, ឯល្ខោនយន្តអ្នកទាញខ្សែយន្តរូបណាពោលរឿងរូបនោះខ្លួនឯង ។ ល្ខោននេះជារបាំបុរាណរបស់ខ្មែរដែលមាន

គ្រឿងប្រដាប់លេង និងដំណើរលេងប្រហែលគ្នានឹងហ៊ីបុកណារបស់ចិន ដែលយើងធ្លាប់ឃើញគេមកលេងនៅប្រទេសយើង ។

អំពីបុកណាមានលេងទាំងល្ខោនខោលទាំងល្ខោនយន្ត តែគេឈប់លេងល្ខោនយន្តនៅចុងរជ្ជកាលព្រះករុណាខត្តិយគោដ្ឋ, ឯល្ខោនខោលនៅលេងរហូតដល់សព្វថ្ងៃ ។

៣– ណាំងស្បែក និង ណាំងទ្រលុង: ពាក្យថា "ណាំង" ក្នុងឈ្មោះរបាំនេះជាពាក្យសៀម ព្រោះគេហៅតាមសម័យដែលខ្មែរ ហើយនិងសៀមមាននាដសិល្បៈទាក់ទងគ្នា, បើហៅតាមសំឡេងខ្មែរថា "របាំស្បែក" តែក្នុងទីនេះ សូមទុកតាមសំឡេងដែលអ្នកស្រុកធ្លាប់ហៅមកហើយ ។ របាំនេះជារបាំព្រះរាជទ្រព្យសម្រាប់លេងក្នុងព្រះរាជពិធីនានា មានព្រះរាជពិធីតាំងតុចម្រើនព្រះជន្មវស្សាព្រះករុណាជាអម្ចាស់ជីវិតលើត្បូងជាដើមយូរអង្វែងច្រើនរជ្ជកាលមកហើយ, រជ្ជកាលមុន ៗ មានលេងទាំងណាំងស្បែកទាំងណាំងទ្រលុង ដល់មករជ្ជកាលព្រះករុណាព្រះបាទសម្ដេចព្រះនរោត្តម - សីហនុ ទ្រង់ឲ្យផ្អាកលេងណាំងស្បែក ដើម្បីជួសជុលរូបដែលខូចឲ្យល្អសិនសឹមលេងឡើងវិញ ទ្រង់ឲ្យទុកតែណាំងទ្រលុងរហូតមកដល់សព្វថ្ងៃ ។

ណាំងស្បែក ហើយនិងណាំងទ្រលុង មានគ្រឿងប្រដាប់លេងនិងរបៀបលេងប្រហែលគ្នា គឺប្រដាប់លេងគេយកស្បែកគោឬក្របីមកដាប់ទម្លុះជាក្បាច់ជារូបតំណាងតួផ្សេង ៗ លាបម្រ័ក្សណ៍ខ្មៅ ៗ ហើយគេយកមកលេងតាមរឿងដែលគេត្រូវការ មានរូបព្រះរាម ព្រះលក្ស្មណ៍

ព្រះនាងសិតា ហនុមាន ឬរូបព្រះជិនវង្ស ព្រះនាងបទុមសុរិយា ព្រាហ្មណ៍កេសរជាដើម ថ្វែកតែខាងណាំងស្បែកគេច្រើរូបធំ ៗ មួយ ៗ ប៉ុនមនុស្សក្មេងដំទង់ ១ ផ្ទាំងមានរូប ១ ក៏មាន រូបច្រើនជាផ្ទាំងធំ ទំហំ ១ ព្យាមក៏មាន, ខាងណាំងទ្រលុងគេច្រើរូបតូចៗ មានទំហំតែត្រឹម ៤ ឬ ៥ ធ្នាប់ កំពស់ ១ ចំអាមប៉ុណ្ណោះ; មួយទៀតខាងណាំងស្បែកគេលេងតែរឿងធំ គឺរឿងរាមកេរ្តិ៍, ខាងណាំងទ្រលុងគេលេងតែរឿងតូចៗ គឺរឿងព្រះជិនវង្ស រឿងស័ង្ខសិល្បជ័យ និងរឿងព្រះចន្ទគោរព ៗ ណាំងស្បែកនិងណាំងទ្រលុង មានតួអ្នករបាំសុទ្ធតែប្រុសៗ ដូចគ្នា, ណាំងស្បែកមានគ្នា ៣០ នាក់ សឹងមានមុខងារជាអ្នកបណ្ដាំង ( អ្នកបណ្ដើរស្បែក ) តែរៀងខ្លួន គឺអ្នកខ្លះបណ្ដើររូបព្រះរាម អ្នកខ្លះបណ្ដើររូបព្រះលក្ស្មណ៍ អ្នកខ្លះបណ្ដើររូបព្រះនាងសិតា អ្នកខ្លះបណ្ដើររូបហនុមាន អ្នកខ្លះបណ្ដើររូបពលស្វា អ្នកខ្លះបណ្ដើររូបកពណ៌ ជាដើម ។ ខាងណាំងស្បែកគេលេងភ្លេងពិណពាទ្យ, ខាងណាំងទ្រលុងគេលេងភ្លេងខ្លងខែក មានគ្នា ៧ នាក់ គឺ ២ នាក់កាន់រូបស្បែក, ១ នាក់កាន់គងម៉ង់, ១ នាក់កាន់ឆាប, ២ នាក់កាន់ក្រាប, ១ នាក់ទៀតជាតួក ។

ទាំងណាំងស្បែកទាំងណាំងទ្រលុង គេបញ្ចាំងរូបស្បែកខ្មៅ ៗ លើស្បៃសឲ្យធ្លុះឃើញជាឆាកវេចុះឡើង ជាដេក ដើរ ឈរ អង្គុយ ជាចំបាំងគ្នា ជាស្នេហា ជាទុក្ខព្រួយ ទៅតាមរឿងដូចគ្នា, ថ្វែកតែណាំងស្បែកអ្នករបាំទាំង ៣០ នាក់ ជាបណ្ដាំងបណ្ដើររូបបង្ហាញខ្លួនពីក្រៅស្បៃ, ឯណាំងទ្រលុងមានអ្នករបាំតែ ២ នាក់ កាន់រូប ១ម្នាក់ បំបាំង

ខ្លួនពីក្នុងស្បៃប៉ុណ្ណោះ តែត្រូវគ្នាត្រង់ណាំងស្បៃកនឹងណាំងទ្រលុងអ្នកបណ្តើររូបនឹងអ្នកកាន់រូបណា និយាយរឿងរូបនោះខ្លួនឯងដូចគ្នា ។

តាមដែលយើងបានសង្កេតស៊ើបសួរចាស់ទុំអ្នកចេះដឹងចំពោះរឿងនេះ បានការណ៍ថា ណាំងស្បៃក អ្នកស្រុកហៅថា ណាំងស្បៃក តាមធម្មតា ឥតមានកែប្រែទេ, ឯណាំងទ្រលុង គេហៅថា ណាំងទ្រលុងផង ថា តាយ៉ីងផង, ដែលគេហៅថា តាយ៉ីង នោះ ព្រោះមានជនម្នាក់ឈ្មោះ យ៉ីង មានទីលំនៅនៅភូមិព្រែកតាឡុង ឃុំចាក់អង្រែ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល គាត់ជាគ្រូណាំងទ្រលុងយ៉ាងជំនាញផ្តាច់តែលេងណាំងទ្រលុងក្នុងព្រះរាជពិធីនានា នៅចុងរជ្ជកាលព្រះករុណាសុវណ្ណកោដ្ឋ ដល់មករជ្ជកាលព្រះករុណា ភជាធុកោដ្ឋ អំណើះពីឈ្មោះយ៉ីងទៅ អ្នកស្រុកជាប់ហៅណាំងទ្រលុងថា "តាយ៉ីងៗ" ហេតុដល់សព្វថ្ងៃ; ដូចឈ្មោះយ៉ៃដែលមានទីលំនៅ ៗ ភូមិត្រពាំងតា ឃុំពងទឹក ស្រុកភ្នំពេញ ខេត្តកណ្តាលជាអ្នកផ្តើមបង្កើតភ្លេងនិងចម្រៀងមួយ មានស្គរដៃ ១ ទ្រ ២ ឬ ៣ ខ្លុយ ១ ក្រាប់ដៃ ១ ក្រាប់សេក ១ ឈិង ១ មុនគេបំផុតក្នុងរជ្ជកាលព្រះករុណាខត្តិយកោដ្ឋ ។ តាំងពីភ្លេង, ចម្រៀងនេះកើតឡើង អ្នកស្រុកទាំងពួងនិយមរាប់អានណាស់ ដល់អំណើះពីឈ្មោះយ៉ៃទៅ អ្នកស្រុកហៅក្រុមភ្លេងនេះថា "ភ្លេងតាយ៉ៃ, ចម្រៀងតាយ៉ៃ" ហេតុដល់សព្វថ្ងៃតាមឈ្មោះយ៉ៃអ្នកផ្តើមដំបូង តែជួនកាលគេហៅថា "ភ្លេងត្រពាំងតា" តាមឈ្មោះស្រុកដែលឈ្មោះយ៉ៃជាអ្នកផ្តើមនោះនៅ ។

៤– កន្ត្រឹម : របាំនេះជារបាំរបស់អ្នកស្រុកតាមជម្ពា ជារបស់រាជការចំពោះតែពេលណាដែលមានព្រះរាជពិធីផ្សេង ៗ មានព្រះរាជពិធីរាជាភិសេកជាដើម ដែលរាជការត្រូវការហៅមកឲ្យលេងម្ដង ៗ ។ របាំនេះ មានតួអ្នករបាំចំនួន ៥ នាក់ មានប្រុសមានស្រីលាយគ្នា គឺ

– ប្រុស ៣ នាក់ជាអ្នកភ្លេង ស្លៀកសំពត់ចងក្បិន ពាក់អាវបំពង់ខ្លី ម្នាក់កាន់គងវង់ ១ វង់ ម្នាក់កាន់ទ្រខ្មែរ ម្នាក់កាន់ចាប៉ី ម្នាក់ទៀតកាន់ខ្លុយ សម្រាប់រាយកូតដេញផ្គុំជាបទភ្លេងពុំកែវ តម្រូវតាមចង្វាក់រាំ ;

– ស្រី ២ នាក់ជាអ្នករាំ ស្លៀកសំពត់ហូលសម្ពុយ ពាក់អាវបំពង់វែងពណ៌បៃតង បង់កសំយុង ក្បាលពាក់វៃ ដៃឆ្វេងស្ដាំកាន់ផ្ចិតក្រដាស រាំតាមចង្វាក់ភ្លេង ។

៥– រាំស្នែងទន្សោង : របាំនេះ គេហៅឈ្មោះ ២ យ៉ាង គឺហៅថា “ រាំស្នែងទន្សោង ” តាមដែលមានពាក់ស្នែងទន្សោងក្នុងទីនោះក៏បាន ហៅថា “ បុកកំប្រុក ” តាមដែលមានបុកកំប្រុកក៏បាន, មានតួអ្នករបាំចំនួន ១៦ នាក់ សុទ្ធតែប្រុសស្លៀកសំពត់ចងក្បិន ពាក់អាវបំពង់ខ្លី គឺ :

– ២ នាក់ជាអ្នកបើកបទឲ្យអ្នកឯទៀតបន្ទរតាម ;

– ២ នាក់កាន់ដងកំប្រុក ដែលមានសណ្ឋានដូចដងកញ្ជ្រា សម្រាប់បុកតាមចង្វាក់ភ្លេង ·

– ២ នាក់កាន់ប៉ុពក.

– ២ នាក់កាន់ស្គរជី;

– ២ នាក់ពាក់ស្នែងទន្សោងសម្រាប់ស្តេចតាំបាញ់;

– ២ នាក់ពាក់កន្ទុយក្ងោកសម្រាប់ស្តេចតាំបាញ់;

– ២ នាក់ពាក់ក្បាលសេះ សម្រាប់កៀងទន្សោង;

– ១ នាក់ស្លៀកពាក់ជាស្តេចទ្រនំ សម្រាប់តាំបាញ់ទន្សោងនឹងក្ងោក;

– ១ នាក់ ហៅថា មេជាគ្រូ សម្រាប់បង្អក់ប្រាប់ឲ្យពួកអ្នកកំដរបូងនឹងដើរនាំមុខហ្វូងក្នុងពេលចេញលេង ។

របាំនេះ សព្វថ្ងៃគេឃើញមានតែនៅខេត្តពោធិ៍សាត់ ។

របាំតាំង ៥ មុខ ដូចរៀបរាប់មកខាងលើនេះ តាមដែលបានស៊ើបសួរមកបានការណ៍ថា សម័យបុរាណវេលាមានធ្វើព្រះរាជពិធីធំ ៗ ជាផ្លូវការម្តង ៗ មានព្រះរាជពិធីរាជាភិសេកជាដើម រាជការបានចាត់ឲ្យលេងជាវេន ៗ នៅមុខព្រះបរមរាជវាំងជាមួយនឹងល្បែង ៥ មុខទៀត គឺស្ពឺព្រែត យោលទោង ដាំដូង គុនដំបង ស្វិលពាក្យាល់ តម្រៀបគ្នាជាជួរឃ្លាត ៗ ពីគ្នា តាមលំដាប់ជាភាពស្មើនគ្រប់ ៗ កណ្តាលហ្វូងល្បែងរបាំតាំងនោះ មានពេនដ៏កល់ស្គរ ១ ដែលមានគូរមុខរាហូនៅលើស្បែកពាស ហៅថា "ស្គរជ័យ" សម្រាប់ឲ្យមនុស្សប្រុសម្នាក់ស្លៀកខោស្នាប់ភ្លៅ ពាក់អាវដាយក្រហម ជួតក្បាលក្រហម កាន់អន្ទងតាំវាយឲ្យសញ្ញាដល់ល្បែងរបាំតាំងទាំងពួង ។ វេលាលេងម្តង ៗ ពួកអ្នកល្បែងរបាំគ្រប់មុខត្រៀមតាំស្តាប់សូរស្គរជ័យ, ពេលផ្តើមលេងអ្នកតាំវាយស្គរ

ជ័យ ក៏ផ្ដើមវាយឡើង ៣ អន្ទង រង្វើល ៗ , ដល់អន្ទងទី ៣ ល្បែងប៉ាំគ្រប់មុខក៏ចាប់ផ្ដើមលេងឡើងតំណាលគ្នា , ដល់ពេលឈប់គេក៏តាំងវាយស្គរជ័យ ៣ អន្ទងទៀត ឲ្យសញ្ញាឈប់ ។

និគមវិបផៈ

បទសេន្ទតិលកា ពាក្យ ១៤

រជាំបុរាណ របស់ជាតិខ្មែរ ជាគ្រឿងផ្ទះ ប្រាប់ពេញលោក,
ថាខ្មែរមានជោគ មានអារ្យធម៌ ល្អប្រសើរ ពីព្រេងនាយ,
ថាខ្មែរជាជាតិ បរមបុរាណ ធ្លាប់មានយស ខ្ពស់ទូលាយ,
ថ្កុំថ្កើងព្រោងព្រាយ ផ្សាយមហាអំណាច នៅអាស៊ី ទ្វីបនេះណា ។
ផ្ទួច្នេះជនខ្មែរ គួររក្សាថៃ រជាំខ្មែរ ពីបុរាណ,
ឲ្យគង់វង្សបាន ជាចេរៈកាល ល្អត្រកាល យ៉ាងថ្លៃថ្លា,
សមតាមពូជខ្មែរ ដែលធ្លាប់ល្បីល្បាញ ខាងរជាំ ក្នុងលោកា
ដោយមានជួនតា ជាមហាក្សត្រ ស្ថាបនា ទុកតមក !

ប៉ាប - ពិន

# កំណត់ចំណាំ ប្រវត្តិការណ៍

## ដំណើរទៅកាន់ប្រទេសភូមា

## នៃភិក្ខុ ៨ រូប

ព្រះញាណវីរិយៈ វ៉ាន់-សាឌុម ក្រុមជំនុំព្រះត្រៃបិដក

រៀបរៀង

---

ដើម្បីទៅកាន់សន្និបាតកម្មបត្តគារៈ នៃឆដ្ឋសង្គាយនា នៅប្រទេសភូមា នាថ្ងៃសុក្រទី ១៦ ធ្នូ ១៩៥៥ តាមសេចក្ដីអញ្ជើញនៃរដ្ឋាភិបាលប្រទេសនេះ រាជរដ្ឋាភិបាលប្រទេសកម្ពុជាបានចាត់ភិក្ខុ ៨ រូប គឺ

១– ព្រះគ្រូវិសុទ្ធមុនី ថ្វាង-អ៊ុត វត្តឧណ្ណាលោម ជាប្រធាន

២– ព្រះបាលដ្ឋសទ្ធាវង្ស ឥន្ទ-ក្ដិប " ជាសមាជិក

៣– ព្រះបាលដ្ឋធម្មឃោសាវត្ថិត ហ៊ុយ-អ៊ុច វត្តសារាវ័ន ,,

៤– ព្រះមហា យ៉ញ្ញ-កែវ វត្តលង្កា ,,

៥– ព្រះញាណវីរិយៈ វ៉ាន់-សាឌុម វត្តទួនមណីរាម ,,

៦– ព្រះគ្រូសិរីបញ្ញាមុនី នូ-យ៉ែន វត្តបទុមវតី ,,

៧– ឧបាសកទេស-សារឿម វេយ្យាវច្ចករ សម្រាប់មហានិកាយ

៨– ឧបាសកពៅ-ប៊ុនយ៉ង់ ,, សម្រាប់ធម្មយុត្តិកនិកាយ ។

នៅថ្ងៃពុធទី ៧ ធ្នូ ១៩៥៥ ភិក្ខុទាំង ៨ រូបនេះ បានធ្វើដំណើរទៅតាមអាកាសយាន ចុះស្នាក់នៅក្រុងបាងកកប្រទេសថៃអស់ ៤ រាត្រី ។

ថ្ងៃទី ១១ ធ្នូ បានបន្តដំណើរទៅដល់ក្រុងរង្គូនប្រទេសភូមា ។ ពុទ្ធសា-
សនសភា បានចាត់ឲ្យស្នាក់នៅបន្ទប់លេខ ១៥-១៧-នឹង ១៩ ជាន់
ទីពីរនៃមហាកុដិមួយឈ្មោះ ឬព្រៃទេវៈ ក្នុងចំណោមមហាកុដិទាំងបួន
ប្របមហាបាសាណគុហា ។

ថ្ងៃ ១៦ ធ្នូ ព្រះសង្ឃជាប្រតិភូទាំង ៦ រូប បានចូលក្នុងមហាបា-
សាណគុហា ដើម្បីប្រជុំសង្គាយនា ជាមួយព្រះសង្ឃជាសង្គីតិការកៈ
ប្រមាណ ២០០០ រូប ។ ក្នុងវារៈនេះ ជាសម័យប្រជុំដែលត្រូវប្រតិភូ
ប្រទេសថៃជាប្រធាន បានចាប់សង្គាយនាអភិធម្មបិដក ត្រង់គម្ពីរបដ្ឋាន
រួចសង្គាយនាសុត្តន្តបិដក ត្រង់គម្ពីរខុទ្ទកនិកាយ គឺខុទ្ទកបាឋ១ ធម្មបទ១
ឧទាន ១ ឥតិវុត្តក ១ សុត្តនិបាត ១ វិមានវត្ថុ ១ បេតវត្ថុ ១ ថេរគាថា ១
ថេរីគាថា ១ អបទាន ១ ចរិយាបិដក ១ នឹងនិទ្ទេស ១ ។ កាលសង្គាយ-
នាចប់គម្ពីរនិទ្ទេសហើយ ក៏ប្រកាសបិទសម័យប្រជុំ ។ នៅសល់គម្ពីរ ៥
ឈ្មោះទៀត គឺ ជាតក ១ បដិសម្ភិទាមគ្គ ១ មិលិន្ទបញ្ហា ១ បដកោប-
ទេស ១ និរុត្តិប្បករណ៍ ១ ដែលកំពុងពិនិត្យផ្ទៀងផ្ទាត់បោះពុម្ព ហើយ
នឹងលើកកាន់សង្គាយនា ក្នុងវារៈសន្និបាតខាងក្រោយនេះ ។

សង្គីតិវារៈនេះ មានថិរវេលា ២ ខែ គឺបើកសម័យនៅថ្ងៃទី ១៦ ធ្នូ
១៩៥៤ បិទសម័យនៅថ្ងៃទី ១៦ កុម្ភៈ ១៩៥៦ ។ តពីនោះមកពុទ្ធ-
សាសនសភាបានជូនដំណើរ ពួកព្រះសង្គីតិការកៈទៅមើលទីនមស្ការ
ព្រះចេតិយដ្ឋាននានា ដល់ថ្ងៃទី ២៦ កុម្ភៈ ទើបប្រតិភូប្រទេសកម្ពុជា បាន
ឱកាសវិលត្រឡប់ពីប្រទេសភូមាវិញ ស្នាក់នៅប្រទេសថៃអស់ ៨ រាត្រី

ហើយមកដល់ប្រទេសកម្ពុជា នៅថ្ងៃទី៥ មីនា ១៩៥៦ ដោយសុវត្ថិភាពៗ

## ព្រឹត្តិការណ៍ថ្មីខ្លះនៅប្រទេសភូមា

## ១_ វត្តជាទីសក្ការយកា

ប្រទេសភូមា មានប្រជាជនជាង ១៨ លាននាក់ប្រហែលប្រទេសថៃ មានការគ្រប់គ្រងតាមរបបប្រជាធិបតេយ្យសាធារណរដ្ឋ ។ ដោយប្រទេសនេះរងគ្រោះយ៉ាងធ្ងន់ ព្រោះមហាសង្គ្រាមទីពីរដែលទើបរលត់ទៅនេះផង ទាំងដោយប្រាថ្នាឲ្យឯករាជ្យដែលទើបត្រឡប់បានមកថ្មីៗនេះមានដំហររាំងបុងបិតបេរគេទៅផង ទើបប្រជាជនភូមា មានលោក អ៊ូ-ក:អ៊ូ ប្រធានាធិបតី ទាំងលោក អ៊ូ-នូ នាយករដ្ឋមន្ត្រីជាដើម រឹតតែបញ្ចេញអាការស្អប់ខ្ពើមសង្គ្រាម ហើយស្រឡាញ់ពេញចិត្ត ខំកសាងសន្តិភាពដោយមធ្យោបាយផ្សេងៗ ។

ដើម្បីជាមធ្យោបាយមួយយ៉ាងឯកកងការកសាងនោះ ក៏ស្រុសគ្នាបង្កើតសន្តិសភា ដែលមានពុទ្ធសាសនសភាជាបង្អែក បរិច្ចាគធនធានជាប្រាក់ពប់លានរូបីយ៍ សាងអាស់សពិសេស ១ ជារបស់ពជការសម្រាប់ព្រះសង្ឃបតុទិសមិនចំពោះនិកាយ លើទីទួលធំទូលាយមួយកន្លែង ហៅ សិរិមង្គលបពត៌ (ឥឡូវហៅ កបាអេ) ដែលពីដើមជាចម្ការកៅស៊ូ តាំងនៅទិសខាងជើងក្រុងរង្គូន ចម្ងាយប្រហែល ៨ គីឡូម៉ែត្រ ពីព្រះចេតិយធំយ៉ាងស័ក្តិសិទ្ធិមួយហៅថា "សិង្គុត្ត:" ដែលប្រតិស្ឋាននៅកណ្តាលក្រុងនេះ ។

ក្នុងអាវាសនោះ គេបានសាងជាវត្ថុផ្សេងៗ មានដើមដូចតទៅនេះ:

១– គុហាថ្មមួយយ៉ាងធំ ហៅថា មហាបាសាណគុហា សម្រាប់ជាទីប្រជុំសង្គាយនានៃក្រុមព្រះសង្ឃជាសង្គីតិការកៈ ទាំងខាងក្នុងប្រទេស ទាំងខាងក្រៅប្រទេស ដែលបាននិមន្តមកក្នុងវារៈប្រជុំ ។

២.– មហាកុដិបួនខ្នង ដែលមានឈ្មោះតាមនាមទ្វីបទាំងបួន សម្រាប់ជាទីស្នាក់អាស្រ័យនៃពួកព្រះសង្ឃជាសង្គីតិការកៈ និងពួកព្រះបាលិវិសោធកៈ ព្រមទាំងពួកសមណនិស្សិតផង ។

៣.– ភត្តសាលា (រោងចំអិនភត្ត) និងអាសនសាលា (រោងឆាន់) ព្រមទាំងទីបរិវេណដ៏ទូលំទូលាយ ។

៤.– ព្រះចេតិយយ៉ាងពិសេស ប្រដាប់ដោយកំពូលទិបមាសមួយ ហៅលោកសន្តិ ដែលក្នុងនោះជាទីប្រតិស្ឋានព្រះពុទ្ធរូបនិងព្រះសារីរិកធាតុ ។

៥.– ឧបោសថាគារៈ (រោងឧបោសថ) ជាទីសង្ឃសន្និបាតធ្វើសង្ឃកម្មមួយខ្នងយ៉ាងធំទូលាយ មានកំពូលទិបមាសខ្ពស់ស្រោង ។

៦.– សណ្ឋាគារសម្រាប់ទទួលភ្ញៀវពីទីឆ្ងាយឬពីនានាប្រទេស...។

ឥឡូវនេះ កំពុងបន្ទិកសាងទាំងយប់ទាំងថ្ងៃ នូវបណ្ណាល័យយ៉ាងសម្បើមអស្ចារ្យ ដើម្បីឲ្យសម្រេចទាន់វារៈមហាសន្និបាតលើកក្រោយនេះ ។

## ២ – របៀបសង្គាយនា

ក្នុងការសង្គាយនាលើកនេះ គេបានបង្កើតសង្គីតិសភាពីរៈ មួយ

តាំងនៅក្រុងមណ្ឌលេ ហើយមួយទៀតនៅក្រុងរង្គូន សម្រាប់ជាទីប្រជុំពួកព្រះសង្ឃបាលីវិសោធកៈ ដែលគេនិមន្តមកពីខាងក្នុងប្រទេសនិងក្រៅប្រទេស ដើម្បីពិនិត្យផ្ទៀងផ្ទាត់ជម្រះបាលីព្រះត្រៃបិដក ដែលមានស្រាប់ក្នុងប្រទេស និងដែលនាំមកពីក្រៅប្រទេស មានប្រទេសលង្កានិងកម្ពុជាជាដើម កាលបានពិនិត្យផ្ទៀងផ្ទាត់ហើយ ទើបប្រគល់ឲ្យពុទ្ធសាសនសភាបោះពុម្ពជាថ្មី តាំងពីព្រះវិនយបិដកជាដើមទៅ ។ រួចហើយទើបតាំងការសន្និបាតនិមន្តព្រះសង្ឃជាសង្គីតិការកៈ ពីខាងក្នុងប្រទេសនិងក្រៅប្រទេស មកប្រជុំបើកសម័យសង្គាយនា ។

ក្នុងសម័យសន្និបាតនីមួយ ៗ មានព្រះសង្ឃជាសង្គីតិការកៈរាប់រយខ្លះ រាប់ពាន់ខ្លះ មិនកំណត់ ។ បើការសង្គាយនាក្នុងសម័យណា មានថិរវេលាខ្លី ដូចក្នុងបឋមសន្និបាតនិងបច្ឆិមសន្និបាត ក៏មានច្រើនដល់រាប់ពាន់រូប ។ បើមានថិរវេលាវែង ៗ ដល់ទៅពីរខែ ដូចក្នុងបត្តការ-សន្និបាតនេះ ឃើញមានតែ ៦០០ រូបប៉ុណ្ណោះ ព្រោះកិច្ចឧបត្ថម្ភព្រះសង្ឃសង្គីតិការកៈទាំងនោះ ជាភារៈធ្ងន់លើពុទ្ធសាសនសភាទាំងអស់ ។

ការសង្គាយនានេះ មិនជាភារៈធ្ងន់អ្វីណាស់លើពួកព្រះសង្គីតិការកៈទេ ព្រោះបាលីដែលត្រូវលើកកាន់សង្គាយនា បានទទួលការពិនិត្យផ្ទៀងផ្ទាត់ជម្រះបោះពុម្ពរួចស្រេចអំពីពួកព្រះបាលីវិសោធកៈមកហើយ ៗ ហេតុនេះនៅវេលាបើកសម័យសង្គាយនាម្តង ៗ ក្នុងពេលរសៀលព្រះសង្គីតិការកៈទាំងឡាយ គ្រាន់តែចាត់ព្រះថេរៈពីររូប ឲ្យជាអ្នកសួរឆ្លើយដោយត្រួសត្រាយបន្តិច ៗ ជាបាលីខ្លះ ជាសម្រាយខ្លះ (ឲ្យសមដល់ទី

ប្រជុំដែលមានពួកព្រះសង្ឃនិងពួកគ្រហស្ថមកធ្វើចាំស្ដាប់ច្រើន ) តាមគោលព្រះបាលីព្រះត្រៃបិដក អស់វេលាចំនួនកន្លះម៉ោង ( លើសខ្លះបន្តិចបន្តួច ) ហើយបានដល់ត្រឹមណា, ព្រះសង្ឃគិការកៈទាំងឡាយក៏នាំគ្នាផ្ដើមអានស្វាធ្យាយព្រះបាលី, ខ្លះមើលសៀវភៅ ខ្លះទៀតស្ទូត្រមាត់ទទេ ចាំងព្រឹកទាំងរសៀលទៅដល់ត្រឹមណោះ គឺគ្រាន់តែធ្វើយកចំនងតាមដែលបានផ្ដើមកហើយ កងអរហន្តសម័យ ។ ព្រឹកធ្វើអស់វេលា ២ ម៉ោង រសៀល ២ ម៉ោង ( លើសខ្លះបន្តិចបន្តួច ) ។ ធ្វើរៀងរាល់ថ្ងៃ ឈប់តែថ្ងៃសីល ឬថ្ងៃបុណ្យពិសេសមួយដងមួយកាលប៉ុណ្ណោះ ។

សង្គាយនាលើកនេះ ប្រទេសភូមា បានសន្មតថាជាឆដ្ឋសង្គាយនា ព្រោះប្រទេសនេះទទួលស្គាល់តែសង្គាយនា ដែលបានធ្វើរួចមកហើយដូចសារពត៌មានបរទេសខ្លះបានសរសេរដូចតទៅនេះ :

សង្គាយនាលើកទី ១ ធ្វើនៅក្រុងរាជគ្រឹះ ក្រោយពេលដែលព្រះពុទ្ធទ្រង់ចូលបរិនិព្វានបន្តិចទៅ ដោយបានទទួលព្រះរាជានុញ្ញាតពីព្រះបាទអជាតសត្រូវ ។

សង្គាយនាលើកទី ២ ធ្វើនៅក្រុងវេសាលី ( កន្លែងព្រះមហាវីរៈទ្រង់ប្រសូត ) កងឆ្នាំ ៤៤៣ មុនគ្រិស្ដសករាជ ក្រោមការដែលនាំនៃព្រះបាទកាលាសោករាជ ។

សង្គាយនាលើកទី ៣ ធ្វើនៅក្រុងបាដលីបុត្រ នៅឆ្នាំ ៣០៨ មុនគ្រិស្ដសករាជ ដោយមានព្រះបាទធម្មាសោក ជាអ្នកបាត់ថែង

អញ្ជើញសមាជិកទាំងឡាយមកប្រជុំ ហើយបានបញ្ជូនបេសកជនជាច្រើននាក់ ទៅប្រទេសលង្កា ប្រទេសភូមា ដើម្បីនឹងផ្សាយលទ្ធិព្រះពុទ្ធសាសនានៅបួនប្រទេស ។

សង្គាយនាលើកទី ៤ ធ្វើនៅប្រទេសលង្កា ។ នៅក្នុងសង្គាយនានេះហើយ ដែលគេបានកត់ត្រាចម្លងអត្ថបទទាំងឡាយ ទុកជាលើកដំបូងបង្អស់ គឺនៅឆ្នាំ ២៩-១៣ មុនគ្រិស្តសករាជ ។

សង្គាយនាលើកទី ៥ ធ្វើនៅទីក្រុងមណ្ឌលេ ក្នុងឆ្នាំ១៨៧១(១) ។ នៅវេលានោះព្រះបាទមិនដូន-មិន (Mindon Min) បានទ្រង់ព្រះបញ្ជាឲ្យចារិកអត្ថបទដ៏សំខាន់នៃព្រះពុទ្ធសាសនា នៅផ្ទាំងសិលាកែវ ចំនួន ៧២៩ ផ្ទាំង ។ ផ្ទាំងសិលាចារិកនោះ បានផ្តល់ប្រយោជន៍យ៉ាងសម្បើមដល់អ្នកប្រាជ្ញដែលមកប្រជុំធ្វើ សង្គាយនាលើកទី៦ (ដែលក្នុងឆ្នាំនេះ កំពុងធ្វើនៅក្រុងរង្គូន ក្នុងករណីផ្ទៀងផ្ទាត់និងរៀបបោះពុម្ពជាថ្មីឲ្យបានត្រឹមត្រូវល្អ នូវអត្ថបទព្រះត្រៃបិដក) ។

ការប្រជុំធ្វើសង្គាយនាលើកទី ៦ នេះ មានភិក្ខុសង្ឃជាតិភូមាចំនួនជាង ៥០០ រូប បានចាប់ធ្វើសហការជាមួយអ្នកប្រាជ្ញព្រះសង្ឃជាតិឥណ្ឌា,

---

១ សង្គាយនាក្រៅពីនេះ ដូចចតុត្ថសង្គាយនា ក្នុងអរហន្តសម័យ នាក្រុងអនុរាធបុរីនៃលង្កាទ្វីប ក្នុងរជ្ជកាលព្រះបាទទេវានម្បិយតិស្សៈក្តី សង្គាយនាដែលមានមកក្នុងប្រទេសភូមា នារជ្ជកាលមនក្តី សង្គាយនា ដែលមានមកក្នុងប្រទេសថៃ នារជ្ជកាលណាវក្តី និងរជ្ជកាលថៃក្តី សូម្បីជាសង្គាយនាខាងថេរវាទ និងជារបស់រដ្ឋ ក៏ប្រទេសភូមាពុំបានទទួលស្គាល់ចុះនាមក្នុងលំដាប់នេះទេ ប្រហែលជាទីប្រជុំយល់ឃើញថាពុំប្រកបដោយអង្គគ្រប់គ្រាន់ល្មមរាប់ថាជាសង្គាយនា ឬ ពុំសូវមានគុណប្រយោជន៍យ៉ាងណាដឹង ? ។

លង្កា , ថៃ , ខ្មែរនិងលាវ ។ល។ ដែលជួយធ្វើការដើម្បីបោះពុម្ពផ្សាយ នូវព្រះពុទ្ធដីកាយ៉ាងត្រឹមត្រូវ ជាភាសាបាលី, ភូមា, ឥណ្ឌា, ទេវនាគរី, រ៉ូម៉ាំង និងភាសាអង់គ្លេស ក្នុងវិធានការដែលអាចធ្វើបាន ។

នេះគឺជាកិច្ចការមួយដ៏ប្រពៃនៃសាសនាធំជាសាកល ដែលព្រះសក្យមុនីបានទ្រង់បង្កើត អាចជួយស្រោចស្រង់អស់ទាំងប្រជាជាតិឲ្យផុតពាកសង្គ្រាមដោយយកពុទ្ធមន្ត គឺអហិង្សានិងមេត្រីកាពមកប្រើ ។ ដូច្នេះប្រទេសឥណ្ឌាមានប្រជាជនចំនួន ៣៦០ លាននាក់ បានត្រូវប្រឹងយ៉ាងអស់ទំហឹងធ្វើសហការជាមួយប្រទេសភូមា និងប្រទេសឯទៀតដែលកាន់ព្រះពុទ្ធសាសនាដែរ ដើម្បីជាប្រយោជន៍ដល់សាកលលោក ។

## ដំណើរដែលគួរគិត

នៅវេលាមុនមហាសង្គ្រាមលើកទី ២ នេះ ពួកពុទ្ធសាសនិកជនក្នុងប្រទេសនានាហាក់ដូចជាអស់សង្ឃឹមសោះទៅហើយ ថាយើងនឹងបានទៅមករកគ្នា ប្រជុំពិភាក្សាដោយស្មោះស្ម័គ្រ អំពីព្រះធម្មវិន័យរបស់ព្រះសាស្តាយើង ដូចក្នុងឧដ្ឋសង្គីតិកាលនេះឡើយ; ព្រោះសម័យនោះប្រទេសខ្លះជាអាណានិគមរបស់គេ ហើយខ្លះទៀត នៅក្រោមអាណា-ព្យាបាលរបស់គេ ។ សូម្បីប្រទេសខ្លះ ដែលនៅជាឯករាជ្យដកបមកក៏គ្មានឥទ្ធិពលនិងបំពេញករណីយកិច្ចចំពោះព្រះពុទ្ធសាសនា ឲ្យមានការទាក់ទងគ្នារវាងជនបរទេសបែបនេះបាន ។ ម៉្លោះហើយសូម្បីប្រទេសកម្ពុជាយើងផ្ដើមបង្កើតសមាគមណាមួយ ដើម្បីរួមកម្លាំងគ្នាលើកតម្កើង

ព្រះពុទ្ធសាសនា  ការនោះក៏ពុំបានឋិតថេរគ្មានផ្លូវសង្ឃឹម  ដូចពុទ្ធិក-សមាគមដែលតាំងឡើងក្នុងប្រទេសទាំងឡាយនៅសម័យនេះទេ ។

សម្តេចក្រុមព្រះរ័ត្នក្រណាវុធ  អធិបតីពុទ្ធសាសនបណ្ឌិតសភាព្រះនាមសុធារស  តែងមានព្រះបន្ទូលហើយព្រះបន្ទូលទៀត  ចំពោះខ្ញុំ (អ្នកសរសេររឿងនេះ) ថា:

"បើប្រទេសយើងឯករាជ្យ  យើងនឹងរួមកម្លាំងគ្នាបង្កើតសមាគម
"បញ្ជូនអ្នកចេះដឹងឲ្យទៅអប់រំវិជ្ជា  នឹងពិនិត្យមើលបុរាណចេតិយដ្ឋាន
"ព្រមទាំងកិច្ចការប្រតិបត្តិខាងពុទ្ធសាសនាក្នុងប្រទេសនានា  ហើយ
"ជ្រើសយកបែបបទទម្លាប់ទំនៀមដែលល្អ ៗ  មកបង្រៀនអប់រំជាតិ
"យើងឲ្យអនុវត្តតាម ។ បើធ្វើដូច្នេះបាន មិនយូរប៉ុន្មានប្រទេសយើងគង់
"សម្បូរអ្នកប្រាជ្ញ  ដែលអាចចូលកាន់មហាសន្និបាតនានាប្រទេសខាង
"ពុទ្ធសាសនា  ហើយញុំាំងសាសនានឹងប្រទេសយើងឲ្យមានកិត្តិយស
"ផ្សព្វផ្សាយទៅក្នុងសកលលោក ។ តែធ្វើម្តេច បើប្រទេសយើងនៅ
"ក្នុងនឹមរបស់គេ  កាលណាគេនឹងបើកឲ្យយើងធ្វើដូច្នោះបាន" ។

ដោយខ្ញុំធ្លាប់បានដឹងហេតុការណ៍ដូច្នេះ  ដល់ខ្ញុំបានទៅឃើញកិច្ចការពុទ្ធិកសមាគម (ដែលគេហៅថាពុទ្ធសាសនសមិតិ) នឹងការស្ថាបនាអាក់សថ្មី ជាទីសគ្គាយនា  ព្រមទាំងកិច្ចការគណៈកម្មការថែទាំព្រះមហា-ចេតិយដ្ឋាន  របស់រដ្ឋភូមានោះ  ខ្ញុំរឹតតែជ្រះថ្លាក្នុងកិច្ចការនោះខ្លាំងឡើង ហើយនឹកអាឡោះអាល័យសម្តេចព្រះបរមរាជបិតាសុធារសពន់ពេក ផ្សិត ខ្ញុំចង់ឲ្យព្រះអង្គបានទ្រង់ជ្រាប  ហើយទ្រង់អនុមោទនារីករាយចំពោះកិច្ច

កសនានៃព្រះពុទ្ធសាសនាផង ព្រោះសព្វថ្ងៃកំពុងមានព្រឹត្តិការណ៍ដើរទៅត្រូវចំទិសដៅឬចំណុចព្រះទ័យព្រះអង្គហើយ ។

វេលានេះ កិច្ចការរបស់ក្រុមខាងពុទ្ធសាសនា មានទំនងល្អណាស់ក្នុងពិធីសាងសាមគ្គី ឲ្យបានជិតស្និទ្ធជាមួយនានាប្រទេសពុទ្ធសាសនិក ទាំងខាងថេរវាទ ទាំងខាងអាចរិយវាទ នឹងការពង្រីកឥទ្ធិពលព្រះពុទ្ធ-សាសនាព្រមទាំងកិត្តិយសប្រទេសគេ ឲ្យប្រាកដទៅក្នុងសកលលោក ។ ក្រុមបានចំណាយប្រាក់សមាគមជាវង់សំខាន់ ៗ នៅប្រទេសលង្កាខ្លះ ប្រទេសឥណ្ឌាជាដើមខ្លះ សាងអាគារសម្រាប់ព្រះសង្ឃក្រុមទៅនៅស្នាក់អាស្រ័យ ដើម្បីនមស្ការព្រះចេតិយដ្ឋានផង ដើម្បីអប់រំបំពេញវិជ្ជាខាងពុទ្ធសាសនា និងផ្សាយព្រះពុទ្ធសាសនាជាដើមផង ។ តទៅយើងអាចជឿបានថា ដំណើរការរបស់ប្រទេសក្រុមនេះ នឹងអាចទាញដំណើរការរបស់ប្រទេសយើង ឲ្យមានសភាពចុះសម្រុងគ្នាខ្លះមិនខាន បើយើងឃើញច្បាស់ថា ដំណើរការគេមានហេតុផលល្អមែន ។

# ដំណើរគណៈប្រតិភូខ្មែរ

ទៅប្រជុំសន្និសីទនៅប្រទេសឥណ្ឌា

លោក បាប-ពិន រៀបរៀង

---

ព្រះរាជរដ្ឋាភិបាលប្រទេសកម្ពុជា បានចាត់ព្រះគ្រូសង្ឃសត្ថា បុណ្យ-សុម្ភាជ ជាប្រតិភូខ្មែរ ដោយមានសាមណេរ ស៊ុជទីហ៊ីល ជាគូស្គាល់ និងលោក គាន់-ប៊ូហេង ជាវេយ្យាវច្ចករផង ឲ្យទៅរួមប្រជុំសន្និសីទជាមួយនឹងគណៈកម្មាធិការទីប្រឹក្សានៅពុទ្ធគយាប្រទេសឥណ្ឌា កាលពីថ្ងៃទី ១៣ មីនា ព.ស. ២៤៩៩ គ.ស. ១៩៥៦ ។

សេចក្តីសង្ខេបក្នុងសន្និសីទនោះ ដូចតទៅនេះ :

សមាជិកគណៈកម្មាធិការទីប្រឹក្សាក្រៅប្រទេស និងក្នុងប្រទេសឥណ្ឌា ២២ រូប ដែលបានមកប្រជុំតែ ១៥ រូប បានចូលរួមប្រជុំនៅថ្ងៃទី ១៩ មីនា ១៩៥៦ ជា ២ លើក: លើកទី ១ នៅម៉ោង ១០ និង ៤៥ នាទីព្រឹក, លើកទី ២ នៅម៉ោង ១៤ រសៀល ។ កាលសមាជិកមកជួបជុំហើយ លោកពជគ្រិស្ណាន អនុប្រធានាធិបតីប្រទេសឥណ្ឌា បានថ្លែងសារលិខិតបើកសម័យប្រជុំ ។ បន្ទាប់មកលោក ស.គ. មុខរជី តំណាងរដ្ឋាភិបាលពិហារប្រទេសឥណ្ឌា បានអានសេចក្តីរាយការណ៍អំពីគោលសំខាន់ៗ របស់គណៈកម្មាធិការចាត់ចែងទីពុទ្ធគយាដូចពោលដោយសង្ខេបតទៅនេះ :

– អំពីដំណើរការដែលគណៈកម្មាធិការនេះ បានចាត់ចែងធ្វើមក

ផកបដល់ពុទ្ធគយាធ្លាក់មកនៅក្នុងកណ្ដាប់ដៃគណៈកម្មាធិការនេះ ពីថ្ងៃពេញបូណ៌មីខែវិសាខ ១៩៥៣ ;

— អំពីចំនួនហិរញ្ញវត្ថុដែលបូជនីយសក៍ និងទស្សនជនបានបូជាក្នុងមួយ ឆ្នាំ ៗ តាំងពីឆ្នាំ ១៩៥៣ · ៥៤-៥៥ មកទល់នឹងខែកុម្ភៈ ១៩៥៦ ដោយកាត់បំណាយចេញទៅនៅសល់ ១៦.៤៦៧ រូពីយ ៥០ ;

— អំពីការរៀបចំទីពុទ្ធគយា ឲ្យមានបរិវេណខាងក្រៅធំទូលាយ និងផូសផុលព្រះមហាចេតិយពុទ្ធគយាព្រមទាំងទីជុំវិញឲ្យបានល្អ ;

— អំពីការបែងចែកទីដីនៅពុទ្ធគយាឲ្យដល់រដ្ឋាភិបាលគ្រប់ប្រទេសពុទ្ធសាសនិកដែលត្រូវទទួលបដូលដោយមានកំណត់កាលដ៏យូរ ដើម្បីយកធ្វើវិហារ កុដិ បណ្ណាល័យ និងសាលាសំណាក់រៀងខ្លួន :

— អំពីការរៀបចំពិធីបុណ្យសម្ពោធពុទ្ធសករាជគម្រប់ ២៥០០ ;

— អំពីកាលបរិច្ឆេទធ្វើបុណ្យសម្ពោធពុទ្ធសករាជគម្រប់ ២៥០០ ។

ចំពោះបញ្ហាខាងក្រោយនេះ សមាជិកគ្រប់ប្រទេសបានមូលមតិថា និងព្រមព្រៀងគ្នាមកធ្វើបុណ្យនេះ នៅក្នុងខែវិច្ឆិកាវិញ ព្រោះខែនេះប្រទេសឥណ្ឌាមានអាកាសធាតុមិនក្ដៅណាស់ដូចខែឧសភា ហើយមិនទាន់ចូលស៊ប់ក្នុងរដូវរងាផង ទាំងត្រូវគ្នានឹងសន្និសីទពុទ្ធិកសមាគមពិភពលោកនៅក្រុងកដ្ឋមណ្ឌូនិងលុម្ពិនីប្រទេសនេប៉ាល់ក្នុងថ្ងៃទី ១០ ដល់ ២០ វិច្ឆិកាផង ។

## យោបល់នៃគណៈប្រតិភូខ្មែរ

ពុទ្ធគយាសព្វថ្ងៃ នៅក្នុងកណ្ដាប់ដៃ អ្នកកាន់សាសនាហិណ្ឌូនៅ

ទៀយ, ហើយក្នុងសមាជិកគណៈកម្មាធិការវាត់វែងទីពុទ្ធគយា ៩ រូប មានតែ ៤ រូបទេដែលជាពុទ្ធសាសនិក, ចាំងគណៈកម្មាធិការទីប្រឹក្សា ទៀតសោតក៏មានសមាជិកជាជាតិឥណ្ឌៀភាគច្រើន. ហេតុនេះគួរតែគ្រប់ប្រទេសពុទ្ធសាសនិក វាត់អ្នកតំណាងឲ្យទៅកាន់ទីប្រជុំគ្រប់ពេល ដែលប្រទេសឥណ្ឌៀត្រូវអញ្ជើញកុំខាន ដើម្បីឲ្យមានឋានៈប្រសើរ ចំពោះសេចក្ដីសម្រេចនីមួយៗ ដែលត្រូវជាប្រយោជន៍ចំពោះប្រទេស ពុទ្ធសាសនិកទាំងមូល ។

ប្រទេសកម្ពុជាគួរតែសុំឲ្យបានទីដីមួយកន្លែង នៅមណ្ឌលពុទ្ធគយា ដើម្បីសង់វិហារ កុដិ បណ្ណាល័យ សាលាសំណាក់ សម្រាប់ប្រទេស របស់ខ្លួន ។

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

គណៈប្រតិភូនេះ ត្រឡប់មកកាន់មាតុភូមិវិញ នៅថ្ងៃ ៤ មេសា ១៩៥៦ ។

---